អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION

# ព្រឹត្តិបត្រពន្ធដារ

## ត្រីមាសទី៤ ឆ្នាំ២០២៥










លេខ៖ ១៦

តុលា - ធ្នូ ២០២៥

# អារម្ភកថា



ក្នុងឆ្នាំ២០២៥ អគ្គនាយកដ្ឋានពន្ធដារ ដែលជាសេនាធិការក្នុងការគ្រប់គ្រងប្រមូលចំណូលពន្ធផ្ទៃក្នុង របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅតែបន្តចូលរួមអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ យ៉ាងពេញទំហឹង មោះមុត និងស្វាហាប់ ដែលបានដាក់ចេញដោយរាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ក្រោមការដឹកនាំពោរពេញដោយសមត្ថភាព ថាមពល និងបញ្ញាញាណដ៏ឆ្នើមរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ព្រមទាំងសម្រេចបានសមិទ្ធផលល្អប្រសើរថ្មីៗជាបន្តបន្ទាប់ ដែលបានជំរុញកំណើនសេដ្ឋកិច្ច បង្កើតការងារ ជានាសមធម៌ ប្រសិទ្ធភាព និងរក្សាចីរភាព ឈានទៅកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០ ជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ និងឆ្នាំ២០៥០ ជាប្រទេសមានចំណូលខ្ពស់។

អគ្គនាយកដ្ឋានពន្ធដារបានបន្តអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិ ដំណាក់កាលទី២ (២០២៤-២០២៨) ដែលកំណត់យកគោលបំណង និងគោលដៅជាយុទ្ធសាស្ត្រធំៗចំនួន ៣ គឺ ១.បង្កើនអនុលោមភាពសារពើពន្ធ តាមរយៈការលើកកម្ពស់គុណភាព ភាពច្បាស់លាស់ តម្លាភាព និងគណនេយ្យភាពក្នុងការផ្តល់សេវា និងការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ ២.បន្តធ្វើបរិវត្តកម្មឌីជីថលរដ្ឋបាលសារពើពន្ធ ដើម្បីក្លាយជារដ្ឋបាលសារពើពន្ធ ២.០ បូក និង ៣.បន្តអភិវឌ្ឍមូលធនមនុស្ស និងពង្រីកប្រសិទ្ធភាពការងារ។

ជាមួយនឹងគោលបំណងនិងគោលដៅជាយុទ្ធសាស្ត្រខាងលើ អគ្គនាយកដ្ឋានពន្ធដារបានធ្វើសកម្មភាពគាំទ្រជាច្រើន ព្រមទាំងបានធ្វើការផ្សព្វផ្សាយយ៉ាងទូលំទូលាយ តាមរយៈប្រព័ន្ធផ្សព្វផ្សាយនានា និងធ្វើការរៀបរៀងតាក់តែង និពន្ធ និងបោះពុម្ពឯកសារជាច្រើន ក្នុងទិសដៅផ្តល់សេវាគ្រប់មធ្យោបាយជូនអ្នកជាប់ពន្ធឱ្យកាន់តែប្រសើរ និងទទួលបានព័ត៌មានត្រឹមត្រូវនិងទាន់ពេលវេលា។ អគ្គនាយកដ្ឋានពន្ធដារបានរៀបចំបោះពុម្ពព្រឹត្តិបត្រពន្ធដារប្រចាំត្រីមាសបានចំនួន ១៥ លេខ តាំងពីដើមឆ្នាំ២០២២ និងបន្តចងក្រងបោះពុម្ពព្រឹត្តិបត្រពន្ធដារលេខ១៦ ប្រចាំត្រីមាសទី៤ ឆ្នាំ២០២៥ ដែលមានផ្នែកសំខាន់ៗរួមមាន ស្ថានភាពនៃការគ្រប់គ្រងប្រមូលចំណូលពន្ធ វឌ្ឍនភាពការងារនៃមុខងារប្រតិបត្តិការស្នូលនិងមុខងារគាំទ្រ បច្ចុប្បន្នភាពច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយសារពើពន្ធ កិច្ចសហប្រតិបត្តិការក្របខ័ណ្ឌជាតិ-អន្តរជាតិ និងការផ្សព្វផ្សាយនិងបញ្ជ្រាបវប្បធម៌បង់ពន្ធ។

តាងនាមឱ្យថ្នាក់ដឹកនាំ មន្ត្រីរាជការពន្ធដារគ្រប់លំដាប់ថ្នាក់ និងក្នុងនាមខ្ញុំផ្ទាល់ សង្ឃឹមយ៉ាងមុតមាំថា ព្រឹត្តិបត្រពន្ធដារនេះនឹងក្លាយជាប្រយោជន៍ដល់អ្នកអាន បានឈ្វេងយល់ឱ្យកាន់តែស៊ីជម្រៅពីកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋបាលសារពើពន្ធក្នុងការកៀរគរប្រមូលចំណូលពន្ធដើម្បីអភិវឌ្ឍប្រទេសជាតិ និងទទួលបាននូវបច្ចុប្បន្នភាពព័ត៌មានសំខាន់ៗ រយៈពេលពេញមួយត្រីមាសពីអគ្គនាយកដ្ឋានពន្ធដារ។

ថ្ងៃចន្ទ ១៥ កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ ២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២៦

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**

**ប្រតិភូរាជរដ្ឋាភិបាល**

**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**

# ព្រឹត្តិបត្រពន្ធដារ

## ត្រីមាសទី៤ ឆ្នាំ២០២៥


**សមាសភាពទទួលបន្ទុកតាក់តែង និពន្ធ និងបោះពុម្ពព្រឹត្តិបត្រពន្ធដារ**

| | | |
|---|---|---|
| និពន្ធនាយក | ៖ | ឯកឧត្តម **គង់ វិបុល** |
| គណៈដឹកនាំ | ៖ | លោក **រៀម រដ្ឋា** និងលោក **កែ ឈុំបញ្ញា** |
| អ្នករៀបរៀងអត្ថបទ | ៖ | លោកស្រី **សេង ច័ន្ទមុន្នី** លោកស្រី **ដេត ពុទ្ធាទី** លោក **រិន ណារ៉ូ** និងលោក **អាន ចាន់ថាណារិទ្ធ** |
| អ្នករចនា | ៖ | កញ្ញា **ឈៀង សុខឡេង** លោក **សារិន ម៉េងហៀង** និងលោក **លីម សិទ្ធិ** |
| អ្នកផ្តល់រូបភាព | ៖ | លោក **ឌិត្យ ចំរើនបញ្ញា** លោក **សុន្ទរៈ ត្រដឹម** និងលោក **ឥន្ទ វាសនា** |
| អ្នកស្រាវជ្រាវ | ៖ | លោក **ជុំ សូលីវណ្ណ** លោក **សំរិទ្ធ មករា** លោក **រិទ្ធ ភីណា** និងលោកស្រី **សាវិន វីនីហ្សា** |
| អ្នកកែសម្រួលនិងត្រួតពិនិត្យអក្ខរាវិរុទ្ធ | ៖ | លោក **អ៊ុន សំបុក** និងលោក **ជា ពិសិដ្ឋ** |
| អ្នកបោះពុម្ព | ៖ | លោក **ស៊ុនលី ដឺនី** |
| អ្នកផ្សព្វផ្សាយព័ត៌មាន និងចែកចាយ | ៖ | លោកស្រី **ឌីពៅ ទិត្យធីយ៉ា** លោក **មូ សុភ័ក្រ្ត** កញ្ញា **ស៊ូ សុដាវី** និងលោក **ឡាង ភក្រ្តា** |

# មាតិកា


ព្រឹត្តិការណ៍សំខាន់ៗ ..... ៦

ផ្នែកទី១៖ ស្ថានភាពនៃការគ្រប់គ្រងការប្រមូលចំណូលពន្ធ

១. លទ្ធផលនៃចំណូលពន្ធ ..... ៥១

២. ស្ថានភាពចំណូលពន្ធតាមប្រភេទអ្នកជាប់ពន្ធ ..... ៥១

៣. ស្ថានភាពចំណូលពន្ធតាមប្រភេទពន្ធសំខាន់ៗ ..... ៥២

៤. ស្ថានភាពចំណូលពន្ធតាមសកម្មភាពអាជីវកម្មសំខាន់ៗ ..... ៥៣

ផ្នែកទី២៖ វឌ្ឍនភាពការងារនៃមុខងារប្រតិបត្តិការស្នូល និងមុខងារគាំទ្រ

១. ការចុះបញ្ជីពន្ធដារ ..... ៥៧

២. ការផ្តល់សេវាអ្នកជាប់ពន្ធ ..... ៥៧

៣. ការចាត់ចែងលិខិតប្រកាសពន្ធ ..... ៦២

៤. ការធ្វើសវនកម្មពន្ធដារ ..... ៦៣

៥. ការប្រមូលបំណុលពន្ធ និងបណ្តឹងតវ៉ា ..... ៦៣

៦. បច្ចេកវិទ្យាព័ត៌មាន ..... ៦៤

ផ្នែកទី៣៖ បច្ចុប្បន្នភាពច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយសារពើពន្ធ

១. ប្រកាស ..... ៦៩

២. សេចក្តីណែនាំ ..... ៧១

៣. សេចក្តីជូនដំណឹង ..... ៧២

៤. សារាចរណែនាំ ..... ៧៥

ផ្នែកទី៤៖ កិច្ចសហប្រតិបត្តិការក្របខ័ណ្ឌជាតិ-អន្តរជាតិ

១. កិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័ន ..... ៧៩

២. កិច្ចសហប្រតិបត្តិការជាមួយវិស័យឯកជន អង្គការ សមាគម និងស្ថាប័នអន្តរជាតិ ..... ៨៦

៣. កិច្ចព្រមព្រៀងស្តីពីការយកពន្ធត្រួតគ្នា (Double Taxation Agreement-DTA) ..... ៩៥

៤. សកម្មភាពផ្សេងៗរបស់អគ្គនាយកដ្ឋានពន្ធដារ ..... ៩៦

ផ្នែកទី៥៖ ការផ្សព្វផ្សាយ និងបញ្ជ្រាបវប្បធម៌បង់ពន្ធ

១. កិច្ចការបណ្តុះបណ្តាល និងសិក្ខាសាលារបស់សាលាជាតិពន្ធដារ ..... ១១០

២. ការស្រាវជ្រាវ អភិវឌ្ឍន៍កម្មវិធី និងបណ្ណាល័យ ..... ១១២

៣. សិក្ខាសាលាសំខាន់ៗ ..... ១១៣

# ទស្សនវិស័យ

អគ្គនាយកដ្ឋានពន្ធដារ ជាស្ថាប័នសាធារណៈ
ដែលត្រូវបានជឿជាក់ គោរព និងទទួលស្គាល់លើ
គុណភាពនិងជំនាញ ក្នុងការប្រមូលចំណូលពន្ធក្នុងស្រុក
ដើម្បីចូលរួមអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព

# បេសកកម្ម

អគ្គនាយកដ្ឋានពន្ធដារ ពង្រឹងការអនុវត្តច្បាប់
និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ និងផ្តល់សេវាប្រកបដោយ
ស័ក្តិសិទ្ធិភាព តម្លាភាព គណនេយ្យភាព និងសុចរិតភាព ដើម្បីធានាបាននូវប្រសិទ្ធភាព
នៃការប្រមូលចំណូលពន្ធ និងលើកកម្ពស់អនុលោមភាពដោយស្ម័គ្រចិត្ត

# គុណតម្លៃ

អគ្គនាយកដ្ឋានពន្ធដារបំពេញបេសកកម្ម និង
ធ្វើប្រតិបត្តិការរបស់ខ្លួន ដោយប្រកាន់ខ្ជាប់នូវគុណតម្លៃ ដូចខាងក្រោម ៖

| ការអនុវត្ត | វិជ្ជាជីវៈ | ស័ក្តិសិទ្ធិភាព | សុចរិតភាព | ភាពបត់បែន |
|---|---|---|---|---|
| អនុវត្តច្បាប់ គាំទ្រអ្នកជាប់ពន្ធដែលមានអនុលោមភាព តែម៉ឺងម៉ាត់ចំពោះអ្នកជាប់ពន្ធដែលមិនមានអនុលោមភាព | ប្រើប្រាស់ក្រមសីលធម៌វិជ្ជាជីវៈ និងជំនាញ ដើម្បីផ្តល់នូវសេវាដែលមានភាពសាមញ្ញ ងាយស្រួល ឆ្លាតវៃ និងនវានុវត្តន៍ | ប្រើប្រាស់ធនធានដោយសន្សំសំចៃ ទាន់ពេលវេលា និងចំគោលដៅ | ផ្តល់សេវាអ្នកជាប់ពន្ធដោយស្មើភាព តម្លាភាព និងស្អាតស្អំ | ឆ្លើយតបយ៉ាងសកម្មទៅនឹងបញ្ហាប្រឈម និងទាញយកប្រយោជន៍ពីគ្រប់ឱកាសដែលមាន |

# គោលបំណង

អគ្គនាយកដ្ឋានពន្ធដារបានកំណត់ចេញនូវគោលបំណងជាយុទ្ធសាស្ត្រសំខាន់ៗ
ចំនួន៣ សម្រាប់ជាត្រីវិស័យក្នុងការតម្រង់ទិសនៃកំណែទម្រង់រដ្ឋបាលសារពើពន្ធ

| គោលបំណងទី១ | គោលបំណងទី២ | គោលបំណងទី៣ |
|---|---|---|
| បង្កើនអនុលោមភាពសារពើពន្ធ តាមរយៈការលើកកម្ពស់គុណភាព ភាពច្បាស់លាស់ តម្លាភាព និងគណនេយ្យភាពក្នុងការផ្តល់សេវា និងការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ | បន្តធ្វើបរិវត្តកម្មឌីជីថលរដ្ឋបាលសារពើពន្ធ ដើម្បីក្លាយជារដ្ឋបាលសារពើពន្ធ ២.០ បូក | បន្តអភិវឌ្ឍមូលធនមនុស្ស និងពង្រឹងប្រសិទ្ធភាពការងារ |

# “យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១”

## ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និង ចីរភាព
## កសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០

### បាវចនា ៥៖

កំណើន, ការងារ, សមធម៌, ប្រសិទ្ធភាព និងចីរភាព

### អាទិភាពគន្លឹះ ៥៖

មនុស្ស, ផ្លូវ, ទឹក, ភ្លើង និងបច្ចេកវិទ្យាឌីជីថល

### គោលដៅយុទ្ធសាស្ត្រ ៥៖

១.កំណើនសេដ្ឋកិច្ច ៧% ប្រចាំឆ្នាំ ២.បង្កើនការងារ (បរិមាណ និងគុណភាព) ៣.កាត់បន្ថយភាពក្រីក្រ ៤.ពង្រឹងប្រសិទ្ធភាពការងារ និង៥.ចីរភាពនៃការអភិវឌ្ឍសង្គមជាតិនិងការកសាងភាពធន់

### ស្នូលនៃយុទ្ធសាស្ត្រ ៥៖ អភិបាលកិច្ច

១. ការកែទម្រង់ស្ថាប័ន
២. ការពង្រឹងប្រសិទ្ធភាពការងារ
៣. ការពង្រឹងភាពស្អាតស្អំក្នុងរដ្ឋបាលសាធារណៈ
៤. ការពង្រឹងប្រសិទ្ធភាពច្បាប់ និងប្រព័ន្ធយុត្តិធម៌ និង
៥. អភិបាលកិច្ចវិស័យឯកជន

### បរិស្ថានគ្របដណ្តប់ ៥៖

១.ការបន្តពង្រឹងសន្តិភាព ស្ថិរភាព សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ
២.ការប្រកាន់ខ្ជាប់នូវនយោបាយការបរទេសឯករាជ្យផ្អែកច្បាប់និងឈ្លាសវៃ
៣.ការធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច
៤.ការកសាងភាពជាដៃគូ និង
៥.ការបន្តធ្វើសមាហរណកម្មស៊ីជម្រៅក្នុងតំបន់ និងសកលលោក

### បញ្ចកោណយុទ្ធសាស្ត្រ ៥៖

**បញ្ចកោណទី១៖** ការអភិវឌ្ឍមូលធនមនុស្ស
**បញ្ចកោណទី២៖** ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការបង្កើនភាពប្រកួតប្រជែង
**បញ្ចកោណទី៣៖** ការអភិវឌ្ឍវិស័យឯកជន និងការងារ
**បញ្ចកោណទី៤៖** ការអភិវឌ្ឍប្រកបដោយភាពធន់, ចីរភាព និងបរិយាបន្ន
**បញ្ចកោណទី៥៖** ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថល

### កម្មវិធីគោលនយោបាយអាទិភាព ៦ សម្រាប់ចាប់ផ្តើមអនុវត្តភ្លាមក្នុងឆ្នាំ២០២៣៖

១.ការពង្រីកសេវាថែទាំសុខភាព ឆ្ពោះទៅរកការគ្របដណ្តប់សុខភាពជាសកល ២.ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនិងបច្ចេកទេស ជូនដល់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យនៅទូទាំងប្រទេស ៣.ការធ្វើស្ថាបនូបនីយកម្មកម្មវិធីជាតិជំនួយសង្គម សម្រាប់គ្រួសារក្រីក្រ ក្រុមជនងាយរងគ្រោះនៅក្នុងគ្រួសារក្រីក្រនិងគ្រួសារងាយរងហានិភ័យនៅក្នុងគ្រាមានវិបត្តិសេដ្ឋកិច្ច និងគ្រាមានអាសន្ន ៤.ការដាក់ចេញយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ (ចូលរួមក្នុងប្រព័ន្ធនិងអាចទទួលបានផលប្រយោជន៍ពីប្រព័ន្ធគាំពារសង្គមផ្លូវការ) ៥.ការដាក់ចេញនូវយន្តការសម្របសម្រួល និងកម្មវិធីហិរញ្ញប្បទាន សំដៅលើកស្ទួយផលិតកម្ម រកទីផ្សារ និងរក្សាលំនឹងថ្លៃកសិផលសំខាន់ៗ ក្នុងកម្រិតសមរម្យ និង៦.ការដាក់ពង្រាយមន្ត្រីបច្ចេកទេសកសិកម្មទៅគ្រប់ឃុំ-សង្កាត់ ដែលមានសកម្មភាពកសិកម្មនៅទូទាំងប្រទេស។

### វិធានការគន្លឹះ ៥៖

១.ការពង្រឹងសមត្ថភាពរដ្ឋបាលសាធារណៈ (ពង្រឹងគុណភាព ប្រសិទ្ធភាពនិងសមិទ្ធកម្មរបស់មន្ត្រី និងស្ថាប័ន) ២.ការលើកកម្ពស់គុណភាពអប់រំ (ពង្រឹងគុណភាពសាលារដ្ឋពីថ្នាក់មត្តេយ្យដល់មធ្យមសិក្សា-K12) ៣.ការលើកកម្ពស់គុណភាពសេវាសុខាភិបាល (ពង្រឹងសមត្ថភាពផ្តល់សេវាសុខភាពបឋមនៅមូលដ្ឋាន) ៤.ការពង្រឹងការអនុវត្តគោលនយោបាយ ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព (កាត់បន្ថយ និងឈានទៅដល់ការលុបបំបាត់ការជួញដូរ និងការប្រើប្រាស់គ្រឿងញៀននៅក្នុងសហគមន៍) និង៥.ការពង្រឹងនិងលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌។

# ព្រឹត្តិការណ៍សំខាន់ៗ



ឯកឧត្តម **គង់ វិបុល** ចូលរួមកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

សូមអានពិស្តារនៅទំព័រទី ១១



ឯកឧត្តម **គង់ វិបុល** ចូលរួមអម**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសទទួលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយគណៈប្រតិភូក្រុមប្រឹក្សាធុរកិច្ចសហរដ្ឋអាមេរិក-អាស៊ាន

សូមអានពិស្តារនៅទំព័រទី ១៣




សម័យប្រជុំលើកទី៤នៃព្រឹទ្ធសភាបានឯកភាពទាំងស្រុងលើសេចក្តីព្រាងច្បាប់ពាក់ព័ន្ធនឹងថវិកាជាតិ និងការលុបបំបាត់ការយកពន្ធត្រួតគ្នា

សូមអានពិស្តារនៅទំព័រទី ១៤



ឯកឧត្តម **គង់ វិបុល** ចូលរួមអម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ចូលរួមកិច្ចប្រជុំពិភាក្សារវាងរាជរដ្ឋាភិបាល ជាមួយអន្តរគណៈកម្មការសភា លើសេចក្តីព្រាងច្បាប់សំខាន់ៗមួយចំនួន

សូមអានពិស្តារនៅទំព័រទី ១៦



ឯកឧត្តម **គង់ វិបុល** ចូលរួមអម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ចូលរួមសិក្ខាសាលាសភាដើម្បីឈ្វេងយល់ពីការកសាងក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់រៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦

សូមអានពិស្តារនៅទំព័រទី ១៨



ឯកឧត្តម **គង់ វិបុល** ចូលរួមអម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ដើម្បីការពារសេចក្តីព្រាងច្បាប់មួយចំនួននៅវិមានរដ្ឋសភា

សូមអានពិស្តារនៅទំព័រទី ២០




សមាគមសភាពាណិជ្ជកម្មអាមេរិកនៅកម្ពុជា ថ្លែងអំណរគុណ ឯកឧត្តម **គង់ វិបុល** ចំពោះកិច្ចសហការរៀបចំវេទិកាពន្ធដារ ឆ្នាំ២០២៥ របស់ AmCham ដែលបង្ហាញពីការធានាតម្លាភាព និងភាពច្បាស់លាស់ជូនវិនិយោគិន

សូមអានពិស្តារនៅទំព័រទី ២២



ឯកឧត្តម **គង់ វិបុល** ទទួលជួបសម្តែងការគួរសមនិងពិភាក្សាការងារជាមួយ ឯកឧត្តម Dominic Williams ឯកអគ្គរាជទូតអង់គ្លេសប្រចាំនៅកម្ពុជា

សូមអានពិស្តារនៅទំព័រទី ២៦



ឯកឧត្តម **គង់ វិបុល** ទទួលជួបសម្ដែងការគួរសមជាមួយឯកឧត្តម Vanlalvawna Bawitlung ឯកអគ្គរដ្ឋទូតឥណ្ឌាប្រចាំព្រះរាជាណាចក្រកម្ពុជា

សូមអានពិស្ដារនៅទំព័រទី ២៨



អគ្គនាយកដ្ឋានពន្ធដារ និងសភាពាណិជ្ជកម្មកម្ពុជា រៀបចំកិច្ចប្រជុំពិភាក្សាលើបញ្ហាប្រឈមពាក់ព័ន្ធនឹងពន្ធដាររបស់វិស័យឯកជន

សូមអានពិស្ដារនៅទំព័រទី ៣០



ដំណើរទស្សនកិច្ចរបស់គណៈប្រតិភូធនាគារជាតិនៃកម្ពុជាមកកាន់អគារទីស្នាក់ការកណ្ដាលអគ្គនាយកដ្ឋានពន្ធដារ

សូមអានពិស្ដារនៅទំព័រទី ៣២



ឯកឧត្តម **គង់ វិបុល** ទទួលស្វាគមន៍ដំណើរទស្សនកិច្ច របស់ប្រតិភូសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជាមកកាន់ទីស្នាក់ការកណ្ដាលអគ្គនាយកដ្ឋានពន្ធដារ

សូមអានពិស្ដារនៅទំព័រទី ៣៤



ឯកឧត្តម **គង់ វិបុល** អញ្ជើញជាអធិបតីក្នុងពិធីប្រកាសចូលកាន់មុខតំណែងប្រធានទីចាត់ការពន្ធដាររាជធានីភ្នំពេញនិងប្រធានសាខាពន្ធដារខណ្ឌ៧មករា

សូមអានពិស្តារនៅទំព័រទី ៣៦



អគ្គនាយកដ្ឋានពន្ធដារនិងរដ្ឋបាលខេត្តកំពង់ធំ រៀបចំពិធីប្រកាសចូលកាន់មុខតំណែងប្រធានសាខាពន្ធដារខេត្តកំពង់ធំថ្មី

សូមអានពិស្តារនៅទំព័រទី ៣៩



ឯកឧត្តម **គង់ វិបុល** អញ្ជើញជាអធិបតីក្នុងពិធីប្រកាសចូលកាន់មុខតំណែងប្រធានសាខាពន្ធដារខេត្តព្រៃវែងថ្មី

សូមអានពិស្តារនៅទំព័រទី ៤១



អគ្គនាយកដ្ឋានពន្ធដាររៀបចំកិច្ចប្រជុំក្រុមការងារអគ្គនាយកដ្ឋានពន្ធដារ និងផ្នែកឯកជន ដើម្បីពិនិត្យ ពិភាក្សា និងដោះស្រាយបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងពន្ធដារជូនវិស័យឯកជន

សូមអានពិស្តារនៅទំព័រទី ៤៣



អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រៀបចំកិច្ចប្រជុំពិភាក្សាលើលទ្ធផលសវនកម្មរបស់អគ្គនាយកដ្ឋានពន្ធដារ

សូមអានពិស្ដារនៅទំព័រទី ៤៥



ឯកឧត្តម **គង់ វិបុល** ដឹកនាំកិច្ចប្រជុំពិនិត្យ និងពិភាក្សាលើវឌ្ឍនភាព នៃការដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងពន្ធដារជូនវិស័យឯកជន

សូមអានពិស្ដារនៅទំព័រទី ៤៧

# ឯកឧត្តម គង់ វិបុល ចូលរួមកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា



នាថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៥ នៅវិមានសន្តិភាព ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានចូលរួមជាមួយគណៈប្រតិភូជាន់ខ្ពស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដឹកនាំដោយឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចូលរួមកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនាវេលានោះ បានពិភាក្សា និងឆ្លងលើរបៀបវារៈចំនួន ៤ រួមមាន៖

១. សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦។
២. សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤។
៣. សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើ៖

- កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធនិងការចៀសវាងពន្ធ
- កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋហ្វីលីពីន ស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធនិងការចៀសវាងពន្ធ
- ពិធីសារទី២ ដើម្បីធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃសាធារណរដ្ឋសិង្ហបុរី ស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការកិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល។

៤. សេចក្តីព្រាងរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តវិធានការកែទម្រង់មុតស្រួចជាកញ្ចប់ដែលបានដាក់ចេញក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី១៩ ប្រចាំឆមាសទី១ ឆ្នាំ២០២៥។




សម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា









# ឯកឧត្តម គង់ វិបុល ចូលរួមអមសម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសទទួលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយគណៈប្រតិភូក្រុមប្រឹក្សាធុរកិច្ចសហរដ្ឋអាមេរិក-អាស៊ាន



នាព្រឹកថ្ងៃអង្គារ ទី២ ខែធ្នូ ឆ្នាំ២០២៥ នៅវិមានសន្តិភាព ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានចូលរួមអម **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងឱកាសដែល **សម្តេចមហាបវរធិបតី** អនុញ្ញាតឱ្យគណៈប្រតិភូក្រុមប្រឹក្សាធុរកិច្ចសហរដ្ឋអាមេរិក-អាស៊ាន (US-ASEAN Business Council-USABC) ដឹកនាំដោយឯកអគ្គរដ្ឋទូត Ted Osius អនុប្រធាន និងនាយកគ្រប់គ្រងប្រចាំតំបន់នៃ USABC ជួបសម្តែងការគួរសម និងពិភាក្សាការងារ៕



# សម័យប្រជុំលើកទី៤ នៃព្រឹទ្ធសភាបានឯកភាពទាំងស្រុង លើសេចក្តីព្រាងច្បាប់ពាក់ព័ន្ធនឹងថវិកាជាតិ និងការលុបបំបាត់ការយកពន្ធត្រួតគ្នា




នាព្រឹកថ្ងៃសុក្រ ទី៥ ខែធ្នូ ឆ្នាំ២០២៥ ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា បានបើកសម័យប្រជុំលើកទី៤ ដើម្បីពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ពាក់ព័ន្ធនឹងថវិកាជាតិ និងការលុបបំបាត់ការយកពន្ធត្រួតគ្នា ក្រោមអធិបតីភាព ឯកឧត្តម **អ៊ុច បូររិទ្ធ** ប្រធានស្តីទីព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា នៅវិមានព្រឹទ្ធសភា។ ក្នុងសម័យប្រជុំលើកទី៤នេះ មានការចូលរួមពីប្រតិភូតំណាងរាជរដ្ឋាភិបាល ដឹកនាំដោយ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អមដោយ ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយក-រដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីឆ្លើយបំភ្លឺចំពោះមតិយោបល់របស់សមាជិកព្រឹទ្ធសភា។

**សេចក្តីព្រាងច្បាប់ដែលទទួលបានការឯកភាពទាំងស្រុងពីសម័យប្រជុំលើកទី៤នៃព្រឹទ្ធសភា រួមមាន៖**

១. សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦។

២. សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤។

៣. សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើ៖

- កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធ និងការចៀសវាងពន្ធ
- កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋហ្វីលីពីន ស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធ និងការចៀសវាងពន្ធ
- ពិធីសារទី២ ដើម្បីធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសិង្ហបុរីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការកិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល៕


ព្រឹទ្ធសភា នីតិកាលទី ៥
សម័យប្រជុំលើកទី ៤











# ឯកឧត្តម គង់ វិបុល ចូលរួមអម ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ចូលរួមកិច្ចប្រជុំពិភាក្សារវាងរាជរដ្ឋាភិបាល ជាមួយអន្តរគណៈកម្មការ សភា លើសេចក្តីព្រាងច្បាប់សំខាន់ៗមួយចំនួន



នាព្រឹកថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅវិមានរដ្ឋសភា មានរៀបចំកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងច្បាប់សំខាន់ៗមួយចំនួន រវាងអន្តរគណៈកម្មការរដ្ឋសភា ដឹកនាំដោយ ឯកឧត្តម **ឈាង វុន** ប្រធានគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម (គណៈកម្មការទី២) និងឯកឧត្តម **សួស យ៉ារ៉ា** ប្រធានគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ និងព័ត៌មាន (គណៈកម្មការទី៥) ជាមួយតំណាងរាជរដ្ឋាភិបាល ដឹកនាំដោយ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អមដោយ ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងមានការចូលរួមកិច្ចប្រជុំពិភាក្សាពីលោកជំទាវបណ្ឌិត **សោម គីមសួគ៌** អគ្គសវនករនៃអាជ្ញាធរសវនកម្មជាតិ។

**សេចក្តីព្រាងច្បាប់ដែលត្រូវបានលើកយកមកពិភាក្សារួមមាន៖**

១. សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦។

២. សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤។

៣. សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើ៖

- កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធ និងការចៀសវាងពន្ធ
- កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋហ្វីលីពីន ស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធ និងការចៀសវាងពន្ធ
- ពិធីសារទី២ ដើម្បីធ្វើវិសោធនកម្មលើ កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសិង្ហបុរី ស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការកិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល។

បន្ទាប់ពីកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងច្បាប់ខាងលើ គណៈកម្មការជំនាញនៃរដ្ឋសភា បានសម្រេចឯកភាពជាមួយតំណាងរាជរដ្ឋាភិបាល ដោយគណៈកម្មការជំនាញនឹងធ្វើសេចក្តីរាយការណ៍ជូន **សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា** និងគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ដើម្បីគោរពស្នើសុំដាក់បញ្ចូលសេចក្តីព្រាងច្បាប់ទាំងនេះទៅក្នុងរបៀបវារៈសម័យប្រជុំរដ្ឋសភានាពេលខាងមុខនេះ៕



*ឯកឧត្តម **ឈាង វុន** ប្រធានគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម (គណៈកម្មការទី២)*



*ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*



*លោកជំទាវបណ្ឌិត **សោម គីមសួគ៌** អគ្គសវនករនៃអាជ្ញាធរសវនកម្មជាតិ*



*ឯកឧត្តមបណ្ឌិតសភាចារ្យ **ជូ វិជិត្ត** រដ្ឋលេខាធិការប្រចាំការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*



*ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ*



*ឯកឧត្តម **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា*





# ឯកឧត្តម គង់ វិបុល ចូលរួមអម ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ចូលរួមសិក្ខាសាលាសភាដើម្បីឈ្វេងយល់ពីការកសាងក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់រៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦



នាព្រឹកថ្ងៃចន្ទ ទី១០ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅវិមានរដ្ឋសភា ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានអញ្ជើញចូលរួមសិក្ខាសាលាស្តីពីការឈ្វេងយល់អំពីការកសាងក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្ដីព្រាងច្បាប់ ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ជាម យៀប អនុប្រធានទី១ រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា**។ សិក្ខាសាលានេះ ក៏មានការចូលរួមជាគណៈអធិបតីពីឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឯកឧត្តម **ឈាង ខុន** ប្រធានគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្មនៃរដ្ឋសភា ឯកឧត្តម **យស ផានីត្ថា** ប្រធានគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្មនៃព្រឹទ្ធសភា និងលោកជំទាវបណ្ឌិត **សោម គីមសួគ៌** អគ្គសវនករនៃអាជ្ញាធរសវនកម្មជាតិ ព្រមទាំងមានការចូលរួមពីឯកឧត្តម លោកជំទាវជាសមាជិក-សមាជិការដ្ឋសភា ព្រឹទ្ធសភា និងថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ថវិកាឆ្នាំ២០២៦ ត្រូវបានរាជរដ្ឋាភិបាលប្រសិទ្ធនាមថាជា "**ថវិកាដើម្បីពង្រឹងសមត្ថភាព ការពារអធិបតេយ្យជាតិ និងបូរណភាពទឹកដី ធានាសុខសន្តិភាព រក្សាលំនឹងសង្គម-សេដ្ឋកិច្ច ធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច អភិវឌ្ឍមនុស្សនិងស្ថាប័ន និងលើកកម្ពស់ភាពប្រកួតប្រជែង តាមរយៈការពង្រឹងស័ក្តិសិទ្ធិភាព និងការធានាចីរភាពហិរញ្ញវត្ថុសាធារណៈ សំដៅលើកកម្ពស់សុខដុមភាពសង្គមទ្រទ្រង់កំណើនសេដ្ឋកិច្ចនិងជំរុញការអភិវឌ្ឍឆ្ពោះទៅសម្រេចគោលដៅសំខាន់ៗនៃយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលនីតិកាលទី៧**"។ ជាមួយគ្នានេះ ព្រឹទ្ធសភា និងរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាបានអនុម័តគោលនយោបាយច្បាប់ និងឧបករណ៍គតិយុត្តមួយចំនួនក្នុងស្មារតីជួយជំរុញនិងគាំទ្រដល់ដំណើរការនៃការកសាងក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ។ បន្ថែមពីនេះ សភា

បានយកចិត្តទុកដាក់និងតាមដាននូវវឌ្ឍនភាពនៃការអនុវត្តការកែទម្រង់ដ៏មុតស្រួចជាប់ជាប្រចាំហើយបានមើលឃើញ និងទទួលស្គាល់នូវការខិតខំរបស់រាជរដ្ឋាភិបាលក្នុងការប្រឹងទម្លាក់អត្រានៃភាពក្រីក្រឱ្យស្ថិតនៅក្នុងកម្រិតជាអប្បបរមា តាមរយៈវិធានការបង្រួមវិសមភាពសេដ្ឋកិច្ច ការអភិវឌ្ឍនិងការកសាងប្រព័ន្ធគាំពារសង្គមឱ្យមានលក្ខណៈប្រមូលផ្តុំនិងសង្គតិភាព ការកាត់បន្ថយបន្ទុកជីវភាពប្រជាជន និងការផ្តល់សេវាសាធារណៈប្រកបដោយគុណភាព ប្រសិទ្ធភាព និងបរិយាបន្ន៕


ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជាម យៀប** អនុប្រធានទី១
រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា


ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ







# ឯកឧត្តម គង់ វិបុល ចូលរួមអម ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ដើម្បីការពារសេចក្តីព្រាងច្បាប់មួយចំនួននៅវិមានរដ្ឋសភា



នាព្រឹកថ្ងៃសុក្រ ទី២៨ ខែវិច្ឆិកា ឆ្នាំ២០២៥ រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា បានបើកសម័យប្រជុំលើកទី៥ នីតិកាលទី៧ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី ប្រធានរដ្ឋសភា** នៅវិមានរដ្ឋសភា។ ក្នុងរបៀបវារៈសម័យប្រជុំនាវេលានោះ មានការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ចំនួន ៣ ដែលមានឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តំណាងរាជរដ្ឋាភិបាល ជាអ្នកការពារសេចក្តីព្រាងច្បាប់ អមដោយ ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**សេចក្តីព្រាងច្បាប់ដែលត្រូវបានលើកយកមកពិភាក្សា និងអនុម័តរួមមាន៖**

១. សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦។

២. សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤។

៣. សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើ៖

- កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធ និងការចៀសវាងពន្ធ
- កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋហ្វីលីពីន ស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធ និងការចៀសវាងពន្ធ
- ពិធីសារទី២ ដើម្បីធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃសាធារណរដ្ឋសិង្ហបុរី ស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការកិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល៕


ប្រធាន











# សមាគមសភាពាណិជ្ជកម្មអាមេរិកនៅកម្ពុជា ថ្លែងអំណរគុណ ឯកឧត្តម គង់ វិបុល ចំពោះកិច្ចសហការរៀបចំវេទិកាពន្ធដារ ឆ្នាំ២០២៥ របស់ AmCham ដែលបង្ហាញពីការធានាតម្លាភាព និងភាពច្បាស់លាស់ជូនវិនិយោគិន




នាព្រឹកថ្ងៃសុក្រ ទី១០ ខែតុលា ឆ្នាំ២០២៥ នៅសាលអប្សរា នៃអគារអគ្គនាយកដ្ឋានពន្ធដារ មានរៀបចំវេទិកាពន្ធដារ AmCham Tax Forum 2025 ដែលសហការរៀបចំដោយអគ្គនាយកដ្ឋានពន្ធដារនិងសមាគមសភាពាណិជ្ជកម្មអាមេរិកនៅកម្ពុជា (AMCHAM) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ និងលោក Casey Barnett ប្រធានសភាពាណិជ្ជកម្មអាមេរិកនៅកម្ពុជា។ វេទិកាពន្ធដារប្រចាំឆ្នាំដ៏មានសារៈសំខាន់នេះ ក៏មានការចូលរួមពីឯកឧត្តម លោកជំទាវ លោក-អគ្គនាយករង, ថ្នាក់ដឹកនាំនិងមន្ត្រីជំនាញពាក់ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធដារ, ថ្នាក់ដឹកនាំនៃសមាគមសភាពាណិជ្ជកម្មអាមេរិកនៅកម្ពុជា, អភិបាល និងបណ្ណាធិការ ព្រមទាំងតំណាងសហគ្រាសដែលជាសមាជិកនៃសមាគមសភាពាណិជ្ជកម្មអាមេរិក សរុបប្រមាណ **៥០០ រូប**។ បន្ទាប់ពីលទ្ធផលប្រកបដោយជោគជ័យជាផ្លែផ្កានៃវេទិកាពន្ធដារ AmCham Tax Forum 2025 លោក Casey Barnett ប្រធានក្រុមប្រឹក្សាភិបាលសមាគម បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងមន្ត្រីគ្រប់លំដាប់ថ្នាក់នៃអគ្គនាយកដ្ឋានពន្ធដារ ចំពោះការផ្តល់កិច្ចសហការគាំទ្រដល់សមាគមក្នុងការរៀបចំវេទិកាពន្ធដារនេះ ដែលឆ្លុះបញ្ចាំងពីការយកចិត្តទុកដាក់ និងការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការជួយសម្រួលនិងទាក់ទាញវិនិយោគិន។ ក្នុងលិខិតថ្លែងអំណរគុណចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២៥ របស់សមាគមនេះផងដែរ លោក Casey Barnett បានបញ្ជាក់បន្ថែមថា វេទិកានេះជាឱកាសដ៏ល្អមួយដែលបង្ហាញពីវឌ្ឍនភាព និងការអនុវត្តកំណែទម្រង់ និងនវានុវត្តន៍របស់អគ្គនាយកដ្ឋានពន្ធដារ គិតចាប់ពីប្រសិទ្ធភាពប្រសើរឡើងដែលកើតចេញពីឌីជីថលនីយកម្មនៃដំណើរការអនុវត្តការងាររហូតដល់សេចក្តីណែនាំស្តីពីនីតិវិធីប្រតិបត្តិការស្តង់ដាដែលសម្រួលដល់ការធ្វើសវនកម្ម និងការស៊ើបអង្កេតពន្ធដារ។ បន្ថែមលើសនេះ ការឆ្លើយសំណួរ និងបកស្រាយ

របស់ថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋានពន្ធដារជូនដល់បណ្តាវិនិយោគិន និងតំណាងមកពីបណ្តាក្រុមហ៊ុន សហគ្រាស បានរំលេចពីការចូលរួម និងការប្តេជ្ញាចិត្តរបស់អគ្គនាយដ្ឋានពន្ធដារក្នុងការធានានូវតម្លាភាព និងភាពច្បាស់លាស់។














ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជា
ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ



លោក Casey Barnett
ប្រធានសភាពាណិជ្ជកម្ម អាមេរិកនៅកម្ពុជា















2025
AmCham Tax Forum
Tax Tower
October 10, 2025
ANDERSEN
HEINEKEN
Gold Sponsors:
bakertilly
DFDL
KS AUDIT AND ASSURANCE
Silver Sponsors:
AHF
EALYTEX
DFC
BDO
BLUE


Mr. Laysym Sim
Partner,
Andersen in Cambodia
Mr. Seng Cheaseth
Director, Law, Tax Policy, and
International Tax Cooperation
Department,
GDT
H.E. Bun Neary
Deputy Director General,
GDT
Dr. Eng Ratana
Director,
Large Taxpayer Department,
GDT
Mr. Pov Ratha
Tax Partner,
PwC Cambodia


rnett
ident
AHF
EALYTEX
ACCENT







# ឯកឧត្តម គង់ វិបុល ទទួលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយ ឯកឧត្តម Dominic Williams ឯកអគ្គរាជទូតអង់គ្លេសប្រចាំនៅកម្ពុជា



នារសៀលថ្ងៃចន្ទ ទី២២ ខែធ្នូ ឆ្នាំ២០២៥ នៅអគ្គនាយកដ្ឋានពន្ធដារ ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានទទួលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយ ឯកឧត្តម Dominic Williams ឯកអគ្គរាជទូតអង់គ្លេសប្រចាំនៅកម្ពុជា។ ក្នុងជំនួបនេះ ថ្នាក់ដឹកនាំអគ្គនាយកដ្ឋានពន្ធដារ និងស្ថានទូតអង់គ្លេសប្រចាំនៅកម្ពុជា បានបង្ហាញពីការប្តេជ្ញាចិត្តលើការបន្តកិច្ចសហប្រតិបត្តិការកាន់តែរឹងមាំនិងជិតស្និទ្ធបន្ថែមទៀត ពិសេសលើការគាំទ្រដល់ការបំពេញកាតព្វកិច្ចសារពើពន្ធរបស់វិនិយោគិនអង់គ្លេសដែលមកបណ្តាក់ទុនវិនិយោគនៅកម្ពុជា តាមរយៈការបង្កើតវេទិកាពិភាក្សានានា ការអប់រំបណ្តុះបណ្តាលអ្នកជាប់ពន្ធ និងការបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាអ្នកជាប់ពន្ធ ព្រមទាំងការផ្សព្វផ្សាយមុនដាក់ឱ្យអនុវត្តនូវវិធានការពន្ធដារនានា៕





ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ



ឯកឧត្តម Dominic Williams
ឯកអគ្គរាជទូតអង់គ្លេសប្រចាំនៅកម្ពុជា




ឯកឧត្តម **គង់ វិបុល** ឯកឧត្តម Dominic Williams និងលោកជំទាវ **ប៊ុន នារី**










# ឯកឧត្តម គង់ វិបុល ទទួលជួបសម្ដែងការគួរសម ជាមួយឯកឧត្ដម Vanlalvawna Bawitlung ឯកអគ្គរដ្ឋទូតឥណ្ឌា ប្រចាំព្រះរាជាណាចក្រកម្ពុជា



*ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ និងឯកឧត្តម Vanlalvawna Bawitlung ឯកអគ្គរដ្ឋទូតឥណ្ឌាប្រចាំព្រះរាជាណាចក្រកម្ពុជា*

នាព្រឹកថ្ងៃពុធ ទី១០ ខែធ្នូ ឆ្នាំ២០២៥ នៅអគ្គនាយកដ្ឋានពន្ធដារ ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានទទួលជួប ឯកឧត្តម Vanlalvawna Bawitlung ឯកអគ្គរដ្ឋទូតឥណ្ឌាប្រចាំព្រះរាជាណាចក្រកម្ពុជា ដើម្បីសម្ដែងការគួរសម។ តាមរយៈជំនួបសម្ដែងការគួរសមនេះ បានបង្ហាញនូវកិច្ចសហប្រតិបត្តិការរវាងអគ្គនាយកដ្ឋានពន្ធដារ និងស្ថានទូតឥណ្ឌាប្រចាំនៅកម្ពុជាកាន់តែរឹងមាំនិងជិតស្និទ្ធបន្ថែមទៀត ពិសេសលើការពង្រឹងនិងសម្រួលកិច្ចការធុរកិច្ច ដែលអគ្គនាយកដ្ឋានពន្ធដារនឹងខិតខំដោះស្រាយនូវការលំបាកនិងបញ្ហាប្រឈមនានាក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធរបស់វិនិយោគិនឥណ្ឌា ដែលមកបណ្ដាក់ទុនវិនិយោគនៅកម្ពុជា។ ដើម្បីធ្វើឱ្យកាន់តែប្រសើរឡើងនូវបរិយាកាសនៃការវិនិយោគនៅកម្ពុជា សម្រាប់វិនិយោគិនក្នុងស្រុក និងវិនិយោគិននៃបណ្ដាប្រទេសផ្សេងទៀត អគ្គនាយកដ្ឋានពន្ធដារបានចាត់ទុកការលើកកម្ពស់វប្បធម៌នៃការបង់ពន្ធ ការពង្រឹងអនុលោមភាពសារពើពន្ធ និងការប្រកួតប្រជែងដោយស្មើភាព គឺជាកិច្ចការអាទិភាព ដោយបានបង្កើតវេទិកាពិភាក្សា ជាច្រើនជាប់ជាប្រចាំ ការអប់រំបណ្ដុះបណ្ដាលអ្នកជាប់ពន្ធ និងការបង្កើនប្រសិទ្ធភាពនៃការផ្ដល់សេវាអ្នកជាប់ពន្ធ ព្រមទាំងការផ្សព្វផ្សាយមុនដាក់ឱ្យអនុវត្តនូវវិធានការពន្ធដារនានាជាដើម៕




ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ


ឯកឧត្តម Vanlalvawna Bawitlung ឯកអគ្គរដ្ឋទូតឥណ្ឌាប្រចាំព្រះរាជាណាចក្រកម្ពុជា











# អគ្គនាយកដ្ឋានពន្ធដារ និងសភាពាណិជ្ជកម្មកម្ពុជា រៀបចំកិច្ចប្រជុំពិភាក្សាលើបញ្ហាប្រឈមពាក់ព័ន្ធនឹងពន្ធដារ របស់វិស័យឯកជន



នារសៀលថ្ងៃអង្គារ ទី២ ខែធ្នូ ឆ្នាំ២០២៥ នៅសាលប្រជុំតាព្រហ្មនៃអគ្គនាយកដ្ឋានពន្ធដារ មានកិច្ចប្រជុំពិភាក្សាលើបញ្ហាប្រឈមពាក់ព័ន្ធនឹងពន្ធដាររបស់វិស័យឯកជន ដែលសហការរៀបចំដោយអគ្គនាយកដ្ឋានពន្ធដារ និងសភាពាណិជ្ជកម្មកម្ពុជាក្រោមអធិបតីភាព ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ និងអ្នកឧកញ៉ា **គិត ម៉េង** ប្រធានសភាពាណិជ្ជកម្មកម្ពុជា។ ក្នុងកិច្ចប្រជុំដ៏មានសារៈសំខាន់នេះ តំណាងវិស័យឯកជនបានលើកឡើងនូវបទពិសោធក្នុងការអនុវត្តកាតព្វកិច្ចសារពើពន្ធ នាពេលកន្លងមក ព្រមទាំងបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងពន្ធដារដែលបានជួបប្រទះជូនអង្គប្រជុំដើម្បីពិនិត្យ និងពិភាក្សា។ ជាលទ្ធផល បញ្ហាប្រឈមជាច្រើនត្រូវបានដោះស្រាយប្រកបដោយជំនាញវិជ្ជាជីវៈរបស់ថ្នាក់ដឹកនាំនិងមន្ត្រី ជំនាញនៃអគ្គនាយកដ្ឋានពន្ធដារ ដែលស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ការជួបប្រជុំពិភាក្សា ដើម្បីស្តាប់ និងដោះស្រាយបញ្ហាប្រឈមរបស់វិស័យឯកជន ត្រូវបានរៀបចំជាប់ជាប្រចាំយ៉ាងសកម្ម ពិសេសតាមរយៈយន្តការក្រុមការងារអគ្គនាយកដ្ឋានពន្ធដារ និងផ្នែកឯកជន ដែលជាផ្នែកមួយនៃក្រុមការងារផ្នែកនីតិកម្មពន្ធដារ និងអភិបាលកិច្ច (ក្រុម "ឃ") នៃវេទិកាពរជរដ្ឋាភិបាល-ផ្នែកឯកជន។ បន្ថែមពីលើនេះ អគ្គនាយកដ្ឋានពន្ធដារតែងតែផ្តោតការយកចិត្តទុកដាក់ខ្ពស់លើការគាំទ្រដល់ការបំពេញកាតព្វកិច្ចសារពើពន្ធរបស់អ្នកជាប់ពន្ធ ក្នុងនោះមានវេទិកាពន្ធដារ សិក្ខាសាលា ការបណ្តុះបណ្តាលផ្សេងៗ ព្រមទាំងកិច្ចប្រជុំជាមួយវិស័យឯកជន អង្គការ សមាគម ត្រូវបានរៀបចំឡើងក្នុងគោលដៅផ្តល់ឱកាសដល់អ្នកជាប់ពន្ធលើកឡើងពីបញ្ហាប្រឈមដែលបានជួបប្រទះក្នុងការអនុវត្តកាតព្វកិច្ចសារពើពន្ធ ដែលជាមូលដ្ឋានសម្រាប់អគ្គនាយកដ្ឋានពន្ធដារ ដាក់ចេញនូវវិធានការនានា ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនោះប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា៕



ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជា
ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ



អ្នកឧកញ៉ា **គិត ម៉េង**
ប្រធានសភាពាណិជ្ជកម្មកម្ពុជា









# ដំណើរទស្សនកិច្ចរបស់គណៈប្រតិភូធនាគារជាតិនៃកម្ពុជា មកកាន់អគារទីស្នាក់ការកណ្តាលអគ្គនាយកដ្ឋានពន្ធដារ



*ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ និងលោកជំទាវបណ្ឌិត **ជា សិរី** អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា*

នារសៀលថ្ងៃអង្គារ ទី៣០ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានទទួលស្វាគមន៍គណៈប្រតិភូធនាគារជាតិ នៃកម្ពុជា ដឹកនាំដោយ លោកជំទាវបណ្ឌិត **ជា សិរី** អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ក្នុងដំណើរទស្សនកិច្ចមកកាន់ទីស្នាក់ការកណ្តាលអគ្គនាយកដ្ឋានពន្ធដារ ដើម្បីដកស្រង់បទពិសោធនៃដំណើរការសាងសង់ រៀបចំ និងគ្រប់គ្រងអគារទីស្នាក់ការកណ្តាលរបស់អគ្គនាយកដ្ឋានពន្ធដារ។ ជាទស្សនាទានរួម អគារទីស្នាក់ការកណ្តាលអគ្គនាយកដ្ឋានពន្ធដារ ( GDT TOWER ) នឹងក្លាយជាទីតាំងបណ្តុំនៃសេវាអ្នកជាប់ពន្ធនៅទីតាំងតែមួយ ( One Stop TAX Service )។ អគារនេះមានទីតាំងផ្តល់សេវាអ្នកជាប់ពន្ធប្រកបដោយផាសុកភាព និងប្រណីតភាព ហើយមានបណ្តុំនៃផ្សារទំនើបធនាគារជាដៃគូ ក្នុងការផ្តល់សេវាទទួលនិងបង់ប្រាក់ពន្ធ ក្រុមហ៊ុនសហគ្រាសនានា ដែលផ្តល់សេវាគាំទ្រផ្នែកពន្ធដារ ក្នុងនោះរួមមាន ក្រុមហ៊ុនផ្តល់សេវាផ្នែកគណនេយ្យនិងពិគ្រោះយោបល់ និងភ្នាក់ងារសេវាកម្មពន្ធដារជាដើម៕





ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ



លោកជំទាវបណ្ឌិត **ជា សិរី**
អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា













# ឯកឧត្តម គង់ វិបុល ទទួលស្វាគមន៍ដំណើរទស្សនកិច្ច របស់ប្រតិភូសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជាមកកាន់ទីស្នាក់ការ កណ្តាលអគ្គនាយកដ្ឋានពន្ធដារ



នាព្រឹកថ្ងៃពុធ ទី១៧ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានទទួលស្វាគមន៍ប្រតិភូសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា ដឹកនាំដោយឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** ប្រធានក្រុមប្រឹក្សាភិបាលសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា ក្នុងដំណើរទស្សនកិច្ចមកកាន់ទីស្នាក់ការកណ្តាលអគ្គនាយកដ្ឋានពន្ធដារ។ ដំណើរទស្សនកិច្ចនេះត្រូវបានរៀបចំឡើងស្របតាមសំណូមពររបស់ថ្នាក់ដឹកនាំនិងសមាជិកសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា ដែលមានគោលបំណងធ្វើទស្សនកិច្ចសិក្សាទីស្នាក់ការកណ្តាលអគ្គនាយកដ្ឋានពន្ធដារ និងមានឱកាសទទួលបានការចែករំលែកដោយផ្ទាល់ពី ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី នូវដំណើរការនៃការធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ ព្រមទាំងយុទ្ធសាស្ត្រគ្រប់គ្រងប្រមូលចំណូលពន្ធប្រកបដោយប្រសិទ្ធភាព របស់អគ្គនាយកដ្ឋានពន្ធដារ។ ក្នុងឱកាសនោះ ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី បានចែករំលែកបទពិសោធនៃការធ្វើកំណែទម្រង់ និងការធ្វើបរិវត្តកម្មរដ្ឋបាលសារពើពន្ធ ក្នុងគោលដៅធ្វើទំនើបកម្មអគ្គនាយកដ្ឋានពន្ធដារឱ្យទៅជារដ្ឋបាលសារពើពន្ធឌីជីថល (Tax Digital Transformation) ស្របតាមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងយុទ្ធសាស្ត្រកៀរគរចំណូលនៅគ្រប់ដំណាក់កាល ដែលប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានជាមុខងារគាំទ្រដ៏សំខាន់ក្នុងការគ្រប់គ្រងប្រមូលចំណូលពន្ធឱ្យសម្រេចបានជោគជ័យជាបន្តបន្ទាប់។ គួរបញ្ជាក់ផងដែរថា បច្ចុប្បន្នសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា មានសមាជិកចំនួន ១៤៤ គ្រឹះស្ថានសិក្សា ដោយមានបេសកកម្មរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការអភិវឌ្ឍវិស័យអប់រំ និងបង្កើនធនធានមនុស្សប្រកបដោយគុណភាព និងប្រសិទ្ធភាព៕



ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជា
ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ



ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា**
ប្រធានក្រុមប្រឹក្សាភិបាលសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា











# ឯកឧត្តម គង់ វិបុល អញ្ជើញជាអធិបតីក្នុងពិធីប្រកាសចូលកាន់មុខតំណែងប្រធានទីចាត់ការពន្ធដាររាជធានីភ្នំពេញ និងប្រធានសាខាពន្ធដារខណ្ឌ៧មករា




នារសៀលថ្ងៃពុធ ទី៨ ខែតុលា ឆ្នាំ២០២៥ នៅអគ្គនាយកដ្ឋានពន្ធដារ មានរៀបចំពិធីប្រកាសចូលកាន់មុខតំណែងប្រធានទីចាត់ការពន្ធដាររាជធានីភ្នំពេញ និងប្រធានសាខាពន្ធដារខណ្ឌ៧មករា ក្រោមអធិបតីភាព ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ឯកឧត្តម **ម៉ប់ សារិន** ប្រធានក្រុមប្រឹក្សារាជធានីភ្នំពេញ និងឯកឧត្តម **ឃួង ស្រេង** អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ។ ពិធីប្រកាសចូលកាន់មុខតំណែងនាពេលនោះ លោក **សិញ សេងហោ** ត្រូវបានទទួលមុខតំណែងថ្មីជាប្រធានទីចាត់ការពន្ធដាររាជធានីភ្នំពេញ ជំនួសលោក **ហ៊ាន ត្រេង** ដែលបានចូលនិវត្តន៍ ខណៈ លោក **ស៊ុន ឧុទ្ធី** ត្រូវបានចូលកាន់មុខតំណែងជាប្រធានសាខាពន្ធដារខណ្ឌ៧មករា ជំនួសលោក **សិញ សេងហោ**៕







ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ



ឯកឧត្តម **ឃួង ស្រេង**
អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ

























# អគ្គនាយកដ្ឋានពន្ធដារ និងរដ្ឋបាលខេត្តកំពង់ធំរៀបចំពិធីប្រកាសចូលកាន់មុខតំណែង ប្រធានសាខាពន្ធដារខេត្តកំពង់ធំថ្មី




*ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ និងលោក **ប៉ូ ពិសិដ្ឋ** ប្រធានសាខាពន្ធដារខេត្តកំពង់ធំ*

នាព្រឹកថ្ងៃអង្គារ ទី៧ ខែតុលា ឆ្នាំ២០២៥ នៅសាលប្រជុំសាខាពន្ធដារខេត្តកំពង់ធំ មានរៀបចំពិធីប្រកាសចូលកាន់មុខតំណែងប្រធានសាខាពន្ធដារខេត្តកំពង់ធំថ្មី ក្រោមអធិបតីភាព ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ និងមានការចូលរួមពីឯកឧត្តម **ងួន ផារ័ត្ន** អភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ។ ក្នុងពិធីនេះ លោក **ប៉ូ ពិសិដ្ឋ** ត្រូវបានប្រកាសចូលកាន់មុខតំណែងជាប្រធានសាខាពន្ធដារខេត្តកំពង់ធំ ជំនួសលោក **ខឹម សុវណ្ណា** ដែលបានទទួលមរណភាព។ ឯកឧត្តម **គង់ វិបុល** បានផ្តាំផ្ញើឱ្យប្រធានសាខាពន្ធដារខេត្តកំពង់ធំថ្មី បន្តពង្រឹងការគ្រប់គ្រងប្រមូលចំណូលពន្ធបង់ចូលថវិកាជាតិឱ្យបានល្អស្របតាមផែនការដែលបានកំណត់ ព្រមទាំងត្រងត្រាប់តាមនូវអភិក្រមការងាររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានពន្ធដារ។ បន្ថែមពីនេះ **ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី** បានណែនាំឱ្យសាខាពន្ធដារខេត្តកំពង់ធំ បន្តចុះផ្សព្វផ្សាយនិងបញ្ជ្រាបការយល់ដឹងពីកាតព្វកិច្ចសារពើពន្ធឱ្យកាន់តែទូលំទូលាយដល់ប្រជាពលរដ្ឋ បន្តកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយអង្គភាពពាក់ព័ន្ធ ព្រមទាំងអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ឱ្យបានកាន់តែល្អប្រសើរថែមទៀតផងដែរ៕







ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ



ឯកឧត្តម **នួន ផារ័ត្ន**
អភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ










# ឯកឧត្តម គង់ វិបុល អញ្ជើញជាអធិបតីក្នុងពិធីប្រកាសចូលកាន់មុខតំណែងប្រធានសាខាពន្ធដារខេត្តព្រៃវែងថ្មី




*ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ និងលោក **ហ៊ូ ហោមរិទ្ធ** ប្រធានសាខាពន្ធដារខេត្តព្រៃវែង*

នាព្រឹកថ្ងៃអង្គារ ទី៩ ខែធ្នូ ឆ្នាំ២០២៥ នៅសាខាពន្ធដារខេត្តព្រៃវែង មានរៀបចំពិធីប្រកាសចូលកាន់មុខតំណែងប្រធានសាខាពន្ធដារខេត្តព្រៃវែងថ្មី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ និងមានការចូលរួមពីឯកឧត្តម **សួន សុម៉ាលីន** អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង។ ក្នុងពិធីនោះ លោក **ហ៊ូ ហោមរិទ្ធ** ត្រូវបានប្រកាសចូលកាន់មុខតំណែងជាប្រធានសាខាពន្ធដារខេត្តព្រៃវែង ជំនួសលោក **ហ៊ឹម ឡេញ** ដែលបានចូលនិវត្តន៍។ ឯកឧត្តម **គង់ វិបុល** បានផ្តាំផ្ញើឱ្យប្រធានសាខាពន្ធដារខេត្តព្រៃវែងថ្មី បន្តពង្រឹងការគ្រប់គ្រងប្រមូលចំណូលពន្ធបង់ចូលថវិកាជាតិឱ្យបានល្អស្របតាមផែនការដែលបានកំណត់ ព្រមទាំងអនុវត្តតាមអភិក្រមការងាររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានពន្ធដារ។ បន្ថែមពីនេះ **ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី** បានណែនាំឱ្យសាខាពន្ធដារខេត្តព្រៃវែង បន្តចុះផ្សព្វផ្សាយនិងបញ្ជ្រាបការយល់ដឹងពីកាតព្វកិច្ចសារពើពន្ធឱ្យកាន់តែទូលំទូលាយដល់ប្រជាពលរដ្ឋ បន្តកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយអង្គភាពពាក់ព័ន្ធ ព្រមទាំងអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ឱ្យបានកាន់តែល្អប្រសើរថែមទៀតផងដែរ៕





ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជា
ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ



ឯកឧត្តម **សួន សុម៉ាលីន**
អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង









# អគ្គនាយកដ្ឋានពន្ធដាររៀបចំកិច្ចប្រជុំក្រុមការងារ អគ្គនាយកដ្ឋានពន្ធដារ និងផ្នែកឯកជន ដើម្បីពិនិត្យ ពិភាក្សា និង ដោះស្រាយបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងពន្ធដារជូនវិស័យឯកជន



នារសៀលថ្ងៃទី២២ ខែតុលា ឆ្នាំ២០២៥ នៅសាលប្រជុំតាព្រហ្ម នៃអគ្គនាយកដ្ឋានពន្ធដារ មានរៀបចំកិច្ចប្រជុំពិនិត្យ ពិភាក្សា និងដោះស្រាយបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងពន្ធដារជូនវិស័យឯកជន ក្រោមអធិបតីភាព ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ និងជាសហប្រធានក្រុមការងារអគ្គនាយកដ្ឋានពន្ធដារ និងផ្នែកឯកជន និង ឧកញ៉ា **លឹម សុជាតិ** សហប្រធានក្រុមការងារអគ្គនាយកដ្ឋានពន្ធដារ និងផ្នែកឯកជន ដោយមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីរាជការពាក់ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធដារ និងតំណាងវិស័យឯកជន។ គួរបញ្ជាក់ផងដែរថា ក្រុមការងារអគ្គនាយកដ្ឋានពន្ធដារ និងផ្នែកឯកជន គឺជាផ្នែកមួយនៃក្រុមការងារផ្នែកនីតិកម្ម ពន្ធដារ និងអភិបាលកិច្ច (ក្រុម "ឃ") នៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន។ កន្លងមក អគ្គនាយកដ្ឋានពន្ធដារបានរៀបចំកិច្ចប្រជុំក្រុមការងារអគ្គនាយកដ្ឋានពន្ធដារ និងផ្នែកឯកជន ហើយគ្រោងនឹងរៀបចំកិច្ចប្រជុំនេះនាពេលខាងមុខជាបន្តបន្ទាប់ ក្នុងគោលដៅដាក់ចេញនូវវិធានការដោះស្រាយសមស្រប និងទាន់ពេលវេលាជូនវិស័យឯកជនដែលកំពុងធ្វើធុរកិច្ចនៅប្រទេសកម្ពុជា ឆ្លើយតបនឹងសំណូមពរនិងបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងពន្ធដារ៕





ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ



ឧកញ៉ា **លឹម សុជាតិ** សហប្រធានក្រុមការងារអគ្គនាយកដ្ឋានពន្ធដារនិងផ្នែកឯកជន









# អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រៀបចំកិច្ចប្រជុំពិភាក្សាលើលទ្ធផលសវនកម្មរបស់អគ្គនាយកដ្ឋានពន្ធដារ



នារសៀលថ្ងៃចន្ទ ទី២៤ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅអគ្គនាយកដ្ឋានពន្ធដារ មានរៀបចំកិច្ចប្រជុំពិភាក្សាលើលទ្ធផលសវនកម្មរបស់អគ្គនាយកដ្ឋានពន្ធដារ ក្រោមអធិបតីភាព ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ និងលោកជំទាវ **ខៅ ម៉ូវីឡែន** អគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងមានការចូលរួមពីថ្នាក់ដឹកនាំ មន្ត្រីជំនាញពាក់ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធដារ និងគណៈប្រតិភូនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង។ កិច្ចប្រជុំបានពិនិត្យពិភាក្សាលើលទ្ធផលសវនកម្មឆ្នាំ២០២៤ ដែលរួមមាន ការអនុវត្តអនុសាសន៍សវនកម្មគ្រាមុន (ឆ្នាំ២០២៣) និងការកត់សម្គាល់ថ្មីឆ្នាំ២០២៤។ ជាលទ្ធផល អង្គប្រជុំបានសម្រេចរក្សាទុកអនុសាសន៍សវនកម្មគ្រាមុន និងការកត់សម្គាល់លទ្ធផលសវនកម្មថ្មីមួយចំនួន សម្រាប់អគ្គនាយកដ្ឋានពន្ធដារអនុវត្តការកែលម្អដើម្បីបង្កើនប្រសិទ្ធភាពការងារឱ្យកាន់តែល្អប្រសើរថែមទៀត៕





ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ



លោកជំទាវ **ង៉ែត ម៉ូរីឡែន** អគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ









# ឯកឧត្តម គង់ វិបុល ដឹកនាំកិច្ចប្រជុំពិនិត្យ និងពិភាក្សាលើវឌ្ឍនភាព នៃការដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងពន្ធដារជូនវិស័យឯកជន



នារសៀលថ្ងៃព្រហស្បតិ៍ ទី២៧ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅសាលប្រជុំតាព្រហ្មនៃអគ្គនាយកដ្ឋានពន្ធដារ ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានដឹកនាំកិច្ចប្រជុំពិនិត្យ និងពិភាក្សាលើវឌ្ឍនភាពនៃការដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងពន្ធដារជូនវិស័យឯកជន ដែលមានការចូលរួមពីថ្នាក់ដឹកនាំនិងមន្ត្រីជំនាញពាក់ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធដារ។ អគ្គនាយកដ្ឋានពន្ធដារតែងតែផ្តោតលើការយកចិត្តទុកដាក់ខ្ពស់ចំពោះការជួយដោះស្រាយបញ្ហាប្រឈមនានារបស់វិស័យឯកជន ដើម្បីជំរុញអនុលោមភាពសារពើពន្ធដោយស្ម័គ្រចិត្ត តាមរយៈការគាំទ្រឱ្យវិស័យឯកជនបំពេញកាតព្វកិច្ចសារពើពន្ធបានត្រឹមត្រូវស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ កិច្ចប្រជុំនាវេលានោះ បានពិនិត្យ និងពិភាក្សាលើវឌ្ឍនភាពនៃការដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងពន្ធដារជូនវិស័យឯកជន ដើម្បីដាក់ចេញវិធានការដោះស្រាយសមស្របនិងទាន់ពេលវេលាជូនវិស័យឯកជនដែលកំពុងធ្វើធុរកិច្ចនៅប្រទេសកម្ពុជាប្រកបដោយប្រសិទ្ធភាព៕





ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជា
ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ



លោកជំទាវ **ប៊ិន នារី** អគ្គនាយករង
នៃអគ្គនាយកដ្ឋានពន្ធដារ











# ផ្នែកទី១

## ស្ថានភាពនៃការគ្រប់គ្រងការប្រមូលចំណូលពន្ធ

១. លទ្ធផលនៃចំណូលពន្ធ

២. ស្ថានភាពចំណូលពន្ធតាមប្រភេទអ្នកជាប់ពន្ធ

៣. ស្ថានភាពចំណូលពន្ធតាមប្រភេទពន្ធសំខាន់ៗ

៤. ស្ថានភាពចំណូលពន្ធតាមសកម្មភាពអាជីវកម្មសំខាន់ៗ

# ๒

# ១. លទ្ធផលនៃចំណូលពន្ធ

សរុបរយៈពេល ១២ខែ ឆ្នាំ២០២៥ ចំណូលពន្ធអាករ ដែលប្រមូលបានជាក់ស្តែង តាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារ មានចំនួន **១៤ ៣៤៥,៥៧ ប៊ីលានរៀល** (ប្រមាណជា **៣ ៥៧៧,៤៥ លានដុល្លារ**) ស្មើនឹង **១០០,២៣%** នៃផែនការច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ២០២៥។

**ចំណូលពន្ធអាករគ្រប់ប្រភេទ រយៈពេល ១២ខែ ឆ្នាំ២០២៥**




| | រយៈពេល ៩ខែ | ខែតុលា | ខែវិច្ឆិកា | ខែធ្នូ | សរុបរួម |
|---|---|---|---|---|---|
| ឆ្នាំ២០២៥ | ១១ ០៣០,៣៣ | ១ ១៥៧,០៩ | ១ ១៨០,៣០ | ៩៧៦,៥៧ | ១៤ ៣៤៥,៥៧ |

# ២. ស្ថានភាពចំណូលពន្ធតាមប្រភេទអ្នកជាប់ពន្ធ

**ចំណូលពន្ធអាករតាមប្រភេទអ្នកជាប់ពន្ធ រយៈពេល ១២ខែ ឆ្នាំ២០២៥**



សរុបរយៈពេល ១២ខែ ឆ្នាំ២០២៥ ចំណូលពន្ធអាករតាមប្រភេទអ្នកជាប់ពន្ធ ដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបានក្នុងនោះរួមមាន៖

- ចំណូលពន្ធអាករពីអ្នកជាប់ពន្ធធំចំនួន **១០ ៥៥៥,១៦ ប៊ីលានរៀល** ស្មើនឹង **៧៣,៥៨%** ធៀបនឹងចំណូលពន្ធអាករសរុប
- ចំណូលពន្ធអាករពីអ្នកជាប់ពន្ធមធ្យមចំនួន **២ ៤៥៥,៦០ ប៊ីលានរៀល** ស្មើនឹង **១៧,១២%** ធៀបនឹងចំណូលពន្ធអាករសរុប
- ចំណូលពន្ធអាករពីអ្នកជាប់ពន្ធតូចចំនួន **១០៣,២៥ ប៊ីលានរៀល** ស្មើនឹង **០,៧២%** ធៀបនឹងចំណូលពន្ធអាករសរុប
- ចំណូលពន្ធអាករពីប្រភេទពន្ធផ្សេងៗ (ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ ពន្ធលើអចលនទ្រព្យ និងពន្ធផ្សេងៗ) ចំនួន **១ ២៣១,៥៦ ប៊ីលានរៀល** ស្មើនឹង **៨,៥៨%** ធៀបនឹងចំណូលពន្ធអាករសរុប។

## ៣. ស្ថានភាពចំណូលពន្ធអាករតាមប្រភេទពន្ធសំខាន់ៗ

**ក្រាហ្វភាគរយចំណូលពន្ធអាករតាមប្រភេទពន្ធសំខាន់ៗ**
**ធៀបនឹងចំណូលពន្ធសរុបប្រមូលបាន ក្នុងរយៈពេល ១២ខែ ឆ្នាំ២០២៥**




សរុបរយៈពេល ១២ខែ ឆ្នាំ២០២៥ អគ្គនាយកដ្ឋានពន្ធដារប្រមូលចំណូលពន្ធអាករតាមប្រភេទពន្ធសំខាន់ៗរួមមាន៖

- ពន្ធលើប្រាក់ចំណូលចំនួន **៤ ០២៥,៩៣ ប៊ីលានរៀល** ស្មើនឹង **២៨,០៦%**
- អាករលើតម្លៃបន្ថែមចំនួន **៣ ៧០៥,១០ ប៊ីលានរៀល** ស្មើនឹង **២៥,៨៣%**
- អាករពិសេសចំនួន **៧២៥,២១ ប៊ីលានរៀល** ស្មើនឹង **៥,០៦%**
- ពន្ធលើប្រាក់បៀវត្សចំនួន **១ ៤៨៩,៨២ ប៊ីលានរៀល** ស្មើនឹង **១០,៣៩%**
- ពន្ធប្រថាប់ត្រាសរុប (ផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យ) ចំនួន **៦៥៥,៦១ ប៊ីលានរៀល** ស្មើនឹង **៤,៥៧%**
- ពន្ធកាត់ទុកទូទៅ (សេវាកម្ម ការប្រាក់ សួយសារ ថ្លៃឈ្នួល និងភាគលាភ) ចំនួន **២ ៨០៥,៨៦ ប៊ីលានរៀល** ស្មើនឹង **១៩,៥៦%**
- ផ្សេងៗចំនួន **៩៣៧,៨១ ប៊ីលានរៀល** ស្មើនឹង **៦,៥៤%**។

# ៤. ស្ថានភាពចំណូលពន្ធតាមសកម្មភាពអាជីវកម្មសំខាន់ៗ

សរុបរយៈពេល ១២ខែ ឆ្នាំ២០២៥ ចំណូលពន្ធពីសកម្មភាពកម្មន្តសាល សកម្មភាពសេវាហិរញ្ញវត្ថុនិងធានារ៉ាប់រង និង អាហារ័ណ-នីហារ័ណ គឺជាចំណូលពន្ធចម្បង និងលេចធ្លោជាងគេ។ តារាងចំណូលពន្ធអាករ តាមសកម្មភាពអាជីវកម្មសំខាន់ៗ ដែលអគ្គនាយកដ្ឋានពន្ធដារ ប្រមូលបានជាក់ស្តែង ក្នុង រយៈពេល ១២ខែឆ្នាំ២០២៥ មានបង្ហាញដូចខាងក្រោម៖

**តារាងចំណូលពន្ធអាករតាមសកម្មភាពអាជីវកម្មសំខាន់ៗ រយៈពេល ១២ខែ ឆ្នាំ២០២៥**

(តាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញ Online របស់អគ្គនាយកដ្ឋានពន្ធដារ)

| បរិយាយ | រយៈពេល៩ខែ | ខែតុលា | ខែវិច្ឆិកា | ខែធ្នូ | សរុបរួម |
|---|---|---|---|---|---|
| កម្មន្តសាល | ២ ២៥៣,០៧ | ២១៥,៧៧ | ២១៧,១៥ | ២២៨,០០ | ២ ៩១៣,៧០ |
| សេវាហិរញ្ញវត្ថុ និងធានារ៉ាប់រង | ២ ១៦២,៩០ | ១៣៩,០០ | ១៣៩,០១ | ១៤១,០០ | ២ ៥៨២,៧៣ |
| ផ្សេងៗ | ១ ៨៩៣,៩៦ | ២៦៧,០៤ | ៣៩១,២៧ | ១៧៨,៤៤ | ២ ៧៣០,៤០ |
| អាហារ័ណ-នីហារ័ណ (សរុបរួម) | ១ ៧៤៣,១៣ | ១៦៦,០០ | ១៦៨,០៦ | ១៦៤,៨០ | ២ ២៤០,៨៤ |
| ការដឹកជញ្ជូន និងការស្តុកទុក | ៦៤១,២២ | ៧២,៦០ | ៦៦,២៤ | ៦៩,៦០ | ៨៤៩,៧១ |
| ទូរគមនាគមន៍ | ៦២២,៧៥ | ១១៤,៥៦ | ៤៧,៤២ | ៤១,៣៤ | ៨២៦,០១ |
| ការសាងសង់ | ៥៦៤,៨៩ | ៦២,៦០ | ៤៤,៧៣ | ៤៨,៨០ | ៧២១,០០ |
| សកម្មភាពអចលនវត្ថុ | ៤៥៦,៣៩ | ៥០,៣០ | ៤៥,៥៨ | ៣៧,៩០ | ៥៩០,៣៨ |
| សេវាកម្មស្នាក់នៅ និងអាហារ | ២៩៧,១៣ | ៣៨,១០ | ៣៧,៥៣ | ៤៥,៨០ | ៤១៨,៩៩ |
| ប្រតិបត្តិការ និងអាជីវកម្មធនធានរ៉ែ | ២១២,៤៥ | ៥,៩៩ | ៦,០៦ | ៦,៨៤ | ២៣១,៣៤ |
| កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១០៤,៦៣ | ១៤,២០ | ៧,៧៩ | ៦,៣០ | ១៣២,៩៤ |
| ការអប់រំ | ៧៧,៨១ | ១១,៧០ | ៩,៤៨ | ៨,៣៩ | ១០៧,៥៤ |

* កំណត់សម្គាល់ ៖ ចំណូលឯកតាគិតជាប៊ីលានរៀល។

# ផ្នែកទី២

## វឌ្ឍនភាពការងារនៃមុខងារប្រតិបត្តិការស្នូល និងមុខងារគាំទ្រ

១. ការចុះបញ្ជីពន្ធដារ

២. ការផ្ដល់សេវាអ្នកជាប់ពន្ធ

៣. ការចាត់ចែងលិខិតប្រកាសពន្ធ

៤. ការធ្វើសវនកម្មពន្ធដារ

៥. ការប្រមូលបំណុលពន្ធ និងបណ្ដឹងតវ៉ា

៦. បច្ចេកវិទ្យាព័ត៌មាន

# ១.ការចុះបញ្ជីពន្ធដារ

សរុបរយៈពេល ១២ខែ ឆ្នាំ២០២៥ អគ្គនាយកដ្ឋានពន្ធដារបានអនុញ្ញាតឱ្យចុះបញ្ជីសរុបចំនួន **១១ ៧៦០ សហគ្រាស** (**ពន្ធធំ ១ ០៦៣ ពន្ធមធ្យម ៥ ៦១៥ ពន្ធតូច ៥ ០៨២**) ក្នុងនោះតាមថ្នាលប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានចំនួន **១១ ៣២៤ សហគ្រាស** (**ពន្ធធំ ១ ០២៨ ពន្ធមធ្យម ៥ ៣៩៦ ពន្ធតូច ៤ ៩០០**)។ ដោយឡែក ក្នុងរយៈពេល ១២ខែ ឆ្នាំ២០២៥ ចំពោះប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មានសហគ្រាសអនិវាសនជនចុះបញ្ជីអាករលើតម្លៃបន្ថែមសាមញ្ញ ចំនួន **៦ សហគ្រាស** (គិតចាប់ពីឆ្នាំ២០២២ ដល់ខែធ្នូ ឆ្នាំ២០២៥ មានសហគ្រាសចុះបញ្ជីសរុបចំនួន **១០២**)។

# ២.ការផ្តល់សេវាអ្នកជាប់ពន្ធ

## ការផ្តល់សេវាពិគ្រោះយោបល់

សរុបរយៈពេល ១២ខែ ឆ្នាំ២០២៥ អគ្គនាយកដ្ឋានពន្ធដារបានផ្តល់សេវាអ្នកជាប់ពន្ធសរុបចំនួន **១០១ ៨៥៩ ករណី** បើធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០២៤ ឃើញថាកើនឡើងចំនួន **២ ៧៩៨ ករណី** ស្មើនឹង **២,៨២%** ក្នុងនោះការផ្តល់សេវាតាមទូរស័ព្ទកើនឡើង **១ ៥៣៣ ករណី** ស្មើនឹង **២,៤០%** និង GDT Live Chat កើនឡើង **១ ០៤៩ ករណី** ស្មើនឹង **៣,៦០%**។

**ការផ្តល់សេវាពិគ្រោះយោបល់ រយៈពេល ១២ខែ ឆ្នាំ២០២៤និងឆ្នាំ២០២៥**

| បរិយាយ | ១២ខែ ឆ្នាំ២០២៤ | ១២ខែ ឆ្នាំ២០២៥ | ភាគរយកើន/ថយ |
|---|---|---|---|
| ទូរស័ព្ទ (១២៧៧) | ៦៣ ៩៨៦ | ៦៥ ៥១៩ | ២,៤០% |
| GDT Live Chat | ២៩ ១១៩ | ៣០ ១៦៨ | ៣,៦០% |
| បណ្តាញសង្គម Facebook | ៤ ១៣៩ | ៤ ៣២៣ | ៤,៤៥% |
| កម្មវិធី "ពន្ធដារកម្ពុជា" | ៤៤ | ៤៣ | -២,២៧% |
| កម្មវិធី "រៀនអំពីពន្ធដារតាមអនឡាញ" | ៣៩ | ៤៩ | ២៥,៦៤% |
| តេឡេក្រាម "ព័ត៌មានពន្ធដារកម្ពុជា" | ១ ២៩១ | ១ ៣៣៤ | ៣,៣៣% |
| គេហទំព័រអគ្គនាយកដ្ឋានពន្ធដារ | ៤៤៣ | ៤២៣ | -៤,៥០% |
| **សរុបរួម** | ៩៩ ០៦១ | ១០១ ៨៥៩ | ២,៨២% |

* កំណត់សម្គាល់ ៖ ឯកតាគិតជាចំនួនករណី។

## ការផ្តល់សេវាអ្នកជាប់ពន្ធចំពោះ "ការគាំទ្រប្រព័ន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ (e-Tax Service)"

ក្នុងរយៈពេល ១២ខែ ឆ្នាំ២០២៥ អគ្គនាយកដ្ឋានពន្ធដារបានផ្តល់សេវាដោះស្រាយបញ្ហាប្រឈមនានា ក្នុងការប្រើប្រាស់ប្រព័ន្ធនិងកម្មវិធីតាមរយៈអនឡាញ (e-Tax Service) សរុបចំនួន **៤៤ ០៩០ ករណី** ដែលក្នុងនោះការស្នើសុំ តាមរយៈ GDT Live Chat ចំនួន **១៥ ៨៥១ ករណី**, សារអេឡិចត្រូនិក (E-Mail) ចំនួន **៧១៣ ករណី** , ទូរស័ព្ទ (១២៧៧) ចំនួន **១៦ ២៦០ ករណី** និងក្រុមតេឡេក្រាម (Telegram) ចំនួន **១១ ២៦៦ ករណី**។

## កម្មវិធីពន្ធដារកម្ពុជា

កម្មវិធីពន្ធដារកម្ពុជា គឺជាកម្មវិធីដែលអគ្គនាយកដ្ឋានពន្ធដារបានរៀបចំឡើងដើម្បីចែករំលែកចំណេះដឹង ព័ត៌មានទាក់ទងនឹងពន្ធដារ ជាពិសេសផ្តល់ឱកាសឱ្យសាធារណជនចូលរួមមតិយោបល់ ឬលើកឡើងនូវចម្ងល់នានាពាក់ព័ន្ធនឹងប្រធានបទនីមួយៗ ដែលធ្វើការផ្សាយផ្ទាល់តាមរយៈទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ រៀងរាល់ថ្ងៃព្រហស្បតិ៍ វេលាម៉ោង ១១:០០ ដល់ម៉ោង ១២:០០ថ្ងៃត្រង់។ កម្មវិធីនេះ ទទួលបានការគាំទ្រយ៉ាងខ្លាំងពីសំណាក់អ្នកជាប់ពន្ធ និងសាធារណជន ដែលទស្សនិកជនអាចផ្តល់មតិយោបល់ ឬសួរសំណួរតាមរយៈទូរស័ព្ទមកលេខ ១២៧៧ ដោយឥតគិតថ្លៃ ឬអាចចូលទៅផ្តល់មតិយោបល់ (Comment) នៅលើទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារភ្លាមៗក្នុងពេលផ្សាយផ្ទាល់ នោះវាគ្មិននឹងធ្វើការឆ្លើយតបផ្ទាល់ក្នុងកម្មវិធីតែម្តង។ ក្នុងករណីខកខានមិនបានទស្សនាការផ្សាយផ្ទាល់ ទស្សនិកជនក៏អាចទស្សនាឡើងវិញ ព្រមទាំងអាចសួរសំណួរតាមរយៈ Comment ក្នុងវីដេអូនោះ ក្រុមការងារ GDT Call Center របស់អគ្គនាយកដ្ឋានពន្ធដារ នឹងធ្វើការឆ្លើយតបជូនតាមលំដាប់លំដោយ។ ក្រៅពីការចូលទៅទស្សនាឡើងវិញនៅលើទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ ទស្សនិកជនក៏អាចចូលទៅទស្សនាក្នុងបណ្តាញយូធូប (YouTube) "General Department of Taxation, Cambodia" របស់អគ្គនាយកដ្ឋានពន្ធដារផងដែរ។

ក្នុងត្រីមាសទី៤ ឆ្នាំ២០២៥ អគ្គនាយកដ្ឋានពន្ធដារ បានរៀបចំកម្មវិធីពន្ធដារកម្ពុជាសរុបចំនួន **៩ លើក** ដោយផ្តោតលើប្រធានបទសំខាន់ៗរួមមាន ១.ពន្ធកាត់ទុកទូទៅ ២.ពន្ធលើមធ្យោបាយដឹកជញ្ជូន ៣.កម្មវិធីទូរស័ព្ទរបស់អគ្គនាយកដ្ឋានពន្ធដារ ៤.កាតព្វកិច្ចសារពើពន្ធក្នុងអំឡុងពេលផ្អាកសកម្មភាពអាជីវកម្ម ៥.ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ៦.សៀវភៅណែនាំស្តីពីបែបបទនិងនីតិវិធីនៃការធ្វើសវនកម្មពន្ធដារសម្រាប់មន្ត្រីពន្ធដារ និងអ្នកជាប់ពន្ធ ៧.កាតព្វកិច្ចសារពើពន្ធរបស់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ៨.ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យនិង ៩.ការស្នើសុំលិខិតបញ្ជាក់ស្ថានភាពសារពើពន្ធនិងលិខិតអនុញ្ញាតឱ្យបង់ពន្ធជាដំណាក់កាល។



## កម្មវិធីពន្ធដារកម្ពុជាស្ដីពី "ពន្ធកាត់ទុកទូទៅ"

កម្មវិធីនេះមានលោក **សុខ កុសល** អនុប្រធាននាយកដ្ឋាន និងលោកស្រី **ខួន ម៉ាឌីណា** អនុប្រធានការិយាល័យ នៃនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ នៃអគ្គនាយកដ្ឋានពន្ធដារ ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី២ ខែតុលា ឆ្នាំ២០២៥ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជនផងដែរ។ បើគិតមកដល់ដំណាច់ត្រីមាសទី៤ ឆ្នាំ២០២៥ តាមស្ថិតិនៅលើបណ្ដាញយូធូបមានអ្នកចូលទស្សនាចំនួន ១ ៤៥០ ដង។




សូមស្កេនដើម្បីចូលទៅទស្សនាវីដេអូដើម

## កម្មវិធីពន្ធដារកម្ពុជាស្ដីពី "ពន្ធលើមធ្យោបាយដឹកជញ្ជូន"

កម្មវិធីនេះមានលោក **យិន សុធាវី** ប្រធានការិយាល័យ និងលោក **ជួប ចាន់ដារ៉ា** អនុប្រធានការិយាល័យ នៃនាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ នៃអគ្គនាយកដ្ឋានពន្ធដារ ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៥ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជនផងដែរ។ បើគិតមកដល់ដំណាច់ត្រីមាសទី៤ ឆ្នាំ២០២៥ តាមស្ថិតិនៅលើបណ្ដាញយូធូបមានអ្នកចូលទស្សនាចំនួន ២៨០ ដង។




សូមស្កេនដើម្បីចូលទៅទស្សនាវីដេអូដើម

## កម្មវិធីពន្ធដារកម្ពុជាស្ដីពី "កម្មវិធីទូរស័ព្ទរបស់អគ្គនាយកដ្ឋានពន្ធដារ"

កម្មវិធីនេះមានលោក **ស្សូត្រ សារេត** អនុប្រធាននាយកដ្ឋាន និងលោក **ស្រេង រតនា** ប្រធានការិយាល័យនៃនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន នៃអគ្គនាយកដ្ឋានពន្ធដារ ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៥ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជនផងដែរ។ បើគិតមកដល់ដំណាច់ត្រីមាសទី៤ ឆ្នាំ២០២៥ តាមស្ថិតិនៅលើបណ្ដាញយូធូបមានអ្នកចូលទស្សនាចំនួន ១៨០ ដង។




សូមស្កេនដើម្បីចូលទៅទស្សនាវីដេអូដើម

## កម្មវិធីពន្ធដារកម្ពុជាស្តីពី "ភាតព្វកិច្ចសារពើពន្ធក្នុងអំឡុងពេលផ្អាកសកម្មភាពអាជីវកម្ម"

កម្មវិធីនេះមានលោក **គុល ម៉ារ៉ាដុល្លា** ប្រធានការិយាល័យ នៃនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ និងលោក **ថៃ ពេជ្រ** ប្រធានការិយាល័យ នៃនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូច និងមធ្យម នៃអគ្គនាយកដ្ឋានពន្ធដារ ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី២៣ ខែតុលាឆ្នាំ២០២៥ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជនផងដែរ។ បើគិតមកដល់ដំណាច់ត្រីមាសទី៤ ឆ្នាំ២០២៥ តាមស្ថិតិនៅលើបណ្តាញយូធូបមានអ្នកចូលទស្សនាចំនួន ១៩១ ដង។




សូមស្កេនដើម្បីចូលទៅទស្សនាវីដេអូដើម

## កម្មវិធីពន្ធដារកម្ពុជាស្តីពី "ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ"

កម្មវិធីនេះមានលោក **ហេង សុវណ្ណារ័ត្ន** អនុប្រធាននាយកដ្ឋាន និងលោក **ទ្រី ច័ន្ទតារារិទ្ធ** ប្រធានការិយាល័យ នៃនាយកដ្ឋានសវនកម្មសហគ្រាស នៃអគ្គនាយកដ្ឋានពន្ធដារ ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៥ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជនផងដែរ។ បើគិតមកដល់ដំណាច់ត្រីមាសទី៤ ឆ្នាំ២០២៥ តាមស្ថិតិនៅលើបណ្តាញយូធូបមានអ្នកចូលទស្សនាចំនួន ៣២៧ ដង។




សូមស្កេនដើម្បីចូលទៅទស្សនាវីដេអូដើម

## កម្មវិធីពន្ធដារកម្ពុជាស្តីពី "សៀវភៅណែនាំស្តីពីបែបបទនិងនីតិវិធីនៃការធ្វើសវនកម្មពន្ធដារសម្រាប់មន្ត្រីពន្ធដារ និងអ្នកជាប់ពន្ធ"

កម្មវិធីនេះមានលោក **ជួរ សៃ** អនុប្រធាននាយកដ្ឋាន និងលោក **ហ៊ាង សុភា** អនុប្រធានការិយាល័យ នៃនាយកដ្ឋានសវនកម្មសហគ្រាស នៃអគ្គនាយកដ្ឋានពន្ធដារ ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៥ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជនផងដែរ។ បើគិតមកដល់ដំណាច់ត្រីមាសទី៤ ឆ្នាំ២០២៥ តាមស្ថិតិនៅលើបណ្តាញយូធូបមានអ្នកចូលទស្សនាចំនួន ១១២ ដង។




សូមស្កេនដើម្បីចូលទៅទស្សនាវីដេអូដើម

## កម្មវិធីពន្ធដារកម្ពុជាស្តីពី "ភាតព្វកិច្ចសារពើពន្ធរបស់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាល"




សូមស្កេនដើម្បីចូលទៅទស្សនាវីដេអូដើម

កម្មវិធីនេះមានលោក **ទូច ជាភាដូ** ប្រធានការិយាល័យនៃនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម និងលោក **ខែន គីម** អនុប្រធានការិយាល័យនៃនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ នៃអគ្គនាយកដ្ឋានពន្ធដារ ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ ២០២៥ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជនផងដែរ។ បើគិតមកដល់ដំណាច់ត្រីមាសទី៤ ឆ្នាំ២០២៥ តាមស្ថិតិនៅលើបណ្តាញយូធូបមានអ្នកចូលទស្សនាចំនួន ១៥៦ ដង។

## កម្មវិធីពន្ធដារកម្ពុជាស្តីពី "ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យ"




សូមស្កេនដើម្បីចូលទៅទស្សនាវីដេអូដើម

កម្មវិធីនេះមានលោក **ទ៉ែត មីដូ** អនុប្រធានការិយាល័យ និងលោកស្រី **ចុង គីមគាង** អនុប្រធានការិយាល័យនៃនាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ នៃអគ្គនាយកដ្ឋានពន្ធដារ ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២៥ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជនផងដែរ។ បើគិតមកដល់ដំណាច់ត្រីមាសទី៤ ឆ្នាំ២០២៥ តាមស្ថិតិនៅលើបណ្តាញយូធូបមានអ្នកចូលទស្សនាចំនួន ១០៥ ដង។

## កម្មវិធីពន្ធដារកម្ពុជាស្តីពី "ការស្នើសុំលិខិតបញ្ជាក់ស្ថានភាពសារពើពន្ធនិងលិខិតអនុញ្ញាតឱ្យបង់ពន្ធជាដំណាក់កាល"




សូមស្កេនដើម្បីចូលទៅទស្សនាវីដេអូដើម

កម្មវិធីនេះមានលោក **ប៉ុ សណ្ដាប់** អនុប្រធាននាយកដ្ឋាន និងលោក **ខួន សិទ្ធីគុណ** មន្ត្រី នៃនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ នៃអគ្គនាយកដ្ឋានពន្ធដារ ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៥ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជនផងដែរ។ បើគិតមកដល់ដំណាច់ត្រីមាសទី៤ ឆ្នាំ២០២៥ តាមស្ថិតិនៅលើបណ្តាញយូធូបមានអ្នកចូលទស្សនាចំនួន ១ ៥០០ ដង។

# ៣.ការចាត់ចែងលិខិតប្រកាសពន្ធ

ក្នុងត្រីមាសទី៤ ឆ្នាំ២០២៥ អគ្គនាយកដ្ឋានពន្ធដារបានចេញសេចក្តីណែនាំមួយចំនួនដែលទាក់ទងនឹងការដាក់លិខិតប្រកាសពន្ធពីសំណាក់អ្នកជាប់ពន្ធរួមមាន៖

១. **សេចក្តីណែនាំលេខ ៣៧៧០៥ អពដ** ស្តីពីនីតិវិធីនៃការកត់ត្រា និងប្រកាសពន្ធចំពោះប្រតិបត្តិការកើតឡើង និងបានកត់ត្រាក្នុងបញ្ជីគណនេយ្យមុនការទូទាត់ប្រាក់ ចេញផ្សាយនាថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២៥។ ការចេញសេចក្តីណែនាំនេះគឺដើម្បីធានាបានប្រសិទ្ធភាព និងសង្គតិភាពក្នុងការអនុវត្តចំពោះប្រតិបត្តិការកើតឡើង និងបានកត់ត្រាក្នុងបញ្ជីគណនេយ្យមុនការទូទាត់ប្រាក់ អគ្គនាយកដ្ឋានពន្ធដារ សូមធ្វើការណែនាំបន្ថែមលើនីតិវិធីនៃការកត់ត្រា និងការប្រកាសពន្ធយ៉ាងលម្អិតដែលរួមមាន ទម្រង់សក្ខីបត្រ ការកត់ត្រាប្រតិបត្តិការចំណាយបង្គរ (ការកត់ត្រា ប្រតិបត្តិការ ចំណាយបង្គរ និងការកត់ត្រាចំណាយតាមវិក្កយបត្រជាក់ស្តែងលើប្រតិបត្តិការបានបង្គររួច) ការកត់ត្រាប្រតិបត្តិការចំណូលបង្គរ (ការកត់ត្រាប្រតិបត្តិការចំណូលបង្គរ និងការកត់ត្រាចំណូលតាមវិក្កយបត្រជាក់ស្តែងលើប្រតិបត្តិការបានបង្គររួច) ព្រមទាំងទោសទណ្ឌនានា។

២. **សេចក្តីណែនាំលេខ ៣៧៧០៦ អពដ** ស្តីពីនីតិវិធីនៃការប្រកាសពន្ធចំពោះប្រតិបត្តិការកើតឡើង និងបានកត់ត្រាក្នុងបញ្ជីគណនេយ្យមុនការទូទាត់ប្រាក់ក្នុងប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មតាមអនឡាញ (e-Filing) ចេញផ្សាយថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២៥។ ការចេញសេចក្តីណែនាំនេះ គឺដើម្បីជម្រាបជូនដល់លោក-លោកស្រី ជាអភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិកររបស់សហគ្រាស អ្នកជាប់ពន្ធ និងភ្នាក់ងារសេវាកម្មពន្ធដារ ឱ្យបានជ្រាបថា ស្របតាមទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន អគ្គនាយកដ្ឋានពន្ធដារ បានអភិវឌ្ឍមុខងារ **"ប្រកាសពន្ធចំពោះប្រតិបត្តិការកើតឡើង និងបានកត់ត្រាក្នុងបញ្ជីគណនេយ្យមុនការទូទាត់ប្រាក់"** ដើម្បីអនុញ្ញាតឱ្យអ្នកជាប់ពន្ធអាចធ្វើការកត់ត្រាប្រតិបត្តិការចំណូល-ចំណាយកើតឡើងមុនមានការទូទាត់ និងកត់ត្រាប្រតិបត្តិការចំណូល-ចំណាយតាមវិក្កយបត្រជាក់ស្តែង ទៅក្នុងប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មតាមអនឡាញ (e-Filing)។ នៅក្នុងសេចក្តីណែនាំនេះ ក៏បានណែនាំយ៉ាងលម្អិតអំពីនីតិវិធី និងការប្រើប្រាស់មុខងារនេះ តាមជំហាននីមួយៗ។



# ៤.ការធ្វើសវនកម្មពន្ធដារ

សរុបរយៈពេល ១២ខែ ឆ្នាំ២០២៥ អគ្គនាយកដ្ឋានពន្ធដារបានធ្វើសវនកម្មគ្រប់ប្រភេទលើសហគ្រាសសរុបបានចំនួន **៧ ៦៦១ ករណី** មានប្រាក់ពន្ធចំនួន **៣ ៩២៥,២៤ ប៊ីលានរៀល**។ បើប្រៀបធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៤ ឃើញថាការធ្វើសវនកម្មមានការថយចុះចំនួន **៣ ០៧៧ ករណី** ស្មើនឹង **-២៨,៦៦%** និងប្រាក់ពន្ធបានកំណត់មានការថយចុះ **១៦,៣៧%**។

**ចំនួនករណី និងប្រាក់ពន្ធអាករ ដែលបានមកពីការធ្វើសវនកម្ម រយៈពេល ១២ខែ ឆ្នាំ២០២៥ ធៀបនឹងរយៈពេលដូចគ្នា ក្នុងឆ្នាំ២០២៤**

| បរិយាយ | ចំនួនករណី | ប្រាក់ពន្ធអាករ(ប៊ីលានរៀល) |
|---|---|---|
| ឆ្នាំ២០២៥ | ៧ ៦៦១ | ៣ ៩២៥,២៤ |
| ឆ្នាំ២០២៤ | ១០ ៧៣៦ | ៤ ៦៩៣,៦១ |

# ៥.ការប្រមូលបំណុលពន្ធ និងបណ្តឹងតវ៉ា

## ការប្រមូលបំណុលពន្ធ

សរុបរយៈពេល ១២ខែ ឆ្នាំ២០២៥ បំណុលពន្ធប្រមូលបានមានចំនួន **៤៣២,៩០ ប៊ីលានរៀល** (ប្រមាណជា **១០៧,៩៥ លានដុល្លារ**) ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៤ មានការថយចុះចំនួន **១៥៥,៣៨ ប៊ីលានរៀល** (ប្រមាណជា **៣៨,៧៥ លានដុល្លារ**) ស្មើនឹង **-២៦,៤១%** ។

**លទ្ធផលប្រមូលបំណុលពន្ធ រយៈពេល ១២ខែ ឆ្នាំ២០២៥ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៤**

ឯកតាគិតជាប៊ីលានរៀល

| បរិយាយ | រយៈពេល៩ខែ | តុលា | វិច្ឆិកា | ធ្នូ | សរុបរួម |
|---|---|---|---|---|---|
| ឆ្នាំ២០២៥ | ៣៤៣,២៣ | ២៩,៧៥ | ៣០,៣៩ | ២៩,៥៣ | ៤៣២,៩០ |
| ឆ្នាំ២០២៤ | ៤៧៦,៤៣ | ៣៧,៨០ | ៣៣,៣៩ | ៤០,៦៦ | ៥៨៨,២៨ |
| %កើន/ថយ | -២៧,៩៦% | -២១,៣១% | -៨,៩៩% | -២៧,៣៧% | -២៦,៤១% |

## បណ្តឹងតវ៉ា

ក្នុងរយៈពេល ១២ខែ ឆ្នាំ២០២៥ អគ្គនាយកដ្ឋានពន្ធដារបានដោះស្រាយសំណុំឯកសារបណ្តឹងតវ៉ា ចំនួន **៧៦២ ករណី** ប្រៀបធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៤ គឺមានការកើនឡើងចំនួន **១២០ ករណី**។

# ៦.បច្ចេកវិទ្យាព័ត៌មាន

អគ្គនាយកដ្ឋានពន្ធដារបានបន្តធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងបច្ចេកវិទ្យាព័ត៌មានពន្ធដារ សម្រាប់គាំទ្រដល់ការគ្រប់គ្រងការប្រមូលចំណូលពន្ធ ការផ្តល់សេវាអ្នកជាប់ពន្ធ ចាប់ពីឆ្នាំ២០១៤ ដល់បច្ចុប្បន្នសរុបចំនួន **៧១ ប្រព័ន្ធ-កម្មវិធី** និង **គេហទំព័រ**។

**ការធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ ពីឆ្នាំ ២០១៤ ដល់បច្ចុប្បន្ន**

| បរិយាយ | ប្រព័ន្ធ | កម្មវិធី | គេហទំព័រ | សរុបរួម |
|---|---|---|---|---|
| ឆ្នាំ២០១៤ | ០៣ | ០១ | ០០ | ០៤ |
| ឆ្នាំ២០១៥ | ០៣ | ០២ | ០០ | ០៥ |
| ឆ្នាំ២០១៦ | ០៣ | ០១ | ០០ | ០៤ |
| ឆ្នាំ២០១៧ | ១០ | ០១ | ០១ | ១២ |
| ឆ្នាំ២០១៨ | ០៤ | ០៤ | ០០ | ០៨ |
| ឆ្នាំ២០១៩ | ០១ | ០០ | ០០ | ០១ |
| ឆ្នាំ២០២០ | ១៣ | ០៤ | ០១ | ១៨ |
| ឆ្នាំ២០២១ | ០៤ | ០១ | ០០ | ០៥ |
| ឆ្នាំ២០២២ | ០៨ | ០៣ | ០០ | ១១ |
| ឆ្នាំ២០២៣ | ០២ | ០១ | ០០ | ០៣ |
| ឆ្នាំ២០២៤ | ០០ | ០០ | ០០ | ០០ |
| ឆ្នាំ២០២៥ | ០០ | ០០ | ០០ | ០០ |
| **សរុបរួម** | ៥១ | ១៨ | ០២ | ៧១ |

## គេហទំព័រអគ្គនាយកដ្ឋានពន្ធដារ (GDT Website)

អគ្គនាយកដ្ឋានពន្ធដារមានគេហទំព័រផ្លូវការមួយ (www.tax.gov.kh) ដើម្បីផ្សព្វផ្សាយព័ត៌មានថ្មីៗ ទាក់ទងនឹងអ្នកជាប់ពន្ធ សេវាសាធារណៈ ច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ ទំនាក់ទំនងអន្តរជាតិ សេវាកម្មអេឡិចត្រូនិកពន្ធដារ និងកិច្ចការទាំងឡាយរបស់អង្គភាពពន្ធដារ ដែលតែងតែមានអ្នកជាប់ពន្ធចូលទស្សនានិងទាញយកឯកសារជាប្រចាំ។ ជាក់ស្តែង ក្នុងខែធ្នូ ឆ្នាំ២០២៥ មានចំនួនអ្នកចូលទស្សនា **៨២៨ ៨០០ ដង** និងក្នុងរយៈពេល១២ខែ ឆ្នាំ២០២៥ មានចំនួនអ្នកចូលទស្សនាសរុប **៤ ០៩៥ ៨៤៣ ដង**។

## ការធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ ពីឆ្នាំ ២០១៤ ដល់បច្ចុប្បន្ន

### ឆ្នាំ២០១៤

១.កម្មវិធីគណនាពន្ធលើមធ្យោបាយដឹកជញ្ជូន
២.ប្រព័ន្ធគ្រប់គ្រងពន្ធមធ្យោបាយដឹកជញ្ជូន
៣.ប្រព័ន្ធគ្រប់គ្រងការចុះបញ្ជីសហគ្រាស
៤.ប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស

### ឆ្នាំ២០១៥

៥.កម្មវិធីគណនាពន្ធលើប្រាក់បៀវត្ស
៦.កម្មវិធីប្រតិទិនពន្ធដារ
៧.ប្រព័ន្ធសុវត្ថិភាពច្រកចេញ-ចូល
៨.ប្រព័ន្ធគ្រប់គ្រងពន្ធអចលទ្រព្យ និងប្រថាប់ត្រា
៩.ប្រព័ន្ធគ្រប់គ្រងពាក្យស្នើសុំប្រឡងចូលបម្រើការងារ

### ឆ្នាំ២០១៦

១០.កម្មវិធីអង្កេតសហគ្រាស
១១.ប្រព័ន្ធគ្រប់គ្រងសន្និធិបង្កាន់ដៃទទួលប្រាក់ពន្ធ
១២.ប្រព័ន្ធគ្រប់គ្រងការទទួលប្រាក់ពន្ធ
១៣.ប្រព័ន្ធគ្រប់គ្រងលើការជួលអចលនទ្រព្យ

### ឆ្នាំ២០១៧

១៤.គេហទំព័របញ្ជូនរបាយការណ៍ព័ត៌មាន(FATCA)
១៥.ប្រព័ន្ធត្រួតពិនិត្យពន្ធមធ្យោបាយតាម RFID
១៦.ប្រព័ន្ធគ្រប់គ្រងកម្មវិធីប្រជុំរបស់អពដ
១៧.ប្រព័ន្ធគ្រប់គ្រងបំណុលពន្ធ
១៨.ប្រព័ន្ធគ្រប់គ្រងគណនីរបស់មន្ត្រីនិងដៃគូសហការ
១៩.ប្រព័ន្ធរក្សាទុកនិងចែកចាយឯកសារផ្ទៃក្នុង
២០.ប្រព័ន្ធគ្រប់គ្រងអ៊ីម៉ែលរបស់អពដ
២១.ប្រព័ន្ធគ្រប់គ្រងសន្លឹកតែមប្រិ៍បារី
២២.ប្រព័ន្ធគ្រប់គ្រងសវនកម្មសហគ្រាស
២៣.ប្រព័ន្ធគ្រប់គ្រងមជ្ឈមណ្ឌលពិគ្រោះយោបល់
២៤.ប្រព័ន្ធគ្រប់គ្រងការបង់ពន្ធតាមអនឡាញ
២៥.កម្មវិធីត្រួតពិនិត្យតែមប្រិ៍បារី

### ឆ្នាំ២០១៨

២៦.ប្រព័ន្ធគ្រប់គ្រងព័ត៌មានសហគ្រាស
២៧.ប្រព័ន្ធគ្រប់គ្រងព័ត៌មានបុគ្គល
២៨.ប្រព័ន្ធគ្រប់គ្រងតាមដានឯកសារ
២៩.ប្រព័ន្ធតាមដានចំណូលពន្ធដារ
៣០.កម្មវិធីព័ត៌មានស្តីពីពន្ធដារ
៣១.កម្មវិធីត្រួតពិនិត្យបេក្ខជនប្រឡង
៣២.កម្មវិធីជជែកជាមួយពន្ធដារ
៣៣.កម្មវិធីអង្កេតអចលនទ្រព្យ

### ឆ្នាំ២០១៩

៣៤.ប្រព័ន្ធគ្រប់គ្រងការស្នើសុំបង្វិលសង អតប

### ឆ្នាំ២០២០

៣៥.គេហទំព័រអគ្គនាយកដ្ឋានពន្ធដារ
៣៦.ប្រព័ន្ធគ្រប់គ្រងរបាយការណ៍នៃការផ្ញើសារខ្លី
៣៧.ប្រព័ន្ធបញ្ជូនឯកសារលិខិតប្រកាសរបស់អពដ
៣៨.ប្រព័ន្ធសន្ទានកម្មទិន្នន័យរវាងប្រព័ន្ធអពដ និងអគរក
៣៩.ប្រព័ន្ធសន្ទានកម្មទិន្នន័យរវាងប្រព័ន្ធអពដ និងដឹកជញ្ជូនផ្លូវគោក នៃក្រសួងសាធារណការនិងដឹកជញ្ជូន
៤០.ប្រព័ន្ធសន្ទានកម្មទិន្នន័យចំណូលពន្ធរវាង FMIS
៤១.ប្រព័ន្ធគ្រប់គ្រងស្នើសុំការលើកទឹកចិត្តពន្ធដារ
៤២.ប្រព័ន្ធគ្រប់គ្រងការសិក្សាពន្ធដារ
៤៣.ប្រព័ន្ធគ្រប់គ្រងគណនីអ្នកជាប់ពន្ធ
៤៤.ប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មតាមអនឡាញ
៤៥.ប្រព័ន្ធគ្រប់គ្រងសន្និធិរបស់អគ្គនាយកដ្ឋានពន្ធដារ
៤៦.ប្រព័ន្ធគ្រប់គ្រងការចៀសវាងយកពន្ធត្រួតគ្នា
៤៧.ប្រព័ន្ធគ្រប់គ្រងចុះបញ្ជីសហគ្រាសតាមថ្នាលបច្ចេកវិទ្យា
៤៨.ប្រព័ន្ធគ្រប់គ្រងបង់ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិយានយន្ត
៤៩.កម្មវិធីការប្រកាសពន្ធអាជីវកម្មសម្រាប់អ្នកជាប់ពន្ធតូច
៥០.កម្មវិធីត្រួតពិនិត្យនិងតាមដានឯកសារ
៥១.កម្មវិធីទូរស័ព្ទដៃអ្នកជាប់ពន្ធ
៥២.កម្មវិធីគ្រប់គ្រងលិខិតរដ្ឋបាលពន្ធដារ

### ឆ្នាំ២០២១

៥៣.ប្រព័ន្ធគ្រប់គ្រងសវនកម្មអាករលើតម្លៃបន្ថែម
៥៤.ប្រព័ន្ធគ្រប់គ្រងការស្នើសុំវិញ្ញាបនបត្រពន្ធដារ
៥៥.ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាស TOI តាមអនឡាញ
៥៦.កម្មវិធីបញ្ជូនឯកសារអេឡិចត្រូនិក
៥៧.កម្មវិធីផ្ទៀងផ្ទាត់ព័ត៌មានតាមទីតាំង និងប្រគល់ឯកសារពន្ធដារ

### ឆ្នាំ២០២២

៥៨.ប្រព័ន្ធគ្រប់គ្រង និងគាំទ្រកម្មវិធីទូរស័ព្ទដៃ-ពន្ធតែមប្រិ៍
៥៩.ប្រព័ន្ធគ្រប់គ្រងគណនីអ្នកប្រើប្រាស់តាមអនឡាញ
៦០.ប្រព័ន្ធគ្រប់គ្រង និងគាំទ្រកម្មវិធីទូរស័ព្ទដៃ-ពន្ធអចលនទ្រព្យ
៦១.ប្រព័ន្ធគ្រប់គ្រងអត្រាប្តូរប្រាក់
៦២.ប្រព័ន្ធគ្រប់គ្រងកម្មវិធីក្លាយបត្រនាំសំណាង (សម្រាប់មន្ត្រី)
៦៣.ប្រព័ន្ធគ្រប់គ្រងទិន្នន័យអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក
៦៤.ប្រព័ន្ធគ្រប់គ្រងទិន្នន័យឧបករណ៍វាស់ចំណុះស្រាបៀរនិងភេសជ្ជៈ
៦៥.ប្រព័ន្ធគ្រប់គ្រងចំណាត់ថ្នាក់(MeritandDemerit_MDS)
៦៦.កម្មវិធីក្លាយបត្រនាំសំណាង
៦៧.កម្មវិធីសទ្ទានុក្រមពន្ធដារ
៦៨.កម្មវិធីផ្ទៀងផ្ទាត់ព័ត៌មានសិស្ស(សម្រាប់ការបណ្តុះបណ្តាល)

### ឆ្នាំ២០២៣

៦៩.ប្រព័ន្ធកំណត់ផែនការចំណូលពន្ធ
៧០.ប្រព័ន្ធគ្រប់គ្រងនិងគាំទ្រកម្មវិធីទូរស័ព្ទដៃ-ពន្ធលើផ្ទាំងផ្សព្វផ្សាយ
៧១.កម្មវិធីលិខិតរដ្ឋបាលអេឡិចត្រូនិកពន្ធដារ

# ផ្នែកទី៣

## បច្ចុប្បន្នភាពច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយសារពើពន្ធ

១. ប្រកាស

២. សេចក្តីណែនាំ

៣. សេចក្តីជូនដំណឹង

៤. សារាចរណែនាំ

# បច្ចុប្បន្នភាពច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយសារពើពន្ធ

សរុបក្នុងរយៈពេល ១២ខែ ឆ្នាំ២០២៥ អគ្គនាយកដ្ឋានពន្ធដារបាននិងកំពុងកែលម្អគោលនយោបាយសារពើពន្ធ តាមរយៈការដាក់ចេញឱ្យអនុវត្តនូវលិខិតបទដ្ឋានគតិយុត្តនានាស្តីពីពន្ធដារ ដូចមានក្នុងតារាងនិងអត្ថបទខាងក្រោម៖

**បច្ចុប្បន្នភាពច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយសារពើពន្ធ រយៈពេល ១២ខែ ឆ្នាំ២០២៥**

| បរិយាយ | រយៈពេល៩ខែ | ខែតុលា | ខែវិច្ឆិកា | ខែធ្នូ | សរុបរួម |
|---|---|---|---|---|---|
| ច្បាប់ | ០០ | ០០ | ០០ | ០០ | ០០ |
| អនុក្រឹត្យ | ០០ | ០០ | ០០ | ០០ | ០០ |
| ប្រកាស | ០២ | ០០ | ០២ | ០២ | ០៦ |
| សារាចរណែនាំ | ០០ | ០០ | ០០ | ០១ | ០១ |
| សេចក្តីណែនាំ | ១៤ | ០០ | ០០ | ០៣ | ១៧ |
| សេចក្តីជូនដំណឹង | ១៧ | ០២ | ០១ | ០៥ | ២៥ |
| សេចក្តីសម្រេច | ០០ | ០០ | ០០ | ០០ | ០០ |
| **សរុបរួម** | ៣៣ | ០២ | ០៣ | ១១ | ៤៩ |

## ១.ប្រកាស

### ប្រកាស ស្តីពីការចាត់ជាបន្ទុករបស់រដ្ឋនូវអាករលើតម្លៃបន្ថែមលើមុខទំនិញ ដែលជាអាហារជាមូលដ្ឋានសម្រាប់ការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ

នាថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៥ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញប្រកាសលេខ ៩៤៨ សហវ.ប្រក.អពដ ស្តីពីការចាត់ជាបន្ទុករបស់រដ្ឋនូវអាករលើតម្លៃបន្ថែមលើមុខទំនិញដែលជាអាហារជាមូលដ្ឋានសម្រាប់ការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។ ប្រកាសនេះ មានគោលបំណងដាក់ជាបន្ទុករបស់រដ្ឋនូវអាករលើតម្លៃបន្ថែមលើមុខទំនិញផលិតក្នុងស្រុកដែលជាអាហារជាមូលដ្ឋាន ដើម្បីជួយសម្រួលជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។ ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះការផ្គត់ផ្គង់ទំនិញផលិតក្នុងស្រុកដែលជាអាហារជាមូលដ្ឋានដោយអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស និងត្រូវបានចាត់ជាបន្ទុករបស់រដ្ឋរហូតដល់ដំណាច់ឆ្នាំ២០២៨។ អាហារជាមូលដ្ឋាន សំដៅដល់មុខទំនិញផលិតក្នុងស្រុកមួយចំនួនដែលចាំបាច់សម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃដូចខាងក្រោម៖

១. សាច់សត្វចិញ្ចឹម ទោះបីមានលក្ខណៈជាសាច់ស្រស់ ឬកែច្នៃតាមវិធីផ្អាប់ ប្រឡាក់ ឬឆ្អើរ។

២. ស៊ុតសត្វចិញ្ចឹមគ្រប់ប្រភេទ ទោះបីមានលក្ខណៈជាស៊ុតស្រស់ ឬកែច្នៃ។

៣. ត្រីទឹកសាប ឬទឹកប្រៃគ្រប់ប្រភេទ រួមទាំង បង្កង បង្គា កំពឹស ក្តាម និងសិប្បីជាតិគ្រប់ប្រភេទ ទោះបីមានលក្ខណៈជាសាច់ស្រស់ ឬកែច្នៃតាមវិធីផ្អាប់ ប្រឡាក់ ឬឆ្អើរ។

៤. ស្ករគ្រប់ប្រភេទ ដែលមិនមានលក្ខណៈជាស្ករគ្រាប់។

៥. អំបិលគ្រប់ប្រភេទ។

៦. ទឹកត្រី ឬទឹកស៊ីអ៊ីវគ្រប់ប្រភេទ៕

សូមស្កេន QR Code
ដើម្បីទទួលបានឯកសារ ឬអានលម្អិត

## ប្រកាស ស្តីពីការលើកទឹកចិត្តពន្ធដារចំពោះវិស័យកសិកម្ម

នាថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៥ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញប្រកាសលេខ ៩៦២ សហវ.ប្រក.អពដ ស្តីពីការលើកទឹកចិត្តពន្ធដារចំពោះវិស័យកសិកម្ម។ ប្រកាសនេះ មានគោលបំណងដាក់ចេញនូវវិធានការលើកទឹកចិត្តពន្ធដារចំពោះវិស័យកសិកម្ម និងមានវិសាលភាពអនុវត្តចំពោះការដាំដុះ ការផលិត ការផ្គត់ផ្គង់ក្នុងស្រុក ឬការនាំចេញ ស្រូវ អង្ករ ពោត សណ្តែក ម្រេច ដំឡូងមី គ្រាប់ស្វាយចន្ទី ជ័រកៅស៊ូ មៀនប៉ៃលិន ស្វាយ ចេក ការចិញ្ចឹមសត្វ វារីវប្បកម្ម និងផលិតផលដូងប្រេងក្នុងស្រុកដែលជាវត្ថុធាតុដើមសម្រាប់ផលិតចំណីសត្វ។ ការលើកទឹកចិត្តចំពោះវិស័យកសិកម្មនេះ ត្រូវបន្តអនុគ្រោះរហូតដល់ដំណាច់ឆ្នាំ២០២៧ ដោយទទួលបានការអនុគ្រោះដូចជា៖ ការព្យួរទុកការបង់ពន្ធអប្បបរមា ការព្យួរទុកការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូល និងការរួចផុតពីកាតព្វកិច្ចកាត់ទុកប្រាក់ពន្ធលើការទូទាត់ចំពោះការផ្គត់ផ្គង់សេវាដោយបុគ្គលមិនស្ថិតក្នុងរបបស្វ័យប្រកាស។

សូមស្កេន QR Code
ដើម្បីទទួលបានឯកសារ ឬអានលម្អិត

## ប្រកាស ស្តីពីការព្យួរទុកការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូល របស់សហគ្រាសឧស្សាហកម្មផ្នែកវាយនភណ្ឌកាត់ដេរ

នាថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៥ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញប្រកាសលេខ ១១២៣ សហវ.ប្រក.អពដ ស្តីពីការព្យួរទុកការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូលរបស់សហគ្រាសឧស្សាហកម្មផ្នែកវាយនភណ្ឌកាត់ដេរ។ ប្រកាសនេះ មានគោលបំណងព្យួរទុកការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូលរបស់សហគ្រាសក្នុងវិស័យឧស្សាហកម្មផ្នែកវាយនភណ្ឌកាត់ដេរ ដើម្បីឱ្យមាននិរន្តរភាព ជំរុញការនាំចេញ និងបង្កើតការងារដល់កម្មករ កម្មការិនី ព្រមទាំងប្រជាពលរដ្ឋដែលទទួលបានផលប្រយោជន៍ពីវិស័យនេះ។ ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះសហគ្រាសជាគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ (គ.ល.គ.) ក្នុងវិស័យវាយនភណ្ឌកាត់ដេរដែលផុតរយៈពេលលើកលែងពន្ធលើប្រាក់ចំណូល រួមមាន សហគ្រាសវាយនភណ្ឌ សហគ្រាសផលិតសម្លៀកបំពាក់ សហគ្រាសផលិតស្បែកជើង សហគ្រាសផលិតកាបូបយួរនិងកាបូបដៃ និងសហគ្រាសផលិតមួក ព្រមទាំងសហគ្រាសផលិតស្លាកយីហោសម្រាប់សម្លៀកបំពាក់ សហគ្រាសផលិតស្រោមដៃ សហគ្រាសផលិតស្រោមជើង សហគ្រាសផលិតកន្សែង សហគ្រាសផលិតស្រោមខ្នើយ សហគ្រាសផលិតស្រោមភួយ សហគ្រាសផលិតកម្រាលពូក និងសហគ្រាសផលិតកម្រាលតុ សម្រាប់បម្រើដល់ការនាំចេញ។ ការអនុគ្រោះព្យួរទុកជាបណ្តោះអាសន្ននូវការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូលប្រចាំខែរហូតដល់ដំណាច់ឆ្នាំ២០២៨។

សូមស្កេន QR Code
ដើម្បីទទួលបានឯកសារ ឬអានលម្អិត

## ប្រកាស ស្តីពីពន្ធលើចំណេញមូលធន

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញប្រកាសលេខ ១១៣០ សហវ.ប្រក.អពដ ស្តីពីពន្ធលើចំណេញមូលធន។ ប្រកាសនេះ មានគោលបំណងកំណត់នូវវិធាន និងនីតិវិធីនៃការគ្រប់គ្រងប្រមូលពន្ធលើចំណេញមូលធន។ ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះអ្នកជាប់ពន្ធនិវាសនជនជារូបវន្តបុគ្គលដែលសម្រេចបានចំណេញមូលធនពីការលក់ឬផ្ទេរចំពោះមូលធនដែលស្ថិតនៅព្រះរាជាណាចក្រកម្ពុជានិងនៅបរទេស និងអ្នកជាប់ពន្ធអនិវាសនជន ដែលសម្រេចបានចំណេញមូលធនពីការលក់ឬផ្ទេរចំពោះមូលធនដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ មូលធនសំដៅដល់ទ្រព្យចំនួន ៦ (ប្រាំមួយ) ប្រភេទ រួមមាន អចលនទ្រព្យ ភតិសន្យា ទ្រព្យវិនិយោគ កេរ្តិ៍ឈ្មោះអាជីវកម្ម កម្មសិទ្ធិបញ្ញា និងរូបិយបណ្ណបរទេស។ អត្រាពន្ធលើចំណេញមូលធន ត្រូវបានកំណត់តាមអត្រា ២០ (ម្ភៃ) ភាគរយនៃចំណេញមូលធន។

សូមស្កេន QR Code
ដើម្បីទទួលបានឯកសារ ឬអានលម្អិត

# ២.សេចក្តីណែនាំ

## សេចក្តីណែនាំ ស្តីពីនីតិវិធីនៃការកត់ត្រា និងប្រកាសពន្ធ ចំពោះប្រតិបត្តិការកើតឡើង និងបានកត់ត្រាក្នុងបញ្ជីគណនេយ្យមុនការទូទាត់ប្រាក់

នាថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២៥ អគ្គនាយកដ្ឋានពន្ធដារបានចេញសេចក្តីណែនាំលេខ ៣៧៧០៥ អពដ ស្តីពីនីតិវិធីនៃការកត់ត្រា និងប្រកាសពន្ធចំពោះប្រតិបត្តិការកើតឡើង និងបានកត់ត្រាក្នុងបញ្ជីគណនេយ្យមុនការទូទាត់ប្រាក់។ ការចេញសេចក្តីណែនាំនេះ គឺដើម្បីធានាបានប្រសិទ្ធភាព និងសង្គតិភាពក្នុងការអនុវត្តចំពោះប្រតិបត្តិការកើតឡើង និងបានកត់ត្រាក្នុងបញ្ជីគណនេយ្យមុនការទូទាត់ប្រាក់ អគ្គនាយកដ្ឋានពន្ធដារ សូមធ្វើការណែនាំបន្ថែមលើនីតិវិធីនៃការកត់ត្រា និងការប្រកាសពន្ធយ៉ាងលម្អិតដែលរួមមាន ទម្រង់សក្ខីបត្រ ការកត់ត្រាប្រតិបត្តិការចំណាយបង្គរ (ការកត់ត្រាប្រតិបត្តិការចំណាយបង្គរ និងការកត់ត្រាចំណាយតាមវិក្កយបត្រជាក់ស្តែងលើប្រតិបត្តិការបានបង្គររួច) ការកត់ត្រាប្រតិបត្តិការចំណូលបង្គរ (ការកត់ត្រាប្រតិបត្តិការចំណូលបង្គរ និងការកត់ត្រាចំណូលតាមវិក្កយបត្រជាក់ស្តែងលើប្រតិបត្តិការបានបង្គររួច) ព្រមទាំងទោសទណ្ឌនានា៕

សូមស្កេន QR Code
ដើម្បីទទួលបានឯកសារ ឬអានលម្អិត

## សេចក្តីណែនាំ ស្តីពីនីតិវិធីនៃការប្រកាសពន្ធចំពោះប្រតិបត្តិការកើតឡើង និងបានកត់ត្រាក្នុងបញ្ជីគណនេយ្យមុនការទូទាត់ប្រាក់ក្នុងប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មតាមអនឡាញ (e-Filing)

នាថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២៥ អគ្គនាយកដ្ឋានពន្ធដារបានចេញសេចក្តីណែនាំលេខ ៣៧៧០៦ អពដ ស្តីពីនីតិវិធីនៃការប្រកាសពន្ធចំពោះប្រតិបត្តិការកើតឡើង និងបានកត់ត្រាក្នុងបញ្ជីគណនេយ្យមុនការទូទាត់ប្រាក់ក្នុងប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មតាមអនឡាញ (e-Filing)។ ការចេញសេចក្តីណែនាំនេះ គឺដើម្បីជម្រាបជូនដល់លោក-លោកស្រី ជាអភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិកររបស់សហគ្រាស អ្នកជាប់ពន្ធ និងភ្នាក់ងារសេវាកម្មពន្ធដារ ឱ្យបានជ្រាបថា ស្របតាមទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន អគ្គនាយកដ្ឋានពន្ធដារ បានអភិវឌ្ឍមុខងារ **"ប្រកាសពន្ធចំពោះប្រតិបត្តិការកើតឡើង និងបានកត់ត្រាក្នុងបញ្ជីគណនេយ្យមុនការទូទាត់ប្រាក់"** ដើម្បីអនុញ្ញាតឱ្យអ្នកជាប់ពន្ធអាចធ្វើការកត់ត្រាប្រតិបត្តិការចំណូល-ចំណាយកើតឡើងមុនមានការទូទាត់ និងកត់ត្រាប្រតិបត្តិការចំណូល-ចំណាយតាមវិក្កយបត្រជាក់ស្តែង ទៅក្នុងប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មតាមអនឡាញ (e-Filing)។ នៅក្នុងសេចក្តីណែនាំនេះ ក៏បានណែនាំយ៉ាងលម្អិតអំពីនីតិវិធី និងការប្រើប្រាស់មុខងារនេះ តាមជំហាននីមួយៗ៕

សូមស្កេន QR Code
ដើម្បីទទួលបានឯកសារ ឬអានលម្អិត

## សេចក្តីណែនាំ ស្តីពីការអនុវត្តពន្ធលើចំណេញមូលធន

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញសេចក្តីណែនាំលេខ ០២២ សហវ.សណន.អពដ ស្តីពីការអនុវត្តពន្ធលើចំណេញមូលធន។ ការចេញសេចក្តីណែនាំនេះ គឺដើម្បីធានាបាននូវប្រសិទ្ធភាព និងសង្គតិភាពក្នុងការអនុវត្តពន្ធលើចំណេញមូលធន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំលម្អិតអំពីនីតិវិធីនៃការគណនាពន្ធលើចំណេញមូលធន មូលធនជាអចលនទ្រព្យ មូលធនដទៃទៀត និងមូលធនសម្រេចបានក្រៅព្រះរាជាណាចក្រកម្ពុជា ព្រមទាំងលើកជាឧទាហរណ៍ពីការគណនាមកពន្យល់យ៉ាងក្បោះក្បាយ៕

សូមស្កេន QR Code
ដើម្បីទទួលបានឯកសារ ឬអានលម្អិត

# ៣.សេចក្តីជូនដំណឹង

## សេចក្តីជូនដំណឹង ស្តីពីការពន្យារពេលបង់ពន្ធលើអចលនទ្រព្យ សម្រាប់ឆ្នាំ២០២៥ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

នាថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៥ អគ្គនាយកដ្ឋានពន្ធដារបានចេញសេចក្តីជូនដំណឹងលេខ ៣២៣២២ អពដ ស្តីពីការពន្យារពេលបង់ពន្ធលើអចលនទ្រព្យ សម្រាប់ឆ្នាំ២០២៥ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥។ ការចេញសេចក្តីជូនដំណឹងនេះ គឺដើម្បីជម្រាបជូនដំណឹងដល់ម្ចាស់អចលនទ្រព្យទាំងអស់ ដែលមិនទាន់បានបំពេញកាតព្វកិច្ចចុះបញ្ជីអចលនទ្រព្យ ឬធ្វើបច្ចុប្បន្នភាពព័ត៌មានអចលនទ្រព្យ និងប្រកាសបង់ប្រាក់ពន្ធនៅឡើយ សូមអញ្ជើញទៅចុះបញ្ជីអចលនទ្រព្យ ឬធ្វើបច្ចុប្បន្នភាពព័ត៌មានអចលនទ្រព្យរបស់ខ្លួន នៅសាខាពន្ធដារខេត្ត-ខណ្ឌដែលអចលនទ្រព្យស្ថិតនៅ។ ចំពោះម្ចាស់អចលនទ្រព្យ ដែលបានចុះបញ្ជីនិងធ្វើបច្ចុប្បន្នភាពព័ត៌មានអចលនទ្រព្យរួចរាល់ក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យអចលនទ្រព្យរបស់អគ្គនាយកដ្ឋានពន្ធដារ និងមានបណ្ណសម្គាល់ការបង់ពន្ធអចលនទ្រព្យ មេត្តាអញ្ជើញមកប្រកាសបង់ប្រាក់ពន្ធឱ្យបានទាន់ពេលវេលាត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ នៅអគ្គនាយកដ្ឋានពន្ធដារ ឬសាខាពន្ធដារខេត្ត-ខណ្ឌដែលអចលនទ្រព្យស្ថិតនៅ ឬនៅគ្រប់សាខាធនាគារពាណិជ្ជដែលបានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬបង់ពន្ធតាមរយៈកម្មវិធីទូរស័ព្ទដៃអ្នកជាប់ពន្ធ (GDT Taxpayer App) ដែលអាចទាញយកមកប្រើប្រាស់ពី App Store ឬ Play Store សម្រាប់អចលនទ្រព្យដែលធ្លាប់បានប្រកាសបង់ពន្ធលើអចលនទ្រព្យកន្លងមក៕

សូមស្កេន QR Code
ដើម្បីទទួលបានឯកសារ ឬអានលម្អិត

## សេចក្តីជូនដំណឹង ស្តីពីការពន្យារពេលនៃការអនុវត្ត ប្រកាសលេខ ៤៩៦ សហវ.ប្រក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៥ ស្តីពីពន្ធលើចំណេញមូលធន

នាថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៥ អគ្គនាយកដ្ឋានពន្ធដារបានចេញសេចក្តីជូនដំណឹងលេខ ៣៤២៣៦ អពដ ស្តីពីការពន្យារពេលនៃការអនុវត្តប្រកាសលេខ ៤៩៦ សហវ.ប្រក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៥ ស្តីពីពន្ធលើចំណេញមូលធន។ ការចេញសេចក្តីជូនដំណឹងនេះ គឺដើម្បីជម្រាបជូនអ្នកជាប់ពន្ធ និងសាធារណជនទាំងអស់ ជ្រាបថាអនុលោមតាមចំណារឯកភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រ **កម្ពុជា** ចុះថ្ងៃទី ១៤ ខែតុលា ឆ្នាំ២០២៥ លើលិខិតលេខ ១០៣៤៨ សហវ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រាជរដ្ឋាភិបាលបានសម្រេចពន្យារពេលនៃការអនុវត្តប្រកាសលេខ ៤៩៦ សហវ.ប្រក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៥ ស្តីពីពន្ធលើចំណេញមូលធន រហូតដល់ថ្ងៃទី១ ខែមករា ឆ្នាំ២០២៦។ ក្នុងន័យនេះ ពន្ធលើចំណេញមូលធនចំពោះទ្រព្យទាំង ៦ ប្រភេទ រួមមាន ភតិសន្យា ទ្រព្យវិនិយោគ កេរ្តិ៍ឈ្មោះអាជីវកម្ម កម្មសិទ្ធិបញ្ញា រូបិយបណ្ណបរទេស និងអចលនទ្រព្យ នឹងត្រូវចាប់ផ្តើមអនុវត្ត ដំណាលគ្នា នៅថ្ងៃទី១ ខែមករា ឆ្នាំ២០២៦ ស្របតាមការសម្រេចរបស់រាជរដ្ឋាភិបាលនាពេលកន្លងទៅ៕

សូមស្កេន QR Code
ដើម្បីទទួលបានឯកសារ ឬអានលម្អិត

## សេចក្តីជូនដំណឹង ស្តីពីការរំលឹកលើកទី២ នៃការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូនសម្រាប់ឆ្នាំ២០២៥

នាថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៥ អគ្គនាយកដ្ឋានពន្ធដារបានចេញសេចក្តីជូនដំណឹងលេខ ៣៥៤៩២ អពដ ស្តីពីការរំលឹកលើកទី២ នៃការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូនសម្រាប់ឆ្នាំ២០២៥។ ការចេញសេចក្តីជូនដំណឹងនេះ គឺដើម្បីធ្វើការក្រើនរំលឹកដល់ម្ចាស់យានយន្តទាំងអស់ដែលមិនទាន់បានបំពេញកាតព្វកិច្ចបង់ពន្ធលើមធ្យោបាយដឹកជញ្ជូនសម្រាប់ឆ្នាំ២០២៥ មេត្តារួសរាន់អញ្ជើញមកបង់ពន្ធឱ្យបានទាន់ពេលវេលាត្រឹមថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅអគ្គនាយកដ្ឋានពន្ធដារ ឬនៅសាខាពន្ធដារខេត្ត-ខណ្ឌ ឬនៅតាមធនាគារដែលបានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬអាចបង់តាមរយៈកម្មវិធី "GDT Taxpayer App" ដែលអាចទាញយកចេញពី App Store ចំពោះ iOS ឬ Play Store ចំពោះ Android សម្រាប់យានយន្តដែលធ្លាប់បានប្រកាសបង់ពន្ធលើមធ្យោបាយដឹកជញ្ជូនកន្លងមក៕

សូមស្កេន QR Code ដើម្បីទទួលបានឯកសារ ឬអានលម្អិត

## សេចក្តីជូនដំណឹង ស្តីពីការលុបចោលអាជ្ញាប័ណ្ណ ភ្នាក់ងារសេវាកម្មពន្ធដាររបស់ក្រុមហ៊ុន អេចជី & ភី ផាតនើរ ឯ.ក

នាថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២៥ អគ្គនាយកដ្ឋានពន្ធដារបានចេញសេចក្តីជូនដំណឹងលេខ ៣៧៧២៩ អពដ ស្តីពីការលុបចោលអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដាររបស់ក្រុមហ៊ុន អេចជី & ភី ផាតនើរ ឯ.ក។ ការចេញសេចក្តីជូនដំណឹងនេះ គឺដើម្បីជម្រាបជូនដំណឹងដល់អ្នកជាប់ពន្ធ ឬសាធារណជនទូទៅទាំងអស់ ឱ្យបានជ្រាបថា ក្រុមហ៊ុននេះ ត្រូវបានលុបអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ និងត្រូវបានបាត់បង់នីតិសម្បទាជាភ្នាក់ងារសេវាកម្មពន្ធដារ ដែលមិនអាចផ្តល់សេវាពាក់ព័ន្ធនឹងពន្ធដារជូនអតិថិជន ឬជូនអ្នកជាប់ពន្ធទៀតទេ គិតចាប់ពីកាលបរិច្ឆេទនៃការចេញលិខិតជូនដំណឹងនេះតទៅ។ ក្នុងន័យនេះ អ្នកជាប់ពន្ធ ឬសាធារណជនទូទៅដែលកំពុង ឬមានបំណងប្រើប្រាស់សេវាកម្មពាក់ព័ន្ធនឹងពន្ធដារពីក្រុមហ៊ុនខាងលើ ត្រូវផ្អាកឬកុំប្រើប្រាស់សេវាកម្មពាក់ព័ន្ធនឹងក្រុមហ៊ុននេះ ដើម្បីចៀសវាងទទួលរងនូវការផាកពិន័យនឹងទណ្ឌកម្មផ្សេងៗ ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារជាធរមាន៕

សូមស្កេន QR Code ដើម្បីទទួលបានឯកសារ ឬអានលម្អិត

## សេចក្តីជូនដំណឹង ស្តីពីការលុបចោលអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដាររបស់ក្រុមហ៊ុន សំរិទ្ធិ អ៊ីខោនជីង អេន មេនេចម៉ិន ឯ.ក (នាមករណ៍បច្ចុប្បន្ន ស៊ី.អូ.អេស.ជី.វី ខេមរា អ៊ីខិនជីង ឯ.ក)

នាថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២៥ អគ្គនាយកដ្ឋានពន្ធដារបានចេញសេចក្តីជូនដំណឹងលេខ ៣៧៧៣១ អពដ ស្តីពីការលុបចោលអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដាររបស់ក្រុមហ៊ុន សំរិទ្ធិ អ៊ីខោនជីង អេន មេនេចម៉ិន ឯ.ក (នាមករណ៍បច្ចុប្បន្ន ស៊ី.អូ.អេស.ជី.វី ខេមរា អ៊ីខិនជីង ឯ.ក)។ ការចេញសេចក្តីជូនដំណឹងនេះ គឺដើម្បីជម្រាបជូនដំណឹងដល់អ្នកជាប់ពន្ធ ឬសាធារណជនទូទៅទាំងអស់ ឱ្យបានជ្រាបថា ក្រុមហ៊ុននេះ ត្រូវបានលុបអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ និងត្រូវបានបាត់បង់នីតិសម្បទាជាភ្នាក់ងារសេវាកម្មពន្ធដារ ដែលមិនអាចផ្តល់សេវាពាក់ព័ន្ធនឹងពន្ធដារជូនអតិថិជន ឬជូនអ្នកជាប់ពន្ធទៀតទេ គិតចាប់ពីកាលបរិច្ឆេទនៃការចេញលិខិតជូនដំណឹងនេះតទៅ។ ក្នុងន័យនេះ

អ្នកជាប់ពន្ធ ឬសាធារណជនទូទៅដែលកំពុង ឬមានបំណងប្រើប្រាស់សេវាកម្មពាក់ព័ន្ធនឹងពន្ធដារពីក្រុមហ៊ុនខាងលើ ត្រូវផ្អាកឬកុំប្រើប្រាស់សេវាកម្មពាក់ព័ន្ធនឹងក្រុមហ៊ុននេះ ដើម្បីចៀសវាងទទួលរងនូវការផាកពិន័យនឹងទណ្ឌកម្មផ្សេងៗ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ ជាធរមាន៕

សូមស្កេន QR Code ដើម្បីទទួលបានឯកសារ ឬអានលម្អិត

## សេចក្តីជូនដំណឹង ស្តីពីបញ្ជីឈ្មោះក្រុមហ៊ុនឬសហគ្រាស ដែលទទួលបានអាជ្ញាប័ណ្ណជាភ្នាក់ងារសេវាកម្មពន្ធដារ និងមានសុពលភាព

នាថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៥ អគ្គនាយកដ្ឋានពន្ធដារបានចេញសេចក្តីជូនដំណឹងលេខ ៣៨២១៧ អពដ ស្តីពីបញ្ជីឈ្មោះក្រុមហ៊ុនឬសហគ្រាសដែលទទួលបានអាជ្ញាប័ណ្ណជាភ្នាក់ងារសេវាកម្មពន្ធដារ និងមានសុពលភាព។ ការចេញសេចក្តីជូនដំណឹងនេះ គឺដើម្បីលោក-លោកស្រីដែលជាម្ចាស់សហគ្រាស ឬក្រុមហ៊ុនទាំងអស់ ជ្រាបថា អគ្គនាយកដ្ឋានពន្ធដារ បានផ្តល់ជូននូវបញ្ជីឈ្មោះក្រុមហ៊ុន ឬសហគ្រាសប្រកបអាជីវកម្មជាភ្នាក់ងារសេវាកម្មពន្ធដារ ដែលទទួលបានអាជ្ញាប័ណ្ណពីអគ្គនាយកដ្ឋានពន្ធដារ គិតត្រឹមថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៥ ដើម្បីជួយសម្រួលដល់លោក-លោកស្រី ដែលមានបំណងប្រើប្រាស់សេវាពាក់ព័ន្ធនឹងពន្ធដារ (បំពេញបែបបទពន្ធដារ ដាក់លិខិតប្រកាសពន្ធ បង់ប្រាក់ពន្ធប្រចាំខែ និងប្រចាំឆ្នាំជាដើម) ពីក្រុមហ៊ុនដែលទទួលបានអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារពីអគ្គនាយកដ្ឋានពន្ធដារ ចៀសវាងការប្រើប្រាស់សេវាពាក់ព័ន្ធនឹងពន្ធដារពីបុគ្គលដែលគ្មានអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ ដែលនាំឱ្យទទួលរងនូវការពិន័យ និងទោសទណ្ឌផ្សេងៗ៕

សូមស្កេន QR Code ដើម្បីទទួលបានឯកសារ ឬអានលម្អិត

## សេចក្តីជូនដំណឹង ស្តីពីការបើកបញ្ជរផ្តល់សេវាពន្ធដារជូនអ្នកជាប់ពន្ធនៅអគារអគ្គនាយកដ្ឋានពន្ធដារថ្មី (GDT Tower) របស់អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

នាថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៥ អគ្គនាយកដ្ឋានពន្ធដារបានចេញសេចក្តីជូនដំណឹងលេខ ៤០០៩៤ អពដ ស្តីពីការបើកបញ្ជរផ្តល់សេវាពន្ធដារជូនអ្នកជាប់ពន្ធនៅអគារអគ្គនាយកដ្ឋានពន្ធដារថ្មី (GDT Tower) របស់អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ការចេញសេចក្តីជូនដំណឹងនេះ គឺដើម្បីជម្រាបជូនដំណឹងដល់អ្នកជាប់ពន្ធ និងសាធារណជនទាំងអស់ ឱ្យបានជ្រាបថា អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងបើកបម្រើសេវាពន្ធដារជូនអ្នកជាប់ពន្ធ នៅទីតាំងអគារអគ្គនាយកដ្ឋានពន្ធដារថ្មី ដែលមានអាសយដ្ឋានស្ថិតនៅ អគារលេខ ៣៣៣ វិថីពន្ធដារ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៥ តទៅ៕

សូមស្កេន QR Code ដើម្បីទទួលបានឯកសារ ឬអានលម្អិត

## សេចក្តីជូនដំណឹង ស្តីពីការដាក់ឱ្យប្រើប្រាស់កម្មវិធីវិក្កយបត្រនាំសំណាង របស់អគ្គនាយកដ្ឋានពន្ធដារ តាមរយៈកម្មវិធីតេឡេក្រាម (GDT Lucky Draw Telegram Bot)

នាថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៥ អគ្គនាយកដ្ឋានពន្ធដារបានចេញសេចក្តីជូនដំណឹងលេខ ៤០២៧១ អពដ ស្តីពីការដាក់ឱ្យប្រើប្រាស់កម្មវិធីវិក្កយបត្រនាំសំណាងរបស់អគ្គនាយកដ្ឋានពន្ធដារ តាមរយៈកម្មវិធីតេឡេក្រាម (GDT Lucky Draw Telegram Bot)។ ការចេញសេចក្តីជូនដំណឹងនេះ គឺដើម្បីជម្រាបជូនដំណឹងដល់អ្នកជាប់ពន្ធ និងសាធារណជន ឱ្យបានជ្រាបថា កន្លងមកអគ្គនាយកដ្ឋានពន្ធដារធ្លាប់បានដាក់ឱ្យប្រើប្រាស់នូវកម្មវិធីវិក្កយបត្រនាំសំណាង ( GDT Lucky Draw App) សម្រាប់ឱ្យសាធារណជនអាចផ្ញើវិក្កយបត្រដែលបានមកពីការចំណាយផ្សេងៗ ដើម្បីជាការចូលរួមចំណែកក្នុងការប្រមូលចំណូលពន្ធដារ និងទទួលបានអត្ថប្រយោជន៍ជាច្រើនពីការចូលរួមនេះ។ បន្ថែមពីនេះ ក្នុងស្មារតី បុរេសកម្មនិងដើម្បីបន្តបង្កើនគុណភាពនិងប្រសិទ្ធភាពនៃយន្តការនេះឱ្យកាន់តែមានលក្ខណៈសាមញ្ញ និងលឿនរហ័សបន្ថែមមួយកម្រិតទៀត សម្រាប់សាធារណជនផ្ញើវិក្កយបត្រមកអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានពន្ធដារ បានអភិវឌ្ឍនិងដាក់ឱ្យប្រើប្រាស់នូវកម្មវិធីវិក្កយបត្រនាំសំណាង តាមរយៈកម្មវិធីតេឡេក្រាម (GDT Lucky Draw Telegram Bot) ដែលនឹងដំណើរការដោយប្រើប្រាស់បច្ចេកវិទ្យាបញ្ញាសិប្បនិមិត្ត (Artificial Intelligence-AI)។ ដើម្បីឱ្យការប្រើប្រាស់កម្មវិធីនេះប្រព្រឹត្តទៅដោយរលូន អគ្គនាយកដ្ឋានពន្ធដារក៏បានធ្វើការណែនាំអំពីការប្រើប្រាស់ជាជំហាននីមួយៗ យ៉ាងលម្អិតផងដែរ។

សូមស្កេន QR Code
ដើម្បីទទួលបានឯកសារ ឬអានលម្អិត

# ៤.សារាចរណែនាំ

## សារាចរណែនាំ ស្តីពីការលើកលែងកាតព្វកិច្ចពន្ធកាត់ទុក លើសួយសារ និងការប្រាក់ក្នុងចំណោមអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញសារាចរណែនាំលេខ ០២៤ សហវ.ស.រ.ណ. អពដ ស្តីពីការលើកលែងកាតព្វកិច្ចពន្ធកាត់ទុកលើសួយសារ និងការប្រាក់ ក្នុងចំណោមអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស។ គោលបំណង គឺដើម្បីជួយសម្រួលដល់យន្តការពន្ធកាត់ទុកក្នុងចំណោមអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស និងលើកកម្ពស់បរិយាកាសធុរកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធ្វើការណែនាំដូចខាងក្រោម៖

១. លើកលែងកាតព្វកិច្ចពន្ធកាត់ទុកលើសួយសារ និងការប្រាក់ រាល់ការទូទាត់ថ្លៃសួយសារ និងការប្រាក់ ក្នុងចំណោមអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដូចគ្នា។

២. សហគ្រាសជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដែលទទួលបានចំណូល ត្រូវកត់ត្រាជាចំណូលជាប់ពន្ធ និងប្រកាសបង់ពន្ធលើប្រាក់ចំណូល ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ ជាធរមាន។

៣. ការលើកលែងកាតព្វកិច្ចកាត់ទុកប្រាក់ពន្ធកាត់ទុកដូចក្នុងចំណុចទី១ខាងលើនេះ លុះត្រាតែចំនួនទឹកប្រាក់នោះត្រូវបានកត់ត្រាក្នុងវិក្កយបត្រស្របតាមវិធាននៃការប្រើប្រាស់វិក្កយបត្រជាធរមាន ដែលបានចេញយ៉ាងត្រឹមត្រូវដោយភាគីអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសម្ខាងទៀត។

សូមស្កេន QR Code
ដើម្បីទទួលបានឯកសារ ឬអានលម្អិត

# ផ្នែកទី៤

## កិច្ចសហប្រតិបត្តិការក្របខ័ណ្ឌជាតិ-អន្តរជាតិ

១. កិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័ន

២. កិច្ចសហប្រតិបត្តិការជាមួយវិស័យឯកជន អង្គការ សមាគម និងស្ថាប័នអន្តរជាតិ

៣. កិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា (Double Taxation Agreement-DTA)

៤. សកម្មភាពផ្សេងៗរបស់អគ្គនាយកដ្ឋានពន្ធដារ

# ១. កិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័ន

## លោក ជ័យ រិទ្ធី ដឹកនាំមន្ត្រីពាក់ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធដារ ចូលរួមកិច្ចប្រជុំក្រុមការងារសម្របសម្រួលអនុលោមភាពហិរញ្ញវត្ថុ របស់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាល



នាថ្ងៃព្រហស្បតិ៍ ទី២ ខែតុលា ឆ្នាំ២០២៥ នៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លោក **ជ័យ រិទ្ធី** ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម បានដឹកនាំមន្ត្រីពាក់ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធដារ ចូលរួមកិច្ចប្រជុំប្រចាំឆមាសរបស់ក្រុមការងារសម្របសម្រួលអនុលោមភាពហិរញ្ញវត្ថុរបស់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីពិនិត្យ និងពិភាក្សាលើការរៀបចំផែនការសកម្មភាពរបស់ក្រុមការងារ និងពិភាក្សាពាក់ព័ន្ធនឹងករណីអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលបានផុតសុពលភាពអនុស្សរណៈនៃការយោគយល់គ្នាជាមួយក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ។ កិច្ចប្រជុំនេះត្រូវបានរៀបចំឡើងក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត **ហ៊ែល ចំរើន** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានប្រចាំការក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមានការចូលរួមពីតំណាងអគ្គនាយកដ្ឋានថវិកា តំណាងអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល តំណាងអគ្គាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តំណាងលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម ព្រមទាំងតំណាងនិយ័តករបរធនបាលកិច្ច និងតំណាងនិយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ៕





# អគ្គនាយកដ្ឋានពន្ធដារ សហការជាមួយវេទិកាសម្ព័ន្ធសង្គមស៊ីវិល នៃទីស្តីការគណៈរដ្ឋមន្ត្រីរៀបចំសិក្ខាសាលាស្តីពី "ការអនុវត្តភាតព្វកិច្ចពន្ធដារ សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ"



ក្រោមកិច្ចសហការរវាងអគ្គនាយកដ្ឋានពន្ធដារ និងវេទិកាសម្ព័ន្ធសង្គមស៊ីវិល នៃទីស្តីការគណៈរដ្ឋមន្ត្រី នាថ្ងៃសុក្រ ទី២៤ ខែតុលា ឆ្នាំ២០២៥ នៅសាលទន្លេសាប អគារខេមរវិទូនៃរាជបណ្ឌិត្យសភាកម្ពុជា លោក **ជ័យ រិទ្ធី** ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានដឹកនាំមន្ត្រីពាក់ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធដារចូលរួមសិក្ខាសាលាស្តីពី "**ការអនុវត្តកាតព្វកិច្ចពន្ធដារសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ**" ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត **ម៉ៃ សំបូរ** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានវេទិកាសម្ព័ន្ធសង្គមស៊ីវិល នៃទីស្តីការគណៈរដ្ឋមន្ត្រី។ ក្នុងកម្មវិធីសិក្ខាសាលានេះ មន្ត្រីជំនាញនៃនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ និងនាយកដ្ឋានសវនកម្មសហគ្រាស បានធ្វើបទបង្ហាញ និងធ្វើជាវាគ្មិនក្នុងវេទិកាសំណួរ-ចម្លើយ ដែលមានការសួរសំណួរ និងពិភាក្សាយ៉ាងផុលផុស ពីតំណាងសមាគម អង្គការមិនមែនរដ្ឋាភិបាល សហគ្រាស និងនិស្សិតប្រមាណ **៧០ រូប**៕






# អគ្គនាយកដ្ឋានពន្ធដារ សហការជាមួយសមាគមសហព័ន្ធធុរកិច្ច វៀតណាម-កម្ពុជា (VCBA) រៀបចំសិក្ខាសាលាផ្សព្វផ្សាយស្ដីពី "បច្ចុប្បន្នភាពច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្ដីពីពន្ធដារ"




នាថ្ងៃសុក្រ ទី២៤ ខែតុលា ឆ្នាំ២០២៥ នៅសណ្ឋាគារកាំបូឌីយ៉ាណា អគ្គនាយកដ្ឋានពន្ធដារបានសហការជាមួយសមាគមសហព័ន្ធធុរកិច្ចវៀតណាម-កម្ពុជា (VCBA) រៀបចំសិក្ខាសាលាផ្សព្វផ្សាយស្ដីពី **"បច្ចុប្បន្នភាពច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្ដីពីពន្ធដារ"** ជូនដល់សមាជិកសមាគមសហព័ន្ធធុរកិច្ចវៀតណាម-កម្ពុជា ក្រោមអធិបតីភាពលោកបណ្ឌិត **អេង រតនា** ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ តំណាងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ឯកឧត្តម Ngo Van Tuat ឯកអគ្គរដ្ឋទូតវៀតណាមប្រចាំកម្ពុជា និងឧកញ៉ា **ឡេង ឫទ្ធី** ប្រធានសមាគមសហព័ន្ធធុរកិច្ចវៀតណាម-កម្ពុជា។ សិក្ខាសាលានេះ មានការចូលរួមពីថ្នាក់ដឹកនាំនិងមន្ត្រីជំនាញពាក់ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធដារ ថ្នាក់ដឹកនាំសមាគមសហព័ន្ធធុរកិច្ចវៀតណាម-កម្ពុជា ព្រមទាំងមានការចូលរួមពីអភិបាល បណ្ណាធិការ និងតំណាងក្រុមហ៊ុន ជាសមាជិកនៃសមាគមសហព័ន្ធធុរកិច្ចវៀតណាម-កម្ពុជា សរុបប្រមាណ **១២០ រូប**៕



# តំណាងអគ្គនាយកដ្ឋានពន្ធដារចូលរួមវេទិកាបង្ហាញសក្តានុពលអាជីវកម្ម និង ឧស្សាហកម្មគាំទ្រនៅកម្ពុជា លើកទី១ រៀបចំដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍




នាព្រឹកថ្ងៃព្រហស្បតិ៍ ទី២៧ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅសណ្ឋាគារ សេរីដង់ សុខាភ្នំពេញ លោក **ជ័យ រិទ្ធី** ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម តំណាងអគ្គនាយកដ្ឋានពន្ធដារ បានចូលរួមវេទិកាបង្ហាញសក្តានុពលអាជីវកម្ម និងឧស្សាហកម្មគាំទ្រលើកទី១ ក្រោមអធិបតីភាព ឯកឧត្តម **ហែម វណ្ណឌី** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ព្រមទាំងមានការចូលរួមពីតំណាងសមាគមឧកញ៉ាកម្ពុជា អ្នកដឹកនាំឧស្សាហកម្ម ក្រុមហ៊ុនពហុជាតិ សហគ្រាសផលិតក្នុងស្រុកដែលមានសក្តានុពល ដៃគូអភិវឌ្ឍន៍ និងអ្នករៀបចំគោលនយោបាយ ប្រមាណ **២៥០ រូប**។ វេទិកាបង្ហាញសក្តានុពលអាជីវកម្ម និងឧស្សាហកម្មគាំទ្រ លើកទី១ ផ្តោតលើសារៈសំខាន់នៃការកសាងខ្សែច្រវាក់ផលិតកម្មក្នុងស្រុកឱ្យកាន់តែរឹងមាំ និងលើកកម្ពស់សមត្ថភាពសហគ្រាសធុនតូចនិងមធ្យមក្នុងស្រុកឱ្យក្លាយជាកម្លាំងជំរុញបរិវត្តកម្មឧស្សាហកម្ម។ វេទិកានេះបានពិភាក្សាលើសសរស្តម្ភចំនួនបីគឺ ១.ការកំណត់យថាប្រភេទអាជីវកម្មកំពុងលូតលាស់ និងមានសក្តានុពលខ្ពស់ ២.ការបង្កើតខ្សែច្រវាក់តភ្ជាប់រវាងការផ្គត់ផ្គង់ និងតម្រូវការទាំងក្នុងស្រុក បង្គ្រប់ការនាំចូល ជំនួសការនាំចូល និងបង្កើនការនាំចេញ និង ៣.ការពង្រឹងបរិយាកាសអំណោយផលសម្រាប់សក្តានុពលអាជីវកម្ម និងឧស្សាហកម្មគាំទ្រនៅកម្ពុជា៕





# ឯកឧត្តមបណ្ឌិត កែន សម្បត្តិ ចូលរួមកិច្ចប្រជុំលើកទី៣ របស់គណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍ (គ.ជ.អ.ទ.)



នារសៀលថ្ងៃពុធ ទី៣ ខែធ្នូ ឆ្នាំ២០២៥ នៅសាលប្រជុំ A អគារមិត្តភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី ឯកឧត្តមបណ្ឌិត **កែន សម្បត្តិ** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានដឹកនាំមន្ត្រីជំនាញពាក់ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធដារ ចូលរួមកិច្ចប្រជុំលើកទី៣ របស់គណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍ ក្នុងអាណត្តិរាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ក្រោមអធិបតីភាព ឯកឧត្តម **ហួត ហាក់** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍ (គ.ជ.អ.ទ.)។ កិច្ចប្រជុំនេះត្រូវបានរៀបចំឡើងដើម្បីពិនិត្យ និងវាយតម្លៃវឌ្ឍនភាពការងារឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ របស់គណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍។ ជាលទ្ធផល អង្គប្រជុំបានវាយតម្លៃខ្ពស់ចំពោះវឌ្ឍនភាព និងលទ្ធផលការងារប្រកបដោយភាពវិជ្ជមានដែលសម្រេចបានក្នុងក្របខ័ណ្ឌនៃគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍ ក៏ដូចជាសមិទ្ធផលក្នុងការជំរុញសកម្មភាពទេសចរណ៍កម្ពុជាក្នុងរដូវកាលបែតងពីខែមិថុនា ដល់ខែតុលា ឆ្នាំ២០២៥ ដែលមានកំណើនភ្ញៀវទេសចរជាតិកើនឡើងគួរឱ្យកត់សម្គាល់៕





# លោក ជ័យ រិទ្ធី ដឹកនាំមន្ត្រីពាក់ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធដារ ចូលរួមកិច្ចប្រជុំពិភាក្សាលើការរៀបចំថ្នាលឌីជីថលចុះបញ្ជីសហគ្រាសធុនមីក្រូ តូច និងមធ្យម




នារសៀលថ្ងៃពុធ ទី៣ ខែធ្នូ ឆ្នាំ២០២៥ នៅសាលប្រជុំជាន់ទី១៧ អគារតេជោសែន នៃទីស្តីការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដោយមានការអនុញ្ញាតពី ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ លោក **ជ័យ រិទ្ធី** ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម បានដឹកនាំមន្ត្រីពាក់ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធដារ ចូលរួមកិច្ចប្រជុំពិភាក្សា ស្តីពីការរៀបចំថ្នាលឌីជីថលចុះបញ្ជីសហគ្រាសធុនមីក្រូ តូច និងមធ្យម ក្រោមអធិបតីភាព ឯកឧត្តម **ហែម វណ្ណឌី** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និង លោកជំទាវ **ចម និម្មល** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។ កិច្ចប្រជុំនេះ ត្រូវបានរៀបចំឡើងក្រោមកិច្ចសហប្រតិបត្តិការរួមគ្នារវាង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដើម្បីពិភាក្សារកដំណោះស្រាយជួយសម្រួលដល់ការចុះបញ្ជីរបស់សហគ្រាសធុនមីក្រូ តូច និងមធ្យម លើថ្នាលឌីជីថលរួមតែមួយ សំដៅផ្តល់លទ្ធភាពឱ្យសហគ្រាសធុនមីក្រូ តូច និងមធ្យម ចូលរួមបានកាន់តែពេញលេញក្នុងប្រព័ន្ធផ្លូវការគឺជាគន្លឹះនៃការពង្រឹង និងពង្រីកមូលដ្ឋានគ្រឹះនៃសេដ្ឋកិច្ចជាតិ៕





# ឯកឧត្តមបណ្ឌិត ម៉ិញ បានកុសល ចូលរួមកិច្ចប្រជុំលើកទី៣ របស់គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិ ប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ



នាព្រឹកថ្ងៃពុធ ទី២៤ ខែធ្នូ ឆ្នាំ២០២៥ នៅទីស្តីការក្រសួងយុត្តិធម៌ ឯកឧត្តមបណ្ឌិត **ម៉ិញ បានកុសល** អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ តំណាងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **គន់ ចិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានដឹកនាំមន្ត្រីជំនាញនៃអគ្គនាយកដ្ឋានពន្ធដារ ចូលរួមកិច្ចប្រជុំលើកទី៣របស់គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ (គ.ស.ហ.) ក្រោមអធិបតីភាព ឯកឧត្តម **កើត រិទ្ធ** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាប្រធាន គ.ស.ហ។ កិច្ចប្រជុំលើកទី៣ របស់ គ.ស.ហ. ត្រូវបានរៀបចំឡើងដើម្បីពិនិត្យ និងអនុម័តលើរបាយការណ៍វាយតម្លៃថ្នាក់ជាតិ ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មលើកទី២ ព្រមទាំងពិនិត្យ និងពិភាក្សាអំពីទិសដៅការងារបន្តរបស់កម្ពុជា។ ជាលទ្ធផល អង្គប្រជុំបានពិនិត្យ និងអនុម័តលើរបាយការណ៍ការវាយតម្លៃហានិភ័យថ្នាក់ជាតិ ស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម (National Risk Assessment - NRA) លើកទី២ ដែលឯកសារនេះនឹងក្លាយទៅជាមូលដ្ឋានសម្រាប់កម្ពុជារៀបចំយុទ្ធសាស្ត្រជាតិ ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដើម្បីដាក់ចេញនូវផែនការសកម្មភាពនានា សំដៅឆ្លើយតបទៅនឹងកម្រិតហានិភ័យដែលបានកំណត់។ ជាទិសដៅបន្ទាប់ អង្គប្រជុំបានសម្រេចដាក់ចេញនូវសកម្មភាពការងារត្រូវអនុវត្តបន្តមួយចំនួន រួមមាន៖ ១.ការរៀបចំសិក្ខាសាលាផ្សព្វផ្សាយជាសាធារណៈនូវរបាយការណ៍សង្ខេបវាយតម្លៃហានិភ័យថ្នាក់ជាតិ NRA លើកទី២នេះ ២.ការរៀបចំយុទ្ធសាស្ត្រជាតិ ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និង ៣.ការត្រៀមលក្ខណៈក្នុងការទទួលការវាយតម្លៃអញ្ញមញ្ញនាពេលខាងមុខ៕

# ២. កិច្ចសហប្រតិបត្តិការជាមួយវិស័យឯកជន អង្គការ សមាគម និងស្ថាប័នអន្តរជាតិ

## ការចូលរួមកិច្ចប្រជុំពេញអង្គ លើកទី៣ នៃគណៈកម្មាធិការអ្នកជំនាញស្តីពីកិច្ចសហប្រតិបត្តិការអន្តរជាតិលើបញ្ហាពន្ធដារ




ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ នាថ្ងៃចន្ទ ទី២០ ដល់ថ្ងៃសុក្រ ទី២៤ ខែតុលា ឆ្នាំ២០២៥ លោកជំទាវ **ម៉ុន នារី** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ ក្នុងនាមជាសមាជិកគណៈកម្មាធិការអ្នកជំនាញទទួលបន្ទុកកិច្ចសហ-ប្រតិបត្តិការអន្តរជាតិលើបញ្ហាពន្ធដាររបស់អង្គការសហប្រជាជាតិ (Committee of Experts on International Tax Cooperation in Tax Matters-Committee of Experts) អមដោយមន្ត្រីជំនាញនៃអគ្គនាយកដ្ឋានពន្ធដារ បានចូលរួមកិច្ចប្រជុំពេញអង្គ លើកទី៣១ (31st Session) នៃគណៈកម្មាធិការអ្នកជំនាញស្តីពីកិច្ចសហប្រតិបត្តិការអន្តរជាតិលើបញ្ហាពន្ធដារ (Committee of Experts) ដែលបានប្រព្រឹត្តទៅនៅការិយាល័យអង្គការសហប្រជាជាតិ (អ.ស.ប) ប្រចាំទីក្រុង Geneva សហព័ន្ធស្វីស។ អគ្គនាយកដ្ឋានពន្ធដារសូមជម្រាបជូនដែរថា លោកជំទាវ **ម៉ុន នារី** ត្រូវបានជ្រើសរើសដោយអគ្គលេខាធិការ អ.ស.ប ជាអ្នកជំនាញនៃគណៈកម្មាធិការ (Committee of Experts) សម្រាប់ទ្វីបអាស៊ីក្នុងអាណត្តិ ២០២៥-២០២៩ ដើម្បីជំនួសសមាសភាពដែលត្រូវចប់អាណត្តិ កាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥ កន្លងទៅ។ Committee of Experts សម្រាប់អាណត្តិថ្មីនេះ មានបេក្ខភាពមកពីរដ្ឋសមាជិក ចំនួន ២៥ រួមមាន៖ កម្ពុជា, កេនយ៉ា, ចិន, ដូមីនីក, ន័រវែស, នីហ្សេរីយ៉ា, បារាំង, បែលហ្ស៊ិក, ប្រេស៊ីល, ម៉ាល់ឌីវ, ម៉ិចស៊ិក, វ៉ាន់ដា, រុស្ស៊ី, លីបេរីយ៉ា, លីទុយអានី, សិង្ហបុរី, សៀរ៉ាឡេអូន, សំប៊ី, ស្វីស, ហ្សាម៉ាអ៊ីក, អ៊ុយរូហ្គាយ, អូស្ត្រាលី, អៀរឡង់, អេស្ប៉ាញ និងឥណ្ឌា។ Committee of Experts ដើរតួនាទីទាក់ទិននឹងការងាររៀបចំបទដ្ឋាននិងគោលនយោបាយ និងការដាក់ចេញនូវមគ្គុទ្ទេសក៍សម្រាប់ការអនុវត្តជាក់ស្តែងពាក់ព័ន្ធនឹងពន្ធដារអន្តរជាតិ ក្នុងគោលដៅពង្រឹងកិច្ចសហប្រតិបត្តិការពន្ធដារអន្តរជាតិ គាំទ្រដល់ការអភិវឌ្ឍប្រព័ន្ធពន្ធដារប្រកបដោយចីរភាព គាំទ្រការបង្ការការគេចវេះពន្ធ និងការចៀសវាងពន្ធ

និងផ្តល់អនុសាសន៍ក្នុងការកសាងសមត្ថភាពគាំទ្រដល់រដ្ឋបាលសារពើពន្ធ ដោយផ្តល់ប្រយោជន៍ដល់ប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសប្រទេសអភិវឌ្ឍន៍តិចតួច និងប្រទេសដទៃទៀត ក្នុងស្ថានភាពពិសេស រួមទាំងរដ្ឋកោះតូចៗ និងប្រទេសគ្មានព្រំដែនទឹក (Landlocked Countries)។ តាមរបៀបវារៈដែលបានគ្រោងទុក អង្គប្រជុំបានបោះឆ្នោតជ្រើសរើសប្រធានឬសហប្រធាន និងអនុប្រធាននៃគណៈកម្មាធិការ សម្រាប់អាណត្តិ ២០២៥-២០២៩ នេះ ជាលទ្ធផល លោក **Mathew Olusanya Gbonjubola** សមាជិក នៃ Institute of Chartered Accountants នៃប្រទេសនីហ្សេរីយ៉ា និងលោកស្រី **Trude Steinnes Sønvisen** ទីប្រឹក្សាច្បាប់នៃក្រសួងហិរញ្ញវត្ថុ នៃប្រទេសន័រវែស ត្រូវបានជ្រើសរើសជាសហប្រធានគណៈកម្មាធិការ អមដោយអនុប្រធានមួយចំនួន តាមការចាំបាច់។ បន្ថែមពីនេះ អង្គប្រជុំក៏បានពិភាក្សា និងបានឯកភាពគ្នាលើរបៀបវារៈ ដើម្បីបន្តការងារទាក់ទិននឹងកិច្ចសហប្រតិបត្តិការពន្ធដារអន្តរជាតិ ដូចជា៖ ១.គំរូកិច្ចព្រមព្រៀង DTA របស់ អ.ស.ប (UN Model), ២.ការធ្វើបច្ចុប្បន្នភាពលើសៀវភៅណែនាំរបស់ អ.ស.ប សម្រាប់ការចរចាសន្ធិសញ្ញាពន្ធទ្វេភាគីដោយប្រទេសកំពុងអភិវឌ្ឍន៍, ៣.ឧស្សាហកម្មធនធានរ៉ែ ៤.សេដ្ឋកិច្ចឌីជីថល និងសកលភាវូបនីយកម្ម ៥.ការផ្ទេរថ្លៃ ៦.រដ្ឋបាលសារពើពន្ធ និងបញ្ញាសិប្បនិម្មិត ៧.អាករលើតម្លៃបន្ថែម ៨.ការចៀសវាងនិងការដោះស្រាយបណ្តឹងតវ៉ា ៩.ការយកពន្ធពាក់ព័ន្ធនឹងបរិស្ថាន ១០.ការយកពន្ធលើទ្រព្យសម្បត្តិ ១១.ពន្ធនិងយេនឌ័រ និង ១២.ការយកពន្ធលើទ្រព្យឌីជីថល (Crypto-assets)៕






# អគ្គនាយកដ្ឋានពន្ធដារសហការជាមួយអង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា រៀបចំសិក្ខាសាលាផ្សព្វផ្សាយពីកាតព្វកិច្ចសារពើពន្ធដល់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល



នាព្រឹកថ្ងៃពុធ ទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៥ អគ្គនាយកដ្ឋានពន្ធដារ បានសហការជាមួយអង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក) រៀបចំសិក្ខាសាលាស្ដីពី **"កាតព្វកិច្ច និងនីតិវិធីក្នុងការធ្វើបច្ចុប្បន្នភាពពន្ធដារស្របតាមច្បាប់ស្ដីពីសារពើពន្ធ សម្រាប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល"** ក្រោមអធិបតីភាពរបស់ឯកឧត្តមបណ្ឌិត **កែន សម្បត្តិ** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ អមដោយលោក **ជ័យ រិទ្ធី** ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម និងលោកស្រី **ស៊ិន ពុទ្ធារី** នាយិកាប្រតិបត្តិនៃអង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា ដោយមានការចូលរួមពីមន្ត្រីរាជការពន្ធដារពាក់ព័ន្ធ ព្រមទាំងតំណាងសមាគម និងអង្គការមិនមែនរដ្ឋាភិបាលសរុបចំនួន **២៤២ រូប**។ សិក្ខាសាលានេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងបញ្ជ្រាបបន្ថែមនូវការយល់ដឹងអំពីច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្ដីពីពន្ធដារ សំដៅពង្រឹងអនុលោមភាពសារពើពន្ធ និងលើកកម្ពស់វប្បធម៌បង់ពន្ធ ជាពិសេសដើម្បីឆ្លើយតបនឹងចម្ងល់ ឬសំណួរនានាពាក់ព័ន្ធនឹងពន្ធដាររបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល។ ក្នុងកម្មវិធីសិក្ខាសាលាមានការធ្វើបទបង្ហាញពីមន្ត្រីជំនាញនៃអគ្គនាយកដ្ឋានពន្ធដារ ដោយផ្ដោតលើប្រធានបទខាងលើ និងបានគូសរំលេចនូវចំណុចសំខាន់ចំនួនប្រាំរួមមាន ១.ទិដ្ឋភាពទូទៅ ២.កាតព្វកិច្ចសារពើពន្ធ ៣.ពន្ធកាត់ទុកទូទៅ ៤.ពន្ធលើប្រាក់បៀវត្ស និង៥.កាតព្វកិច្ចសារពើពន្ធផ្សេងៗទៀត៕






# តំណាងអគ្គនាយកដ្ឋានពន្ធដារ ជួបពិភាក្សាការងារជាមួយតំណាងស្ថានទូតសហព័ន្ធរុស្ស៊ីប្រចាំកម្ពុជា ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការផ្នែកពន្ធដារ



នាព្រឹកថ្ងៃអង្គារ ទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅអគ្គនាយកដ្ឋានពន្ធដារ លោក **ជ័យ រិទ្ធី** ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានជួបពិភាក្សាការងារជាមួយតំណាងស្ថានទូតសហព័ន្ធរុស្ស៊ីប្រចាំកម្ពុជា រួមមាន លោក Ivan Dubinkin លេខាទី១ និង កញ្ញា Sofia Oborskaia លេខាទី៣ នៃស្ថានទូតសហព័ន្ធរុស្ស៊ីប្រចាំកម្ពុជា។ ប្រធានបទដែលបានលើកយកមកពិភាក្សានាវេលានេះមាន ១.ការពង្រឹងកិច្ចសហប្រតិបត្តិការផ្នែកពន្ធដារ ២.យន្តការនៃការបង្វិលសងអាករលើតម្លៃបន្ថែមលើការទិញទំនិញ និងសេវារបស់ស្ថានទូត និង៣.កិច្ចការផ្នែកពន្ធដារផ្សេងៗទៀត៕



# អគ្គនាយកដ្ឋានពន្ធដាររៀបចំសិក្ខាសាលាស្តីពី "កាតព្វកិច្ចពន្ធលើប្រាក់ចំណូល" ជូនដល់សមាជិកសមាគម TAFTAC ដើម្បីត្រៀមលក្ខណៈបំពេញកាតព្វកិច្ច នាពេលដ៏ខ្លីខាងមុខ



ក្នុងគោលបំណងពង្រឹងអនុលោមភាពសារពើពន្ធដោយស្ម័គ្រចិត្ត តាមរយៈការបញ្ជ្រាបការយល់ដឹងអំពីកាតព្វកិច្ចសារពើពន្ធ បច្ចុប្បន្នភាពច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារដល់អ្នកជាប់ពន្ធ ពិសេសត្រៀមលក្ខណៈក្នុងការបំពេញកាតព្វកិច្ច ពន្ធលើប្រាក់ចំណូល ដែលនឹងឈានចូលមកដល់នាពេលដ៏ខ្លីខាងមុខ អគ្គនាយកដ្ឋានពន្ធដារ បានសហការជាមួយសមាគមវាយនភណ្ឌ សម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរនៅកម្ពុជា (TAFTAC) រៀបចំសិក្ខាសាលាស្តីពី "**កាតព្វកិច្ចពន្ធលើប្រាក់ចំណូល និងការបំពេញលិខិតប្រកាសពន្ធលើប្រាក់ចំណូល**" ក្រោមអធិបតីភាព លោកបណ្ឌិត **អេង រតនា** ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ និង លោក Enjoy Ho អនុប្រធានសមាគម TAFTAC។ ក្នុងកម្មវិធីសិក្ខាសាលានេះ មានការធ្វើបទបង្ហាញពីមន្ត្រីជំនាញនៃអគ្គនាយកដ្ឋានពន្ធដារ និងវេទិកាពិភាក្សាដែលមានការចូលរួមដោយផ្ទាល់ពីថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋានពន្ធដារ និងមានការលើកឡើងជាសំណួរយ៉ាងផុលផុសពីអភិបាល បណ្ណាធិការ ព្រមទាំងតំណាងសហគ្រាសសមាជិក TAFTAC សរុប **១៨៥ រូប**៕



# អគ្គនាយកដ្ឋានពន្ធដារ និងសមាគមពាណិជ្ជកម្មកម្ពុជា-ជប៉ុន រៀបចំកិច្ចប្រជុំពិភាក្សាដើម្បីផ្តល់ការគាំទ្របច្ចេកទេសពាក់ព័ន្ធនឹងពន្ធដារជូនសហគ្រាសជប៉ុន



នាព្រឹកថ្ងៃពុធ ទី៣ ខែធ្នូ ឆ្នាំ២០២៥ នៅបន្ទប់ប្រជុំបន្ទាយស្រីនៃអគ្គនាយកដ្ឋានពន្ធដារ មានរៀបចំកិច្ចប្រជុំពិភាក្សាលើករណីស្នើសុំកិច្ចគាំទ្របច្ចេកទេសពាក់ព័ន្ធនឹងពន្ធដារជូនសហគ្រាសជប៉ុន ក្រោមអធិបតីភាព លោកជំទាវ **ម៉ុន នារី** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ តំណាងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ និងលោក KAWAHARA Ryo ប្រធានគណៈកម្មាធិការពន្ធដារនៃសមាគមពាណិជ្ជកម្មកម្ពុជា-ជប៉ុន។ ក្នុងកិច្ចប្រជុំនេះមានការចូលរួមពីថ្នាក់ដឹកនាំនិងមន្ត្រីជំនាញពាក់ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធដារ តំណាងស្ថានទូតជប៉ុនប្រចាំកម្ពុជា និងសមាជិកសមាគមពាណិជ្ជកម្មកម្ពុជា-ជប៉ុន ព្រមទាំងភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុនប្រចាំកម្ពុជា ក្នុងគោលដៅធ្វើការឆ្លើយតប និងដោះស្រាយនូវបញ្ហាប្រឈម ក៏ដូចជាសំណូមពររបស់សហគ្រាសជប៉ុនក្នុងការអនុវត្តគម្រោងក្រោមក្របខ័ណ្ឌជំនួយអភិវឌ្ឍន៍ផ្លូវការ ( ODA )៕



# ឯកឧត្តមបណ្ឌិត កែន សម្បត្តិ ទទួលជួបក្រុមការងារបច្ចេកទេសនៃធនាគារពិភពលោក ទទួលបន្ទុកអនុវត្តកម្មវិធី "ទីក្រុងគួរឱ្យចង់រស់នៅ (Cambodia Livable Cities Program)"




នារសៀលថ្ងៃអង្គារ ទី៩ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **កែន សម្បត្តិ** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ បានទទួលជួបពិភាក្សាការងារជាមួយក្រុមការងារបច្ចេកទេសនៃធនាគារពិភពលោកទទួលបន្ទុកអនុវត្តកម្មវិធី "**ទីក្រុងគួរឱ្យចង់រស់នៅ** (Cambodia Livable Cities Program)" ដឹកនាំដោយ លោក Stamatis Kotouzas ទីប្រឹក្សាបច្ចេកទេស។ កិច្ចប្រជុំនេះ មានការចូលរួមពីតំណាងនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ នាយកដ្ឋានពន្ធចលនទ្រព្យ និងអចលនទ្រព្យ និងនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន៕



# កម្មវិធីជួបជាមួយសមាគមសហព័ន្ធភ្នាក់ងារសេវាកម្មពន្ធដារកម្ពុជា ដើម្បីសម្តែងការគួរសម និងគោរពស្នើសុំការគាំទ្រលើសកម្មភាពចែករំលែកព័ត៌មានពន្ធដារជូនចំពោះធុរកិច្ចជនជាអ្នកជាប់ពន្ធ



តាមការចាត់តាំងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **គន់ ទិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃព្រហស្បតិ៍ ទី១១ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **លឹម ហ៊ុយជីវ** ទីប្រឹក្សាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទទួលបន្ទុកជួយការងារពន្ធដារ បានដឹកនាំកិច្ចជំនួបពិភាក្សាការងារជាមួយគណៈប្រតិភូ នៃសមាគមសហព័ន្ធភ្នាក់ងារសេវាកម្មពន្ធដារកម្ពុជា តំណាងដោយ ឯកឧត្តម **អ៊ុំ សារ៉ាឌុធ** ប្រធានសមាគមសហព័ន្ធភ្នាក់ងារសេវាកម្មពន្ធដារកម្ពុជា ដោយមានការចូលរួមពីថ្នាក់ដឹកនាំនិងមន្ត្រីពាក់ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធដារ។ ការរៀបចំកម្មវិធីជំនួបរវាងអគ្គនាយកដ្ឋានពន្ធដារជាមួយនិងសមាគមសហព័ន្ធភ្នាក់ងារសេវាកម្មពន្ធដារកម្ពុជា ត្រូវបានធ្វើឡើងតបតាមការស្នើសុំរបស់សមាគមសហព័ន្ធភ្នាក់ងារសេវាកម្មពន្ធដារកម្ពុជា ដែលមានគោលបំណងគោរពស្នើសុំការគាំទ្រពីអគ្គ-នាយកដ្ឋានពន្ធដារ លើការចែករំលែកព័ត៌មានពន្ធដារជូនចំពោះធុរកិច្ចជនជាអ្នកជាប់ពន្ធ សម្រាប់ជាការរួមចំណែកជួយផ្សព្វផ្សាយ បញ្ជ្រាប និងលើកស្ទួយវប្បធម៌បង់ពន្ធនៅក្នុងសង្គមកម្ពុជាជាពិសេសក្នុងចំណោមភ្នាក់ងារសេវាកម្មពន្ធដារ ដើម្បីសម្រេចបាននូវទស្សនវិស័យ បេសកកម្ម គោលបំណង និងសកម្មភាពល្អៗ របស់សមាគមសហព័ន្ធភ្នាក់ងារសេវាកម្មពន្ធដារកម្ពុជា៕






# អគ្គនាយកដ្ឋានពន្ធដាររៀបចំវគ្គបណ្តុះបណ្តាល ស្តីពីប្រព័ន្ធ e-Filing និងការបង្វិលសងអាករលើតម្លៃបន្ថែម ជូនគណៈប្រតិភូកុងស៊ុលកិត្តិយស នៃបណ្តាប្រទេសអឺរ៉ុបមួយចំនួនប្រចាំនៅកម្ពុជា



នាព្រឹកថ្ងៃព្រហស្បតិ៍ ទី១៨ ខែធ្នូ ឆ្នាំ២០២៥ នៅអគ្គនាយកដ្ឋានពន្ធដារ មានរៀបចំកម្មវិធីបណ្តុះបណ្តាល ស្តីពីប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មតាមអនឡាញ (e-Filing System) និងការបង្វិលសងអាករលើតម្លៃបន្ថែម (VAT Refund) ជូនគណៈប្រតិភូកុងស៊ុលកិត្តិយសនៃបណ្តាប្រទេសអឺរ៉ុបមួយចំនួនប្រចាំនៅកម្ពុជា ក្រោមអធិបតីភាព លោក **ជ័យ រិទ្ធី** ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម និង ឯកឧត្តម Salah Essa កុងស៊ុលកិត្តិយសនៃសាធារណរដ្ឋស៊ីប (Cyprus) ប្រចាំនៅកម្ពុជា។ វគ្គបណ្តុះបណ្តាលនេះមានការចូលរួមពីតំណាងកុងស៊ុលកិត្តិយសនៃប្រទេសរ៉ូម៉ានី ដាណឺម៉ាក ស៊ុយអែត អេស្ប៉ាញ ហូឡង់ និងប៉ូឡូញ ព្រមទាំងតំណាងនាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ នាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន និងនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម៕





# ៣. កិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា (Double Taxation Agreement-DTA)

**កិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា** - Double Taxation Agreement (DTA) គឺជាកិច្ចព្រមព្រៀងរវាងប្រទេសពីរឬច្រើន ដើម្បីចៀសវាងការទូទាត់ពន្ធទ្វេដង លើប្រាក់ចំណូល ឬទ្រព្យសម្បត្តិ។ កិច្ចព្រមព្រៀងនេះមានគោលបំណងជួយឱ្យអ្នកជាប់ពន្ធមិនត្រូវបង់ពន្ធលើប្រាក់ចំណូលដដែលម្តងទៀតនៅប្រទេសផ្សេងទៀត។

អត្ថប្រយោជន៍ក្រោមកិច្ចព្រមព្រៀង DTA នឹងត្រូវអនុវត្តសម្រាប់រយៈពេលមួយឆ្នាំពេញ សម្រាប់ករណីស្នើសុំដែលទទួលបានការអនុញ្ញាតពីអគ្គនាយកដ្ឋានពន្ធដារ។ អ្នកជាប់ពន្ធត្រូវដាក់ពាក្យស្នើសុំ និងអនុវត្តតាមច្បាប់ពន្ធដារជាធរមានមុនពេលទទួលបានអត្ថប្រយោជន៍នេះ។ វឌ្ឍនភាពនៃកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា (DTA) គិតត្រឹមឆ្នាំ២០២៥ មានបង្ហាញដូចតារាងខាងក្រោម៖

**ប្រទេសដែលមានប្រសិទ្ធភាពអនុវត្ត ចំនួន ១១**

| | | | | | |
|---|---|---|---|---|---|
| សិង្ហបុរី | ថៃ | ព្រុយណេ | ចិន | វៀតណាម | តំបន់រដ្ឋបាលពិសេសហុងកុង |
| ឥណ្ឌូណេស៊ី | ម៉ាឡេស៊ី | សាធារណរដ្ឋកូរ៉េ | តំបន់រដ្ឋបាលពិសេសម៉ាកាវ | តួកគី | |

**ប្រទេសដែលបាន "ចុះហត្ថលេខា" ចំនួន ២៖**

| | |
|---|---|
| ឡាវ | បានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/១២២៥/០៣៨ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៥ និងកំពុងជូនដំណឹងតាមផ្លូវទូតទៅភាគីឡាវ |
| ហ្វីលីពីន | បានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/១២២៥/០៣៨ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៥ និងកំពុងជូនដំណឹងតាមផ្លូវទូតទៅភាគីហ្វីលីពីន |

**ប្រទេសដែលបាន "ចុះហត្ថលេខា លើពិធីសារបន្ថែម" ចំនួន ១៖**

| | |
|---|---|
| សិង្ហបុរី | ពិធីសារទី២ ដើម្បីធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃសាធារណរដ្ឋសិង្ហបុរី ស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគេចវេសបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២២៥/០៣៨ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៥ និងកំពុងជូនដំណឹងតាមផ្លូវទូតទៅភាគីសិង្ហបុរី |

**ប្រទេសដែលបាន "បញ្ចប់ការចរចា" ចំនួន ២៖**

| | |
|---|---|
| មីយ៉ាន់ម៉ា | បានបញ្ចប់ការចរចា DTA និងកំពុងរៀបចំសម្រាប់ការត្រៀមចុះហត្ថលេខា |
| បារាំង | បានបញ្ចប់ការចរចា DTA និងកំពុងរៀបចំសម្រាប់ការត្រៀមចុះហត្ថលេខា |

**ប្រទេសដែល "កំពុងចរចា" ចំនួន ៥ ៖**

| | | | | |
|---|---|---|---|---|
| អេមីរ៉ាតអារ៉ាប់រួម (UAE) | ជប៉ុន | ម៉ារ៉ុក | កាតា | អាស៊ែបៃហ្សង់ |

# ៤. សកម្មភាពផ្សេងៗរបស់អគ្គនាយកដ្ឋានពន្ធដារ

## គណៈប្រតិភូអគ្គនាយកដ្ឋានពន្ធដារចូលរួមវេទិកា "EDUtech Asia 2025 លើកទី១០" ដើម្បីដកស្រង់បទពិសោធ និងឧត្តមានុវត្តន៍អន្តរជាតិថ្មីៗ សម្រាប់អភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលរបស់អគ្គនាយកដ្ឋានពន្ធដារ




នាថ្ងៃពុធ ទី៥ ដល់ថ្ងៃព្រហស្បតិ៍ ទី៦ ខែវិច្ឆិកា ឆ្នាំ២០២៥ លោក **ហ៊ឹម ម៉ិនធឿន** ប្រធាននាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក និងលោក **ស៊ុន ឧត្តី** នាយកសាលាជាតិពន្ធដារ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពីឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានដឹកនាំ គណៈប្រតិភូនៃអគ្គនាយកដ្ឋានពន្ធដារ ទៅចូលរួមវេទិកាស្តីពី "EDUtech Asia 2025 លើកទី១០" រៀបចំដោយក្រុមហ៊ុន Terrapinn Holdings Ltd. នៅ Sands Expo & Convention Centre សាធារណរដ្ឋសិង្ហបុរី។

ការផ្តល់ឱកាសឱ្យចូលរួមវេទិកានេះ គឺជាគំនិតផ្តួចផ្តើមប្រកបដោយទស្សនវិស័យដ៏វែងឆ្ងាយក្នុងការវិនិយោគលើការអភិវឌ្ឍ និងបណ្តុះបណ្តាលភាពជាអ្នកដឹកនាំ និងជំនាញទន់បន្ថែមទៀតដល់មន្ត្រីពន្ធដារ ព្រមទាំងជាឱកាសមួយសម្រាប់ទទួលបានចំណេះដឹង បទពិសោធ និងឧត្តមានុវត្តន៍អន្តរជាតិថ្មីៗ ដើម្បីកែលម្អកម្មវិធីបណ្តុះបណ្តាលរបស់អគ្គនាយកដ្ឋានពន្ធដារឱ្យបានកាន់តែល្អប្រសើរឡើងថែមមួយកម្រិតទៀត។

វេទិកាស្តីពី "**EDUtech Asia 2025 លើកទី១០**" ជាវេទិកាដ៏ធំនិងសំខាន់ជាងគេក្នុងវិស័យអប់រំដែលបង្ហាញពីបច្ចេកវិទ្យាជឿនលឿនសម្រាប់វិស័យអប់រំ និងការបណ្តុះបណ្តាលធំជាងគេនៅក្នុងតំបន់អាស៊ី មានការចូលរួមពីតំណាងសាលារៀនគ្រប់កម្រិតថ្នាក់ (Pre-school, K-12 Schools, & Higher Education Institutions) មន្ត្រីរាជការតាមក្រសួង-ស្ថាប័ននៃបណ្តាប្រទេសនានា អ្នកជំនាញល្បីៗ (Leading Experts) សាស្ត្រាចារ្យ អ្នកវិទ្យាសាស្ត្រ (Technology Innovators) និងសាធារណជនចូលរួមជាច្រើនកុះករ។ ការចូលរួមវេទិកានេះ បានផ្តល់ការឈ្វេងយល់ ព្រមទាំងចំណេះដឹងសំខាន់ៗអំពីនវានុវត្តន៍នៃការអភិវឌ្ឍធនធានមនុស្ស ក្នុងយុគសម័យបដិវត្តន៍ឧស្សាហកម្ម ៥.០ ដូចខាងក្រោម៖

១. អំពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងបច្ចេកទេសក្នុងការបណ្តុះបណ្តាលកាន់តែល្អប្រសើរឡើង

២. ការបង្ហាញបច្ចេកវិទ្យាព័ត៌មាន ដូចជា AI, Robotics, VR, AR ដែលអាចដាក់បញ្ចូលកម្មវិធី ឬដំណើរការបណ្តុះបណ្តាល ឬការបង្រៀន

៣. បណ្តាញទំនាក់ទំនង និងភាពជាដៃគូរវាងសាលារៀន សាកលវិទ្យាល័យ រាជរដ្ឋាភិបាល វិស័យឯកជន និងអ្នកផ្គត់ផ្គង់បច្ចេកវិទ្យា៕

# Williams College សហរដ្ឋអាមេរិក បានធ្វើបទបង្ហាញស្តីពី "របៀបដាក់ពាក្យស្នើសុំអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាញគោលនយោបាយសេដ្ឋកិច្ច សម្រាប់ឆ្នាំសិក្សា២០២៦-២០២៧" ជូនមន្ត្រីរាជការនៃអគ្គនាយកដ្ឋានពន្ធដារ



នាព្រឹកថ្ងៃព្រហស្បតិ៍ ទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅអគ្គនាយកដ្ឋានពន្ធដារ មានរៀបចំការធ្វើបទបង្ហាញរបស់ Williams College សហរដ្ឋអាមេរិក ស្តីពី **"របៀបដាក់ពាក្យស្នើសុំអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាញគោលនយោបាយសេដ្ឋកិច្ច សម្រាប់ឆ្នាំសិក្សា២០២៦-២០២៧"** ដោយលោក Thomas S. Powers នាយកសាលា Center for Development Economics នៃ Williams College ជូនមន្ត្រីរាជការនៃអគ្គនាយកដ្ឋានពន្ធដារ ក្រោមអធិបតីភាព ឯកឧត្តម **លឹម ហ៊ុយឌីទ (លឹម គុណ)** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងមានការចូលរួមដោយផ្ទាល់ និងតាមប្រព័ន្ធអនឡាញពីមន្ត្រីរាជការនៃអគ្គនាយកដ្ឋានពន្ធដារ សរុបចំនួន **៧០ រូប**។ Williams College គឺជាគ្រឹះស្ថានឧត្តមសិក្សាចំណាស់ជាងគេទី២ បន្ទាប់ពីសាកលវិទ្យាល័យ Harvard និងមានភាពល្បីល្បាញខ្លាំងលើគុណភាពអប់រំក្នុងបរិយាកាសសិក្សាដ៏តឹងរ៉ឹង និងការបណ្តុះបណ្តាលនិស្សិតឱ្យក្លាយជាអ្នកដឹកនាំ និងអ្នកជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍នាពេលអនាគត។ ចាប់តាំងពីឆ្នាំ២០០៣ មក William College បានបណ្តុះបណ្តាលមន្ត្រីរាជការកម្ពុជាសម្រាប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាញគោលនយោបាយសេដ្ឋកិច្ច ចំនួនសរុប **២៥ រូប** រួចមកហើយ ដែលក្នុងនោះក៏មានមន្ត្រីរាជការនៃអគ្គនាយកដ្ឋានពន្ធដារផងដែរ។ ចំពោះ កម្មវិធីអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាញគោលនយោបាយសេដ្ឋកិច្ច (Master in Policy Economics) របស់ Center for Development Economics (CDE) នៃ Williams College មកជាកម្មវិធីដ៏ល្បីល្បាញមួយដែលមានរយៈពេលខ្លីត្រឹមតែ ១០ខែ និងត្រូវបានរៀបចំឡើងជាពិសេសសម្រាប់បណ្តុះបណ្តាលមន្ត្រីរាជការសាធារណៈ និងអ្នកជំនាញផ្នែកសេដ្ឋកិច្ច ដែលមានសក្តានុពលខ្ពស់មកពីប្រទេសកំពុងអភិវឌ្ឍន៍៕

# ក្រុមការងារចម្រុះតែមប្រ៊ីចុះត្រួតពិនិត្យអនុលោមភាពនៅតាមបណ្តាអាជីវកម្មដ្ឋានដែលសង្ស័យថាមានចែកចាយបារីខុសច្បាប់ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ ខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ



ដោយមានការសម្របសម្រួលពីតំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ និងតំណាងអយ្យការអមសាលាដំបូងខេត្តព្រះសីហនុ ព្រមទាំងកិច្ចសហការពីកងកម្លាំងមានសមត្ថកិច្ចចម្រុះ នាថ្ងៃព្រហស្បតិ៍ ទី២៧ ខែវិច្ឆិកា និងថ្ងៃសៅរ៍ ទី១៣ ខែធ្នូ ឆ្នាំ២០២៥ ក្រុមការងារចម្រុះដើម្បីត្រួតពិនិត្យកាតព្វកិច្ចបិទតែមប្រ៊ីអាករសម្រាប់បារី (ក្រុមការងារចម្រុះតែមប្រ៊ី) ដឹកនាំដោយ លោក **ម៉ឹង សុខឡៅ** អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ នៃអគ្គនាយកដ្ឋានពន្ធដារ និងជាអនុប្រធានក្រុមការងារចម្រុះតែមប្រ៊ី និងលោក **ហ៊ុល ម៉ុនថា** អនុប្រធាននាយកដ្ឋានបង្ការនិងបង្ក្រាបបទល្មើសនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងជាអនុប្រធានក្រុមការងារចម្រុះតែមប្រ៊ី បានចុះត្រួតពិនិត្យអនុលោមភាពនៅតាមអាជីវកម្មដ្ឋានដែលមានការសង្ស័យថាមានស្តុក និងចែកចាយបារីខុសច្បាប់ ដែលមិនមានបិទតែមប្រ៊ីអាករ និងគ្មានបង្កាន់ដៃពន្ធបញ្ជាក់ថាបានបង់ពន្ធត្រឹមត្រូវសរុបចំនួន **៦ ទីតាំង** ស្ថិតក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ ខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ ដូចខាងក្រោម៖

១. អាជីវកម្មដ្ឋានទី១ ដែលមានអាសយដ្ឋានស្ថិតនៅ សង្កាត់ទួលស្វាយព្រៃ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ បានរកឃើញមានស្តុកនិងមានដាក់លក់បារីចម្រុះម៉ាកចំនួន ៤២៧ កេស ក្នុងនោះបារីខុសច្បាប់ដែលមិនមានបិទតែមប្រ៊ីអាករ និងមិនមានបោះពុម្ពសារព្រមានសុខភាព ចំនួន ១៧៦ កេស ស្មើនឹង ៨ ៨០០ សុង។

២. អាជីវកម្មដ្ឋានទី២ ដែលមានអាសយដ្ឋានស្ថិតនៅភូមិវាលស្បូវ សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មានស្តុកបារីចម្រុះម៉ាកចំនួន ១៦៨,៥ កេស ស្មើនឹង ៤ ៤២៥ សុង ដែលសុទ្ធសឹងជាបារីដែលមានបិទតែមប្រ៊ីអាករត្រឹមត្រូវ និងមិនមានបោះពុម្ពសារព្រមានសុខភាព។

៣. អាជីវកម្មដ្ឋានទី៣ ដែលមានអាសយដ្ឋានស្ថិតនៅឃ្លាំងលើផ្លូវលេខ៥១ ក្នុងភូមិឡធ្យូង ឃុំសំបូរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ បានរកឃើញមានស្តុកនិងមានដាក់លក់បារីចម្រុះម៉ាកចំនួន ១០៨,១៨ កេស ស្មើនឹង ៥ ៤០៩ សុង

ក្នុងនោះបារីខុសច្បាប់ដែលមិនមានបិទតែមប្រើអាករ និងមិនមានបោះពុម្ពសារព្រមានសុខភាព ចំនួន ១.៦៨ កេស ស្មើនឹង ៨៤ សុង។

៤. អាជីវកម្មដ្ឋានទី៤ ដែលមានអាសយដ្ឋានស្ថិតនៅសង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ បានរកឃើញមានស្តុកនិងមានដាក់លក់បារីចម្រុះម៉ាកចំនួន ១១៨ កេស ស្មើនឹង ៥ ៨៧៥ សុង ក្នុងនោះបារីខុសច្បាប់ដែលមិនមានបិទតែមប្រើអាករ និងមិនមានបោះពុម្ពសារព្រមានសុខភាព ចំនួន ៨៣ កេស ស្មើនឹង ៤ ១២៥ សុង។

៥. អាជីវកម្មដ្ឋានទី៥ ដែលមានអាសយដ្ឋានស្ថិតនៅក្នុងផ្សារទំនើប សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ មានដាក់តាំងលក់រាយបារីម៉ាកចិនមួយចំនួនដែលមិនមានបិទតែមប្រើអាករត្រឹមត្រូវ ដូច្នេះក្រុមការងារបានអប់រំណែនាំ និងឱ្យធ្វើកិច្ចសន្យាបញ្ឈប់ការដាក់តាំងលក់បារីដែលមិនមានបិទតែមប្រើ និងមិនមានបោះពុម្ពសារព្រមានសុខភាពបន្តទៀត។

៦. អាជីវកម្មដ្ឋានទី៦ ហាងលក់បារីដែលមានអាសយដ្ឋានស្ថិតនៅសង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ មានដាក់តាំងបារីមានបិទតែមប្រើអាករ និងបោះពុម្ពសារព្រមានសុខភាពត្រឹមត្រូវ។

ក្នុងប្រតិបត្តិការខាងលើ ក្រុមការងារចម្រុះតែមប្រើ បានធ្វើការបង្ក្រាបភ្លាមៗលើអាជីវកម្មដ្ឋាន ដោយបានរៀបចំកំណត់ហេតុដកហូតបារីខុសច្បាប់ទាំងនោះ ដើម្បីយកទៅរក្សាទុកជាបណ្ដោះអាសន្ននៅមណ្ឌលឃ្លាំង របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដើម្បីចាត់ការបន្តតាមនីតិវិធីតាមការយល់ព្រម និងផ្តិតស្នាមមេដៃប្រគល់ជូនពីម្ចាស់អាជីវកម្មដ្ឋាន។ ជាមួយគ្នានេះ ក្រុមការងារចម្រុះតែមប្រើក៏បានណែនាំឱ្យម្ចាស់អាជីវកម្មដ្ឋានទាំងបីត្រូវបញ្ឈប់ការទិញ លក់ និងចែកចាយបារី ដែលមិនមានបិទតែមប្រើអាករត្រឹមត្រូវ និងត្រូវចូលរួមសហការជាមួយក្រុមការងារក្នុងការផ្តល់ព័ត៌មានអំពីក្រុមហ៊ុន ឬជនណាដែលយកបារីខុសច្បាប់មកដាក់លក់ឬចែកចាយ ដើម្បីក្រុមការងារចម្រុះតែមប្រើអាចចាត់វិធានការឱ្យមានប្រសិទ្ធភាព និងទាន់ពេលវេលា។ គួររំលឹកផងដែរថា មុននឹងឈានដល់ការធ្វើប្រតិបត្តិការបង្ក្រាបនេះ ក្រុមការងារចម្រុះតែមប្រើ បានអនុវត្តវិធានការទន់ភ្លន់ជាបន្តបន្ទាប់ដូចជា ការរៀបចំសិក្ខាសាលាផ្សព្វផ្សាយដល់ម្ចាស់សហគ្រាសផលិត នាំចូល និងចែកចាយបារី ជាច្រើនលើក និងបានចុះផ្សព្វផ្សាយ អប់រំ ណែនាំ និងចែកខិត្តប័ណ្ណអំពីកាតព្វកិច្ចបិទតែមប្រើអាករលើកញ្ចប់បារីដោយផ្ទាល់ដល់អ្នកចែកចាយ អ្នកលក់ដុំ និងរាយ នៅតាមទីផ្សារ និងអាជីវកម្មដ្ឋាននានាក្នុងក្របខ័ណ្ឌទូទាំងប្រទេសជាបន្តបន្ទាប់ជាច្រើនរួចមកហើយ៕



# ថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃអគ្គនាយកដ្ឋានពន្ធដារ បានចូលរួមបរិច្ចាគថវិកា ១៨៧ ៨៧០ ០០០ រៀល ជូនមូលនិធិគន្ធបុប្ផាកម្ពុជា ព្រមទាំងប្តេជ្ញាបន្តគាំទ្រដល់មូលនិធិនេះដើម្បីកុមារកម្ពុជា



នាព្រឹកថ្ងៃចន្ទ ទី១ ខែធ្នូ ឆ្នាំ២០២៥ នៅអគ្គនាយកដ្ឋានពន្ធដារ លោកជំទាវ **ម៉ិន នារី** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ តំណាងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ អមដោយលោក **ហ៊ឹម ម៉ិនធឿន** ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងបុគ្គលិក លោកប្រធាន អនុប្រធាន និងសមាជិកលេខាធិការដ្ឋាន នៃគណៈកម្មការទ្រទ្រង់មូលនិធិគន្ធបុប្ផាកម្ពុជាប្រចាំអគ្គនាយកដ្ឋានពន្ធដារ រៀបចំពិធីប្រគល់ថវិកាបរិច្ចាគវិភាគទាន ចំនួន **១៨៧ ៨៧០ ០០០ (មួយរយប៉ែតសិបប្រាំពីរលាន ប្រាំបីរយចិតសិបពាន់) រៀល** ជូនមូលនិធិគន្ធបុប្ផាកម្ពុជា សម្រាប់ឆ្នាំ២០២៥។

ឈរលើស្មារតី "**ខ្មែរជួយខ្មែរ**" អគ្គនាយកដ្ឋានពន្ធដារ បានចូលរួមបរិច្ចាគថវិកាជូនមូលនិធិគន្ធបុប្ផាកម្ពុជា ចាប់តាំងពីឆ្នាំ២០១៩ មកម្ល៉េះ ដោយក្នុងឆ្នាំ២០១៩ ចំនួន ១៣៤ ៨៤៣ ០០០ រៀល, ឆ្នាំ២០២០ ចំនួន ១៦៣ ៥៥០ ០០០ រៀល, ឆ្នាំ២០២១ ចំនួន ១៦៦ ៤៥០ ០០០ រៀល, ឆ្នាំ២០២២ ចំនួន ១៨០ ០៤០ ០០០ រៀល, ឆ្នាំ២០២៣ ចំនួន ១៨៣ ៨៥១ ០០០ រៀល និងឆ្នាំ២០២៤ ចំនួន ១៩០ ៣០០ ០០០ រៀល។ ទន្ទឹមនេះ អគ្គនាយកដ្ឋានពន្ធដារ ក៏បានចូលរួមចលនាសប្បុរសធម៌របស់មូលនិធិគន្ធបុប្ផាយ៉ាងផុសផុល រួមមាន យុទ្ធនាការ "**១ម៉ឺនរៀល ១ម៉ឺននាក់**" ជាដើម។

ឆ្លៀតក្នុងឱកាសនោះ លោកជំទាវ **ម៉ិន នារី** បានបង្ហាញការប្តេជ្ញាបន្តជំរុញការចូលរួមបរិច្ចាគថវិកាពីថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការនៃអគ្គនាយកដ្ឋានពន្ធដារ ដើម្បីរួបរួមគ្នារក្សានិរន្តរភាពនៃកិច្ចដំណើរការរបស់មន្ទីរពេទ្យគន្ធបុប្ផា ក្នុងការបន្តបេសកកម្មផ្តល់សេវាពិនិត្យ និងព្យាបាលទារក និងកុមារ ព្រមទាំងស្ត្រីមានផ្ទៃពោះរាប់លានករណីក្នុងមួយឆ្នាំៗ ប្រកបដោយគុណភាព ឥតគិតថ្លៃ និងមិនមានការរើសអើង៕

# ពិធីសំណេះសំណាល
# ជាមួយក្រុមនិស្សិតជ័យលាភីអាហារូបករណ៍របស់រដ្ឋាភិបាលប្រទេសអូស្ត្រាលី




នាព្រឹកថ្ងៃចន្ទ ទី៨ ខែធ្នូ ឆ្នាំ២០២៥ នៅអគ្គនាយកដ្ឋានពន្ធដារ មានរៀបចំពិធីសំណេះសំណាលជាមួយក្រុមនិស្សិតជ័យលាភីអាហារូបករណ៍របស់រដ្ឋាភិបាលប្រទេសអូស្ត្រាលី (Australia Awards Scholarship) ចំនួន **៥៥ រូប** ក្រោមអធិបតីភាព ឯកឧត្តម **លឹម ហ៊ុយជីវ** តំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ដោយមានការចូលរួមពីថ្នាក់ដឹកនាំនិងមន្ត្រីពាក់ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធដារ។ ក្នុងឱកាសនេះ ឯកឧត្តម **លឹម ហ៊ុយជីវ** បានសម្តែងនូវការកោតសរសើរ និងចូលរួមអបអរសាទរចំពោះក្រុមនិស្សិតជ័យលាភីអាហារូបករណ៍របស់រដ្ឋាភិបាលប្រទេសអូស្ត្រាលី ព្រមទាំងបានរំលឹក និងពញ្ញាក់ស្មារតីដល់ក្រុមនិស្សិតអំពីសារៈសំខាន់នៃការទទួលជ័យលាភីអាហារូបករណ៍ទៅបន្តការសិក្សានៅប្រទេសអូស្ត្រាលី ដែលត្រូវបានចាត់ទុកថាជាឯកសិទ្ធិមួយដ៏ឧដុង្គឧត្តម (A Great Privilege) របស់និស្សិតជ័យលាភីអាហារូបករណ៍ទាំងអស់គ្នា។ ឯកឧត្តម **លឹម ហ៊ុយជីវ** ក៏បានផ្តែផ្តាំឱ្យក្រុមនិស្សិតជ័យលាភីទាំងអស់ត្រូវចេះដឹងគុណដល់រាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលប្រទេសអូស្ត្រាលី តាមរយៈការប្រើប្រាស់ ឯកសិទ្ធិនេះឱ្យបានល្អប្រសើរដើម្បីផលប្រយោជន៍ខ្លួនឯង គ្រួសារ និងប្រទេសជាតិយើង ស្របតាមគោលបំណងរបស់រាជរដ្ឋាភិបាលកម្ពុជាយើងក៏ដូចជារដ្ឋាភិបាលប្រទេសអូស្ត្រាលី ដែលជាប្រភពនៃការផ្តល់ឯកសិទ្ធិនេះ។ ក្រៅពីនេះឯកឧត្តមបានចែករំលែកនូវបទពិសោធការងារ និងគតិបណ្ឌិតជាច្រើន ដើម្បីផ្តល់ជូនក្រុមនិស្សិតជ័យលាភីអាហារូបករណ៍របស់រដ្ឋាភិបាលប្រទេសអូស្ត្រាលី ជាជំនួយស្មារតីសម្រាប់យកទៅគិតពិចារណាឱ្យបានគ្រប់ជ្រុងជ្រោយក្នុងដំណើរការសិក្សានៅទីនោះឱ្យបានជោគជ័យ និងពាំនាំយកនូវចំណេះដឹង និងបទពិសោធល្អៗត្រឡប់មកបម្រើផលប្រយោជន៍ប្រទេសជាតិយើងឱ្យបានរីកចម្រើនរុងរឿងតរៀងទៅមុខទៀត។

# អគ្គនាយកដ្ឋានពន្ធដារ បានរៀបចំសម្ភារប្រើប្រាស់ និងគ្រឿងឧបភោគបរិភោគជូនជនភៀសសឹកដែលបានរត់ភៀសខ្លួនចេញពីផ្ទះសម្បែងស្ថិតនៅតាមតំបន់ជម្លោះព្រំដែនកម្ពុជា-ថៃ



ក្រោមការចង្អុលបង្ហាញពី ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ នាថ្ងៃពុធ ទី១០ ដល់ថ្ងៃសុក្រ ទី១២ ខែធ្នូ ឆ្នាំ២០២៥ លោកជំទាវ **ម៉ុន នារី** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ បានដឹកនាំការងាររៀបចំសម្ភារប្រើប្រាស់ និងគ្រឿងឧបភោគបរិភោគ ដែលបានមកពីការចូលរួមរបស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យានៃអគ្គនាយកដ្ឋានពន្ធដារ សម្រាប់ប្រគល់ជូនដល់ជនភៀសសឹកដែលបានរត់ភៀសខ្លួនចេញពីផ្ទះសម្បែងស្ថិតនៅតាមតំបន់ជម្លោះព្រំដែនកម្ពុជា-ថៃ។ សម្ភារប្រើប្រាស់ និងគ្រឿងឧបភោគបរិភោគទាំងអស់នោះសុទ្ធសឹងជាតម្រូវការបន្ទាន់ និងចាំបាច់របស់ជនភៀសសឹក រួមមាន តង់ មុង ភួយ កន្ទេល ក្រមា ប្រេងក្រឡា សាប៊ូ ធូបមូស ត្រីខ ផៃប៉ូវ និងសាច់ក្រកជាដើម។ បន្ទាប់ពីបានរៀបចំរួច អគ្គនាយកដ្ឋានពន្ធដារបានបែងចែកក្រុមការងារជា ៤ គោលដៅដើម្បីនាំយកសម្ភារប្រើប្រាស់ និងគ្រឿងឧបភោគ បរិភោគទៅប្រគល់ជូនជនភៀសសឹក ក្នុងនោះមាន ខេត្តព្រះវិហារ ចំនួន ៥០០ គ្រួសារ ខេត្តឧត្តរមានជ័យ ចំនួន ៥០០ គ្រួសារ ខេត្តសៀមរាប ចំនួន ២០០ គ្រួសារ និងខេត្តកោះកុង បានប្រគល់ជូននូវអង្ករ ៥ តោន ទឹកសុទ្ធ ៣០០ កេស និងផៃប៉ូវ ៣០០ គីឡូក្រាម។ អគ្គនាយកដ្ឋានពន្ធដារ នឹងនៅតែបន្តស្មារតីសាមគ្គីនៃមហាគ្រួសារខ្មែរ ដើម្បីចូលរួមគាំទ្រនិងលើកទឹកចិត្តដល់វីរកងទ័ពជួរមុខកម្ពុជា និងសម្តែងនូវស្មារតីភាតរភាពចំពោះបងប្អូនប្រជាពលរដ្ឋ ដែលត្រូវបានជម្លៀសខ្លួនមកកាន់ទីសុវត្ថិភាពនានា៕





# ពិធីសំណេះសំណាលជាមួយប្រតិភូយុវជន នៃសមាគមនាវាយុវជនអាស៊ីអាគ្នេយ៍កម្ពុជា



នាព្រឹកថ្ងៃពុធ ទី១៧ ខែធ្នូ ឆ្នាំ២០២៥ នៅអគ្គនាយកដ្ឋានពន្ធដារ មានរៀបចំពិធីសំណេះសំណាលជាមួយក្រុមប្រតិភូយុវជននៃសមាគមនាវាយុវជនអាស៊ីអាគ្នេយ៍កម្ពុជាចំនួន **១៧ រូប** ក្រោមអធិបតីភាព ឯកឧត្តម **លឹម ហ៊ុយជីវ** តំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ដោយមានការចូលរួមពីថ្នាក់ដឹកនាំនិងមន្ត្រីពាក់ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធដារ តំណាងក្រសួងអប់រំ យុវជន និងកីឡា និងតំណាងសមាគមនាវាយុវជនអាស៊ីអាគ្នេយ៍។ ក្នុងឱកាសនេះ ឯកឧត្តម **លឹម ហ៊ុយជីវ** បានចែករំលែកនូវបទពិសោធការងារ និងគតិបណ្ឌិតជាច្រើនជូនប្រតិភូយុវជននៃសមាគមនាវាយុវជនអាស៊ីអាគ្នេយ៍កម្ពុជា និងបានធ្វើបទបង្ហាញជូនអំពីសាវតាររបស់អគ្គនាយកដ្ឋានពន្ធដារនៃដំណើរវិវត្តន៍រដ្ឋបាលសារពើពន្ធ និងអភិក្រមការងារសំខាន់ៗ របស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាលកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានពន្ធដារ ការធ្វើបរិវត្តកម្មនៃអគ្គនាយកដ្ឋានពន្ធដារដែលបានក្លាយជារដ្ឋបាលសារពើពន្ធទំនើបទាន់សម័យមកដល់ពេលបច្ចុប្បន្ន និងជាពិសេស គឺការសម្រេចបាននូវលទ្ធផលកំណើនចំណូលពន្ធដារជាបន្តបន្ទាប់ពីមួយឆ្នាំទៅមួយឆ្នាំក្នុងរយៈពេលជាងមួយទសវត្សរ៍កន្លងមកនេះសម្រាប់ដាក់ចូលជាថវិកាជាតិ ដើម្បីជាប្រយោជន៍ដល់ការបន្តអភិវឌ្ឍប្រទេសជាតិយើងជានិរន្តរ៍។ ជាចុងបញ្ចប់ ឯកឧត្តម **លឹម ហ៊ុយជីវ** បានវាយតម្លៃខ្ពស់ ផ្តល់អនុសាសន៍ និងផ្តែផ្តាំដល់ប្រតិភូយុវជននៃសមាគមនាវាយុវជនអាស៊ីអាគ្នេយ៍កម្ពុជា ត្រូវដើរតួនាទីជាទូតសុច្ឆន្ទៈតំណាងឱ្យកម្ពុជាដើម្បីបង្ហាញប្រតិភូយុវជននៃសមាគមនាវាយុវជនអាស៊ីអាគ្នេយ៍នៃបណ្តាប្រទេសដទៃទៀតអំពីចរិតលក្ខណៈស្លូតត្រង់ និងវប្បធម៌ដ៏ល្អប្រពៃរបស់កម្ពុជាយើងនិងត្រូវខិតខំសម្រេចឱ្យបាននូវបេសកកម្ម និងគោលបំណងនៃកម្មវិធីនេះ ដើម្បីជាប្រយោជន៍ដល់ការបន្តអភិវឌ្ឍសាមីខ្លួនផង និងដើម្បីចូលរួមចំណែកជួយលើកស្ទួយដំណើរអភិវឌ្ឍន៍ប្រទេសជាតិយើងឱ្យបានរីកចម្រើនរុងរឿងជាបន្តបន្ទាប់ប្រកបដោយចីរភាព៕

# កម្មវិធីបិទវគ្គបណ្តុះបណ្តាលតម្រង់ទិសផ្ទៃក្នុង ជូនមន្ត្រីពន្ធដារក្របខណ្ឌថ្មីចំនួន ២៥២ រូប ដែលត្រូវបានប្រកាសទទួលស្គាល់ឱ្យចូលបម្រើការងារនៅអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ




នាព្រឹកថ្ងៃពុធ ទី៣១ ខែធ្នូ ឆ្នាំ២០២៥ អគ្គនាយកដ្ឋានពន្ធដារ បានរៀបចំកម្មវិធីបិទវគ្គបណ្តុះបណ្តាលតម្រង់ទិសផ្ទៃក្នុង ជូនមន្ត្រីពន្ធដារថ្មីចំនួន **២៥២ រូប** ដែលត្រូវបានប្រកាសទទួលស្គាល់ឱ្យចូលបម្រើការងារនៅអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រោមអធិបតីភាពលោក **ហ៊ឹម ម៉ុនធឿន** ប្រធាននាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក និងលោក **ស៊ុន វុទ្ធី** នាយកសាលាជាតិពន្ធដារ។ ជាកិច្ចចាប់ផ្តើម លោក **ហ៊ឹម ម៉ុនធឿន** បានសម្តែងការស្វាគមន៍យ៉ាងកក់ក្តៅ សូមចូលរួមអបអរសាទរដល់មន្ត្រីពន្ធដារថ្មីចំនួន **២៥២ រូប** ដែលត្រូវបានប្រកាសទទួលស្គាល់ឱ្យចូលបម្រើការងារនៅអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងបានបញ្ចប់វគ្គបណ្តុះបណ្តាលតម្រង់ទិសផ្ទៃក្នុងដោយទទួលបានលទ្ធផលល្អប្រសើរទាំងអស់គ្នា។ ឆ្លៀតក្នុងឱកាសនេះ លោកប្រធាននាយកដ្ឋានបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលកម្ពុជា ដែលបានអនុញ្ញាតឱ្យអគ្គនាយកដ្ឋានពន្ធដារធ្វើការជ្រើសរើសមន្ត្រីក្របខណ្ឌថ្មីឆ្នាំ២០២៥ ដោយការជ្រើសរើសគឺត្រូវបានដឹកនាំដោយផ្ទាល់ពី ឯកឧត្តម **ហ៊ុន ម៉ានី** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។ ជាមួយគ្នានេះ លោក **ស៊ុន វុទ្ធី** នាយកសាលាជាតិពន្ធដារ បានលើកឡើងថា វគ្គបណ្តុះបណ្តាលតម្រង់ទិសផ្ទៃក្នុងសម្រាប់មន្ត្រីថ្មីឆ្នាំ២០២៥នេះ មានមុខវិជ្ជាបណ្តុះបណ្តាលច្រើនជាងវគ្គបណ្តុះបណ្តាលតម្រង់ទិសកន្លងមក ដោយអគ្គនាយកដ្ឋានពន្ធដារ បានធ្វើការបន្ថែមនូវមុខវិជ្ជាសំខាន់ៗមួយចំនួនដែលពាក់ព័ន្ធទៅនឹងការបំពេញការងារប្រចាំថ្ងៃរបស់មន្ត្រីជាពិសេសវគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យផ្សេងៗរបស់អគ្គនាយកដ្ឋានពន្ធដារ។

# អគ្គនាយកដ្ឋានពន្ធដារ បន្តសកម្មភាពចែកសម្ភារប្រើប្រាស់ និងគ្រឿងឧបភោគបរិភោគជូនជនភៀសសឹកដែលបានរត់ភៀសខ្លួនចេញពីផ្ទះសម្បែងស្ថិតនៅតាមតំបន់ជម្លោះព្រំដែនកម្ពុជា-ថៃ



ក្រោមការចង្អុលបង្ហាញពី ឯកឧត្តម **គន់ ទិមុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ នាថ្ងៃព្រហស្បតិ៍ ទី១៨ ដល់ថ្ងៃសុក្រ ទី១៩ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **រ័ត្ន មុនី** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ បានដឹកនាំក្រុមការងារនៃអគ្គនាយកដ្ឋានពន្ធដារ នាំយកសម្ភារប្រើប្រាស់ និងគ្រឿងឧបភោគបរិភោគ ចែកជូនដល់ជនភៀសសឹកដែលបានរត់ភៀសខ្លួនចេញពីផ្ទះសម្បែងស្ថិតនៅតាមតំបន់ជម្លោះព្រំដែនកម្ពុជា-ថៃ ចំនួន **២ ៤០០ គ្រួសារ** ក្នុងមូលដ្ឋានខេត្តសៀមរាប។ សម្ភារប្រើប្រាស់ និងគ្រឿងឧបភោគបរិភោគទាំងអស់នោះសុទ្ធសឹងជាតម្រូវការចាំបាច់បន្ទាន់របស់ជនភៀសសឹក ដែលបានមកពីការចូលរួមរបស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យានៃអគ្គនាយកដ្ឋានពន្ធដារ រួមមាន៖ អង្ករ មី នំ ទឹកត្រី ទឹកស៊ីអ៊ីវ សៀងផ្អែម ប្រេងឆា និងត្រីខជាដើម។ ក្នុងឱកាសនេះដែរ ប្រតិភូអគ្គនាយកដ្ឋានពន្ធដារក៏បានចែកជូនគ្រួសារកងទ័ពដែលកំពុងមានផ្ទៃពោះ និងជនពិការ ចំនួន **៣២២ រូប** នូវថវិកាមួយចំនួន បន្ថែមពីលើសម្ភារ និងគ្រឿងឧបភោគបរិភោគដែលទទួលបាន។ អគ្គនាយកដ្ឋានពន្ធដារ នឹងនៅតែបន្តស្មារតីសាមគ្គីនៃមហាគ្រួសារខ្មែរ ដើម្បីចូលរួមគាំទ្រនិងលើកទឹកចិត្តដល់វីរកងទ័ពជួរមុខកម្ពុជា និងសម្តែងនូវស្មារតីភាតរភាពចំពោះបងប្អូនប្រជាពលរដ្ឋដែលត្រូវបានជម្លៀសខ្លួនមកកាន់ទីសុវត្ថិភាពនានា៕





# ឯកឧត្តម គង់ វិបុល ចាត់តំណាងឱ្យនាំយកស្បៀងអាហារ និងសម្ភារចាំបាច់មួយចំនួនជូនកងការពារព្រំដែនលេខ៥០១ និងបញ្ជាការដ្ឋានរថក្រោះ កងទ័ពជើងគោក



នាថ្ងៃអាទិត្យ ទី២១ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានចាត់តំណាងរួមមាន ឯកឧត្តមបណ្ឌិត **ម៉ិញ បានកុសល** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ និង ឯកឧត្តម **ហេង សុខណាង** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ នាំយកស្បៀងអាហារ និងសម្ភារចាំបាច់មួយចំនួន ជូនកងការពារព្រំដែនលេខ៥០១ តាមរយៈរដ្ឋបាលខេត្តពោធិ៍សាត់ និងជូនបញ្ជាការដ្ឋានរថក្រោះ កងទ័ពជើងគោក តាមរយៈរដ្ឋបាលខេត្តបាត់ដំបង។ ស្បៀងអាហារ និងសម្ភារចាំបាច់ទាំងអស់នេះបានមកពីការចូលរួមរបស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យានៃអគ្គនាយកដ្ឋានពន្ធដារ រួមមាន៖ អង្ករ ទឹកសុទ្ធ ភេសជ្ជៈ ឆៃប៉ូវប្រៃ សាច់ក្រក ត្រីខ សាច់មាន់ផាត់ ទឹកត្រី ទឹកស៊ីអ៊ីវ អំបិល ស្ករស ប៊ីចេង ព្រមទាំងថវិកា និងសម្ភារផ្សេងមួយចំនួនទៀត។ បន្ថែមពីនេះ គណៈប្រតិភូអគ្គនាយកដ្ឋានពន្ធដារក៏បានពាំនាំថវិកាឧបត្ថម្ភជូនរដ្ឋបាលខេត្តពោធិ៍សាត់ និងរដ្ឋបាលខេត្តបាត់ដំបង ដើម្បីរួមចំណែកក្នុងកិច្ចការសម្របសម្រួលដល់សកម្មភាពគាំទ្រដល់ជនភៀសសឹក និងវីរកងទ័ពរបស់យើងផងដែរ។






# ផ្នែកទី៥

## ការផ្សព្វផ្សាយ និងបញ្ច្រាបវប្បធម៌បន់ពន្ធ

១. កិច្ចការបណ្តុះបណ្តាល និងសិក្ខាសាលារបស់សាលាជាតិពន្ធដារ

២. ការស្រាវជ្រាវ អភិវឌ្ឍន៍កម្មវិធី និងបណ្ណាល័យ

៣. សិក្ខាសាលាសំខាន់ៗ

# ការផ្សព្វផ្សាយ និងបញ្ជ្រាបវប្បធម៌បង់ពន្ធ

ក្នុងគោលដៅពង្រឹងការយល់ដឹងអំពីពន្ធដារ ពាក់ព័ន្ធនឹងច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ ការធ្វើទំនើបកម្មពន្ធដារ និងវឌ្ឍនភាពថ្មីៗ ជាពិសេសពាក់ព័ន្ធការផ្តល់សេវាអ្នកជាប់ពន្ធ ក្នុងខែធ្នូ ឆ្នាំ២០២៥ អគ្គនាយកដ្ឋានពន្ធដារបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយនិងវគ្គបណ្តុះបណ្តាលចំនួន **៥០ លើក** មានសិក្ខាកាមចូលរួមចំនួន **៥ ៨៤១ រូប** ក្នុងនោះវគ្គបណ្តុះបណ្តាលចំនួន **១៦ លើក** មានសិក្ខាកាមចូលរួមចំនួន **៣ ៥៥៧ រូប** និងសិក្ខាសាលាចំនួន **៣៤ លើក** មានសិក្ខាកាមចូលរួមចំនួន **២ ២៨៤ រូប**។

សរុបរយៈពេល ១២ខែ ឆ្នាំ២០២៥ អគ្គនាយកដ្ឋានពន្ធដារបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយនិងវគ្គបណ្តុះបណ្តាលចំនួន **៨៨៨ លើក** មានសិក្ខាកាមចូលរួមចំនួន **៨៩ ២២៦ រូប** ក្នុងនោះវគ្គបណ្តុះបណ្តាលចំនួន **៤៩២ លើក** មានសិក្ខាកាមចូលរួមចំនួន **៥២ ៥០២ រូប** និងសិក្ខាសាលាចំនួន **៣៩៦ លើក** មានសិក្ខាកាមចូលរួមចំនួន **៣៦ ៧២៤ រូប**។

**របាយការណ៍ ស្តីពីការរៀបចំវគ្គបណ្តុះបណ្តាលនិងសិក្ខាសាលា ក្នុងរយៈពេល ១២ខែ ឆ្នាំ២០២៥**

| **បរិយាយ** | **ខែតុលា** | | **ខែវិច្ឆិកា** | | **ខែធ្នូ** | | **រយៈពេល ១២ខែ** | |
|---|---|---|---|---|---|---|---|---|
| | ចំនួនលើក | សិក្ខាកាម | ចំនួនលើក | សិក្ខាកាម | ចំនួនលើក | សិក្ខាកាម | ចំនួនលើក | សិក្ខាកាម |
| I.**សិក្ខាសាលា** | | | | | | | | |
| អ្នកជាប់ពន្ធ | ១៧ | ១ ៧៨០ | ១៨ | ១ ៤៧៥ | ២៤ | ១ ៧០២ | ២៦៨ | ២៥ ៩៨១ |
| មន្ត្រីរាជការពន្ធដារ | ០១ | ១៣០ | ០០ | ០០ | ០២ | ១១២ | ៥៦ | ៤ ៣៨៩ |
| សិស្ស-និស្សិត | ០០ | ០០ | ០០ | ០០ | ០០ | ០០ | ០០ | ០០ |
| សាធារណជន | ១០ | ៧០៣ | ០៥ | ២៦៦ | ០៨ | ៤៧០ | ៧២ | ៦ ៣៥៤ |
| មន្ត្រីធនាគារដៃគូ | ០០ | ០០ | ០០ | ០០ | ០០ | ០០ | ០០ | ០០ |
| **សរុបសិក្ខាសាលា** | **២៨** | **២ ៦១៣** | **២៣** | **១ ៧៤១** | **៣៤** | **២ ២៨៤** | **៣៩៦** | **៣៦ ៧២៤** |
| II.**វគ្គបណ្តុះបណ្តាល** | | | | | | | | |
| អ្នកជាប់ពន្ធ | ០០ | ០០ | ០០ | ០០ | ០០ | ០០ | ១៦ | ១ ២៥៩ |
| មន្ត្រីធនាគារដៃគូ | ០៥ | ២៩០ | ០០ | ០០ | ០៤ | ១ ៦៩២ | ៤១ | ៨ ៦១៦ |
| មន្ត្រីរាជការពន្ធដារ | ២៨ | ៣ ៨៣៦ | ៣៥ | ៣ ៦៨៣ | ១២ | ១ ៨៦៥ | ៤៣៥ | ៤២ ៦២៧ |
| **សរុបវគ្គបណ្តុះបណ្តាល** | **៣៣** | **៤ ១២៦** | **៣៥** | **៣ ៦៨៣** | **១៦** | **៣ ៥៥៧** | **៤៩២** | **៥២ ៥០២** |
| **សរុបរួម** (I+II) | **៦១** | **៦ ៧៣៩** | **៥៨** | **៥ ៤២៤** | **៥០** | **៥ ៨៤១** | **៨៨៨** | **៨៩ ២២៦** |






# ១.កិច្ចការបណ្តុះបណ្តាល និងសិក្ខាសាលារបស់សាលាជាតិពន្ធដារ

## កម្មវិធីបិទវគ្គបណ្តុះបណ្តាលតម្រង់ទិសជូនមន្ត្រីពន្ធដារថ្មី វគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈពន្ធដារ

ក្នុងត្រីមាសទី៤ ឆ្នាំ២០២៥ នេះ សាលាជាតិពន្ធដារ នៃអគ្គនាយកដ្ឋានពន្ធដារ បានរៀបចំកម្មវិធីបិទវគ្គបណ្តុះបណ្តាលតម្រង់ទិសសម្រាប់មន្ត្រីថ្មីចំនួន **២៥២ រូប** ដែលត្រូវប្រកាសឱ្យចូលបម្រើការងារនៅអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានវត្តមានរបស់លោក **ហ៊ឹម ម៉ុនធឿន** ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងបុគ្គលិក និងលោក **ស៊ុន ឧុទ្ធី** នាយកសាលាជាតិពន្ធដារ ជាគណៈធិបតី រួមជាមួយគ្រូឧទ្ទេស ថ្នាក់ដឹកនាំ និងមន្ត្រីនៃសាលាជាតិពន្ធដារ ព្រមទាំងសិក្ខាកាមទាំងអស់។



## វគ្គបណ្តុះបណ្តាលខ្លីៗសម្រាប់អ្នកជាប់ពន្ធ និងសាធារណជនទូទៅ

ស្របតាមផែនការប្រតិបត្តិឆ្នាំ២០២៥ របស់សាលាជាតិពន្ធដារ នៅក្នុងត្រីមាសទី៤ នេះ សាលាជាតិពន្ធដារបានបន្តបើកវគ្គបណ្តុះបណ្តាលខ្លីៗ ជូនសាធារណជនទូទៅ ចំនួន **៦ វគ្គ** ដែលក្នុងនោះរួមមាន៖ ១.កាតព្វកិច្ចសារពើពន្ធចំពោះសកម្មភាពអាជីវកម្មដឹកជញ្ជូនទំនិញតាមផ្លូវទឹកជាអន្តរជាតិ សរុបចំនួន **១ ក្រុម** ដែលមានសិក្ខាកាមចុះឈ្មោះសិក្សាចំនួន ២៨ រូប ស្រី ២១ រូប ២.កាតព្វកិច្ចសារពើពន្ធរបស់អ្នកជាប់ពន្ធតូច ចំនួន **១ ក្រុម** ដែលមានសិក្ខាកាមចូលរួមចំនួន ២៣ រូប ស្រី ១៧ រូប ៣.ពន្ធលើប្រាក់ចំណូល និងអាករលើតម្លៃបន្ថែម ចំនួន **១ ក្រុម** ដែលមានសិក្ខាកាមចូលរួមចំនួន ៥៨ រូប ស្រី ៤០ រូប ៤.ការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មតាមអនឡាញ e-Filing (CPE) ចំនួន ១ ក្រុម ដែលមានសិក្ខាកាមចូលរួមចំនួន ៤២ រូប ស្រី ២៦ រូប ៥.ការប្រកាសអាករលើតម្លៃបន្ថែមតាមវិធីគិតអាករជំនួស (Reverse Charge) និងការប្រើប្រាស់សេវាកម្មអេឡិចត្រូនិកពន្ធដារ ចំនួន **១ ក្រុម** ដែលមានសិក្ខាកាមចូលរួមចំនួន ១៣ រូប ស្រី ១០ រូប។

# សិក្ខាសាលាជូននិស្សិត ភ្នាក់ងារសេវាកម្មពន្ធដារ អ្នកជាប់ពន្ធ និងសាធារណជនទូទៅ

ក្នុងត្រីមាសទី៤ នេះសាលាជាតិពន្ធដារបានរៀបចំសិក្ខាសាលាតាមអនឡាញ ជូនអ្នកជាប់ពន្ធ ភ្នាក់ងារសេវាកម្មពន្ធដារ និងសាធារណជនទូទៅ ចំនួន **២ លើក** ដែលមានសិក្ខាកាមចូលរួមសរុបចំនួន **១ ១៦៦ រូប** រួមមានប្រធានបទដូចជា៖ ១.អាករលើតម្លៃបន្ថែម និងវិធាននៃការប្រើប្រាស់វិក្កយបត្រ ដែលមានសិក្ខាកាមចូលរួមសរុប ៩៧ រូប ស្រី ៧៨ រូប ២.ពន្ធប្រថាប់ត្រា ពន្ធលើអចលនទ្រព្យ និងពន្ធលើដីធ្លីមិនបានប្រើប្រាស់ ដែលមានសិក្ខាកាមចូលរួមសរុប ៩៣ រូប ស្រី ៧៤ រូប ក្រោមការសម្របសម្រួលពីលោក **នាក់ ឌីម** ប្រធានការិយាល័យបណ្ដុះបណ្ដាល និងសហប្រតិបត្តិការនៃសាលាជាតិពន្ធដារ ដោយមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីសាលាជាតិពន្ធដារ។ និងបានរៀបចំសិក្ខាសាលាជូនសិស្ស និស្សិត តាមបណ្ដាសាកលវិទ្យាល័យ ចំនួន **២ លើក** ក្រោមប្រធានបទ ស្ដីពីសារៈសំខាន់នៃការប្រមូលពន្ធ ការវិវត្តនៃការប្រមូលពន្ធ និងបច្ចុប្បន្នភាពច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្ដីពីពន្ធដារ ចំនួន ២ លើក ដែលមានសិក្ខាកាមចូលរួមសរុប **២៧៣ រូប** ស្រី **១៩១ រូប** ក្រោមការសម្របសម្រួលពីលោក **លី ចាន់ធី** នាយករងសាលាជាតិពន្ធដារ ដោយមានការចូលរួមពីមន្ត្រីនៃសាលាជាតិពន្ធដារផងដែរ។






# ២.ការស្រាវជ្រាវ អភិវឌ្ឍន៍កម្មវិធី និងបណ្ណាល័យ

## ការផ្តល់សេវាបណ្ណាល័យសាលាជាតិពន្ធដារ

នៅក្នុងត្រីមាសទី៤ ឆ្នាំ២០២៥ សាលាជាតិពន្ធដារបានផ្តល់សេវាបណ្ណាល័យរួមមាន៖ ការចូលអាន ការខ្ចី និងការទទួលសងសៀវភៅ និងឯកសារផ្សេងៗ ជូនដល់មន្ត្រីរាជការ សិក្ខាកាម សិស្ស-និស្សិត និងសាធារណជនទូទៅ បានចំនួន **៨៩ រូប** (ស្រីចំនួន **៨ រូប**)។ ក្រៅពីការងារផ្តល់សេវាទាំងនេះ សាលាជាតិពន្ធដារក៏បានខិតខំស្រាវជ្រាវប្រមូល និងបានទទួលសៀវភៅថ្មីៗពាក់ព័ន្ធនឹងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពីអគ្គនាយកដ្ឋានពន្ធដារ និងស្ថាប័នផ្សេងៗ ចំនួន **៣៧៥ ក្បាល** បន្ថែមទៀត ដើម្បីបំពេញការខ្វះខាត ក៏ដូចជាតម្រូវការរបស់អ្នកអាន បន្ថែមលើឯកសារដែលមានស្រាប់ផងដែរ។ គិតមកដល់បច្ចុប្បន្ន បណ្ណាល័យសាលាជាតិពន្ធដារបានរក្សាទុកសៀវភៅ ច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងឯកសារសំខាន់ៗផ្សេងៗទៀតជាច្រើនសរុបចំនួន **៨ ៣៧៧ ក្បាល** ក្នុងនោះមានឯកសារជាទម្រង់ឌីជីថលចំនួន **២ ៣៥៣ ឯកសារ**។





# ៣.សិក្ខាសាលាសំខាន់ៗ

## អគ្គនាយកដ្ឋានពន្ធដាររៀបចំសិក្ខាសាលា ស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងពន្ធលើប្រាក់ចំណូល ជូនសហគ្រាសជាអ្នកជាប់ពន្ធតូចនិងមធ្យម



នាព្រឹកថ្ងៃពុធ ទី១៧ ខែធ្នូ ឆ្នាំ២០២៥ នៅសណ្ឋាគារសុខាភ្នំពេញ អគ្គនាយកដ្ឋានពន្ធដារ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងពន្ធលើប្រាក់ចំណូលជូនសហគ្រាសជាអ្នកជាប់ពន្ធតូចនិងមធ្យម ដែលស្ថិតក្រោមការគ្រប់គ្រងរបស់សាខាពន្ធដារខណ្ឌទាំង ៩ ក្នុងរាជធានីភ្នំពេញ ក្រោមអធិបតីភាព ឯកឧត្តម **ហេង សុខណាង** អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ។ សិក្ខាសាលានេះមានការចូលរួមពីថ្នាក់ដឹកនាំនិងមន្ត្រីជំនាញពាក់ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធដារ តំណាងមកពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រសួងពាណិជ្ជកម្ម អគ្គនាយកដ្ឋានគោលនយោបាយនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រុមការងារអគ្គនាយកដ្ឋានពន្ធដារនិងផ្នែកឯកជន សភាពាណិជ្ជកម្មកម្ពុជា មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ សម្ព័ន្ធសហគ្រាសធុនតូចនិងមធ្យមកម្ពុជា សភាមុខរបរនិងមីក្រូសហគ្រាសកម្ពុជា និងលេខាធិការដ្ឋានក្រុមការងារអន្តរក្រសួងរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច សរុបចំនួន **៣៦៥រូប**។ សិក្ខាសាលានេះរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងបន្ថែមអំពីការលើកទឹកចិត្តផ្នែកពន្ធដារសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងពន្ធលើប្រាក់ចំណូលសម្រាប់អ្នកជាប់ពន្ធតូចនិងមធ្យមដែលចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្ត ព្រមទាំងបង្កើតវេទិកាជាឱកាសសម្រាប់អ្នកជាប់ពន្ធបានជួបពិភាក្សាជាមួយរដ្ឋបាលសារពើពន្ធដោយផ្ទាល់ ដើម្បីលើកឡើងនូវសំណើ សំណូមពរ និងបញ្ហាប្រឈមនានាដែលពាក់ព័ន្ធនឹងការអនុវត្តកាតព្វកិច្ចសារពើពន្ធ សំដៅពង្រឹងអនុលោមភាពសារពើពន្ធ និងលើកកម្ពស់វប្បធម៌នៃការបង់ពន្ធ៕

# សិក្ខាសាលាផ្សព្វផ្សាយសេចក្ដីណែនាំ ស្ដីពី "នីតិវិធីនៃការអនុវត្តការលើកទឹកចិត្តផ្នែកពន្ធដារ ក្រោមកម្មវិធីពិសេស ជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុ"




នាព្រឹកថ្ងៃព្រហស្បតិ៍ ទី២៧ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅសណ្ឋាគារ SEA BREEZE HOTEL & VILLA ខេត្តព្រះសីហនុ អគ្គនាយកដ្ឋានពន្ធដារ បានសហការជាមួយក្រុមការងារជំរុញការវិនិយោគខេត្តព្រះសីហនុ រៀបចំសិក្ខាសាលាផ្សព្វផ្សាយសេចក្ដីណែនាំស្ដីពី "**នីតិវិធីនៃការអនុវត្តការលើកទឹកចិត្តផ្នែកពន្ធដារ ក្រោមកម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុ**" ក្រោមអធិបតីភាព ឯកឧត្តម **វ័ត្ន មុនី** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ និង លោក **៦ម ភាព** អភិបាលរងនៃគណៈអភិបាលខេត្តព្រះសីហនុ។ សិក្ខាសាលានេះមានការចូលរួមពីមន្ត្រីជំនាញពាក់ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធដារ តំណាងមន្ទីរ-អង្គភាពពាក់ព័ន្ធនៃរដ្ឋបាលខេត្តព្រះសីហនុ ក្រុមការងារជំរុញការវិនិយោគខេត្តព្រះសីហនុ និងវិនិយោគិនក្នុងខេត្តព្រះសីហនុ សរុប **៩៣ រូប**។

គួរបញ្ជាក់ផងដែរថា គិតមកដល់បច្ចុប្បន្ន ក្រោមកម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុ ក្រុមការងារជំរុញការវិនិយោគខេត្តព្រះសីហនុ បានទទួលសំណើសុំលើកទឹកចិត្តចំនួន **៤១៣ គម្រោង** ក្នុងនោះគម្រោងដែលទទួលបានលិខិតអនុញ្ញាតជាគោលការណ៍ចំនួន **៤១២ គម្រោង** មានទុនវិនិយោគសរុបប្រមាណ **៧ ៩៧០ លានដុល្លារ** និងប៉ាន់ស្មានអាចបង្កើតឱកាសការងារ **៥២ ០០៤ កន្លែង**។ ក្នុងចំណោមគម្រោងវិនិយោគទាំងនោះ មានគម្រោងពាក់ព័ន្ធនឹងអគារជាប់គាំងមានចំនួន **១៩៤ គម្រោង** គម្រោងថ្មីមានចំនួន **១៧៨ គម្រោង** ការពង្រីកគម្រោងដែលមានស្រាប់មានចំនួន **២៥ គម្រោង** និងគម្រោងវិនិយោគដែលមានស្រាប់មានចំនួន **១៥ គម្រោង**៕

# សិក្ខាសាលាផ្សព្វផ្សាយស្តីពី "ការកំណត់ហានិភ័យអ្នកជាប់ពន្ធ ការពង្រឹងយន្តការនៃការគ្រប់គ្រងចំណូលពន្ធ ការអញ្ជើញអ្នកជាប់ពន្ធមកចុះបញ្ជីពន្ធដារ និងការព្យួរសុពលភាពវិញ្ញាបនបត្រអាករលើតម្លៃបន្ថែម"



ដោយមានការចាត់តាំងពី ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ និងជាប្រធានគណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ និង ឯកឧត្តមបណ្ឌិត **មិញ បានកុសល** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ និងជាប្រធានអនុគណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងទទួលបានការគាំទ្រពីអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "**ការកំណត់ហានិភ័យអ្នកជាប់ពន្ធ, ការពង្រឹងយន្តការនៃការគ្រប់គ្រងចំណូលពន្ធ, ការអញ្ជើញអ្នកជាប់ពន្ធមកចុះបញ្ជីពន្ធដារ និងការព្យួរសុពលភាពវិញ្ញាបនបត្រអាករលើតម្លៃបន្ថែម**" ចំនួនពីរលើកជូនមន្ត្រីពន្ធដារ គឺលើកទី១ នាថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅខេត្តរតនគិរី និងលើកទី២ នាថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៥ នៅខេត្តកោះកុង ក្រោមអធិបតីភាព លោក **ប៉ូ សណ្តាប់** ប្រធានលេខាធិការដ្ឋានការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ។ ក្នុងកម្មវិធីសិក្ខាសាលានេះ មានការធ្វើបទបង្ហាញដោយមន្ត្រីជំនាញនៃនាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ និងនាយកដ្ឋានសវនកម្មសហគ្រាស ព្រមទាំងមានការចូលរួមពីតំណាងសាខាពន្ធដារខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ក្រចេះ ត្បូងឃ្មុំ ស្វាយរៀង ព្រៃវែង កំពង់ចាម ឧត្តរមានជ័យ ព្រះវិហារ កោះកុង កណ្តាល កំពង់ធំ សៀមរាប ប៉ៃលិន ពោធិ៍សាត់ កំពង់ឆ្នាំង កំពង់ស្ពឺ បាត់ដំបង ព្រះសីហនុ តាកែវ កំពត កែប និងបន្ទាយមានជ័យ សរុបប្រមាណ **២០០ រូប**។

សិក្ខាសាលាដ៏មានសារៈសំខាន់នេះ ត្រូវបានរៀបចំឡើងស្របតាមគោលនយោបាយកែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ដែលផ្តោតលើការកែទម្រង់ និងការពង្រឹងអភិបាលកិច្ចល្អ ក៏ដូចជាការខិតខំកែទម្រង់របស់អគ្គនាយកដ្ឋានពន្ធដារ ក្នុងគោលដៅបន្តពង្រឹងសមត្ថភាពការងារគ្រប់គ្រង និងប្រមូលចំណូលពន្ធ ការបន្តធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធការកែលម្អសេវាអ្នកជាប់ពន្ធ ការលើកកម្ពស់វប្បធម៌បង់ពន្ធ និងការពង្រឹងអនុលោមភាពសារពើពន្ធ

ដែលនឹងធានាបាននូវចីរភាពចំណូល ក៏ដូចជាចូលរួមចំណែកលើកកម្ពស់ការប្រកួតប្រជែងដោយស្មើភាពជូនវិស័យឯកជន ស្របតាមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងយុទ្ធសាស្ត្រកៀរគរចំណូលផងដែរ ដើម្បីបញ្ជ្រាបចំណេះដឹងបន្ថែមទៀតដល់មន្ត្រីពន្ធដារលើប្រធានបទខាងលើ។

ថ្លែងក្នុងកម្មវិធីសិក្ខាសាលានេះ លោកប្រធានលេខាធិការដ្ឋាន PFM បានលើកឡើងថា កន្លងមកក្នុងកិច្ចខិតខំប្រឹងប្រែងប្រមូលចំណូលទៅតាមគោលដៅដែលច្បាប់បានកំណត់ ស្របតាមការកែទម្រង់ស៊ីជម្រៅ រាជរដ្ឋាភិបាលមិនមានគោលនយោបាយក្នុងការដំឡើងអត្រាពន្ធ ឬបង្កើតប្រភេទពន្ធថ្មី ដូច្នេះយន្តការសំខាន់ៗ និងវិធានការយ៉ាងម៉ឺងម៉ាត់ និងមុតស្រួច ទាំងវិធានការរដ្ឋបាល និងវិធានការគោលនយោបាយទាំងសម្រាប់រយៈពេលខ្លី និងមធ្យម ត្រូវបានដាក់ចេញឱ្យអនុវត្ត។ ទន្ទឹមនឹងនេះ ការលើកកម្ពស់វប្បធម៌បង់ពន្ធ និងពង្រឹងអនុលោមភាពសារពើពន្ធ ព្រមទាំងការបង្ក្រាបការគេចវេះពន្ធគ្រប់រូបភាព ទាមទារឱ្យមានការពង្រឹង និងបង្កើនសមត្ថភាពរដ្ឋបាលសារពើពន្ធ ជាពិសេស ការរៀបចំប្រព័ន្ធគ្រប់គ្រងមួយដ៏រឹងមាំ តម្លាភាព និងស័ក្តិសិទ្ធិភាព៕











# លោកបណ្ឌិត អេង រតនា អញ្ជើញជាអធិបតីក្នុងសិក្ខាសាលាផ្សព្វផ្សាយ ស្ដីពី "ភាតព្វកិច្ចសារពើពន្ធ និងពន្ធគយ សម្រាប់អាជីវកម្មដឹកជញ្ជូនទំនិញតាមផ្លូវទឹកជាអន្តរជាតិ"




នារសៀលថ្ងៃពុធ ទី៣ ខែធ្នូ ឆ្នាំ២០២៥ នៅសណ្ឋាគារ ហ៊ីម៉ាវ៉ារី (HIMAWARI HOTEL) អគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងសមាគមពាណិជ្ជករដឹកជញ្ជូន និងខ្សែប្រវាក់ផ្គត់ផ្គង់នៅកម្ពុជា (LOSCBA) បានសហការរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្ដីពី "**ភាតព្វកិច្ចសារពើពន្ធ និងពន្ធគយ សម្រាប់អាជីវកម្មដឹកជញ្ជូនទំនិញតាមផ្លូវទឹកជាអន្តរជាតិ**" ក្រោមអធិបតីភាព លោកបណ្ឌិត **អេង រតនា** ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ។ សិក្ខាសាលានេះក៏មានការចូលរួមពី លោក **ជា ចាន់តារ៉ា** ប្រធានសមាគម LOSCBA មន្ត្រីជំនាញពាក់ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធដារ តំណាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ព្រមទាំងមានការចូលរួមពីថ្នាក់ដឹកនាំសមាគម អភិបាល បណ្ណាធិការ និងតំណាងក្រុមហ៊ុនដែលជាសមាជិកនៃសមាគម សរុបប្រមាណ ១៤០ រូប៕



# អគ្គនាយកដ្ឋានពន្ធដារ និងធនាគារពិភពលោក (World Bank) សហការរៀបចំសិក្ខាសាលាស្ដីពី "ការបកស្រាយបទប្បញ្ញត្តិ នៃកិច្ចព្រមព្រៀងស្ដីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការអនុវត្តពន្ធអប្បបរមាសកល"



នាថ្ងៃចន្ទ ទី៨ ដល់ថ្ងៃព្រហស្បតិ៍ ទី១១ ខែធ្នូ ឆ្នាំ២០២៥ នៅបន្ទប់ប្រជុំបាយ័ននៃអគ្គនាយកដ្ឋានពន្ធដារ មានរៀបចំសិក្ខាសាលាស្ដីពី "**ការបកស្រាយបទប្បញ្ញត្តិ នៃកិច្ចព្រមព្រៀងស្ដីពី ការចៀសវាងការយកពន្ធត្រួតគ្នា និងការអនុវត្តពន្ធអប្បបរមាសកល**" សហការរៀបចំដោយអគ្គនាយកដ្ឋានពន្ធដារ និងធនាគារពិភពលោក (World Bank)។ សិក្ខាសាលានេះដឹកនាំដោយ លោកជំទាវ **ម៉ុន នារី** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ តំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ អមដោយ លោក **សេង ជាសិទ្ធ** ប្រធាននាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ និង លោក Yuki Araki អ្នកឯកទេសជាន់ខ្ពស់ផ្នែកអភិបាលកិច្ចនៃធនាគារពិភពលោក ព្រមទាំងមានការចូលរួមពីមន្ត្រីជំនាញពាក់ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធដារ និងតំណាងការិយាល័យធនាគារពិភពលោកប្រចាំនៅកម្ពុជា៕





# សិក្ខាសាលាតាមខេត្ត-ខណ្ឌ

នាថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៥ នៅ **សាខាពន្ធដារខេត្តកំពង់ស្ពឺ** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្ដីពី "អាករពិសេស អាករសម្រាប់បំភ្លឺសាធារណៈ និងអាករលើការស្នាក់នៅ" ជូនតំណាងសហគ្រាសក្រោមអធិបតីភាព លោក **ម៉ែត ចក់** ប្រធានសាខាពន្ធដារខេត្តកំពង់ស្ពឺ។



នាថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៥ នៅ **សាខាពន្ធដារខេត្តកំពង់ធំ** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្ដីពី "វិធាននៃការប្រើប្រាស់វិក្កយបត្រ និងកម្មវិធីវិក្កយបត្រនាំសំណាង (GDT Lucky Draw App)" ជូនតំណាងសហគ្រាស និងនិស្សិតមកពីសាកលវិទ្យាល័យឯកទេស នៃកម្ពុជា និងវិទ្យាស្ថានក្រុងអង្គរ ក្រោមអធិបតីភាព លោក **ជា មករា** អនុប្រធានសាខាពន្ធដារខេត្តកំពង់ធំ។



នាថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២៥ នៅ **សាខាពន្ធដារខេត្តបាត់ដំបង** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្ដីពី "ពន្ធលើប្រាក់បៀវត្ស ពន្ធកាត់ទុក កម្មវិធីទូរស័ព្ទដៃអ្នកជាប់ពន្ធ (GDT Taxpayer App) និងប្រព័ន្ធគ្រប់គ្រងការបង់ប្រាក់ពន្ធតាមអនឡាញ (e-Payment System)" ជូនតំណាងសហគ្រាសជាអ្នកជាប់ពន្ធមធ្យម ក្រោមអធិបតីភាព លោក **ហេង ជំនិត** ប្រធានសាខាពន្ធដារខេត្តបាត់ដំបង។



នាថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅ **សាខាពន្ធដារខណ្ឌ៧មករា** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្ដីពី "កម្មវិធីរដ្ឋបាលអេឡិចត្រូនិកពន្ធដារ (GDT e-Administration) និងវិធាននៃការប្រើប្រាស់វិក្កយបត្រ" សហគ្រាសជាអ្នកជាប់ពន្ធមធ្យម ក្រោមអធិបតីភាព លោក **ស៊ុន ឧទ្ធី** ប្រធានសាខាពន្ធដារខណ្ឌ៧មករា។



នាថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅ **សាខាពន្ធដារខេត្តកំពត** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្ដីពី "ច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងពន្ធប្រថាប់ត្រា ពន្ធលើអចលនទ្រព្យ ពន្ធលើដីធ្លីមិនបានប្រើប្រាស់ និងពន្ធលើចំណេញមូលធន" ជូនមេឃុំ ចៅសង្កាត់ និងអ្នកជាប់ពន្ធ ក្រោមអធិបតីភាព លោក **ហៀន សុខល់** ប្រធានសាខាពន្ធដារខេត្តកំពត។



នាថ្ងៃ២៥ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅ **សាខាពន្ធដារខេត្តកំពង់ធំ** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្ដីពី "បញ្ជីគណនេយ្យសាមញ្ញសម្រាប់អ្នកជាប់ពន្ធតូច ជូនតំណាងសហគ្រាសជាអ្នកជាប់ពន្ធតូច" ក្រោមអធិបតីភាព លោក **ម៉ូ ពិសិដ្ឋ** ប្រធានសាខាពន្ធដារខេត្តកំពង់ធំ។



នាថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅ **សាខាពន្ធដារខេត្តកំពង់ចាម** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្ដីពី "វិធាននៃការប្រើប្រាស់វិក្កយបត្រ បញ្ជីគណនេយ្យសាមញ្ញ និងកម្មវិធីប្រកាសពន្ធអាជីវកម្មសម្រាប់អ្នកជាប់ពន្ធតូច (GDT Tax Prefiling App)" ជូនតំណាងសហគ្រាស ក្រោមអធិបតីភាព លោក **គង់ សុវណ្ណនី** អនុប្រធានសាខាពន្ធដារកំពង់ចាម។



នាថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅ **សាខាពន្ធដារខេត្តកែប** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្ដីពី "សិទ្ធិនិងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ និងបញ្ជីគណនេយ្យសាមញ្ញសម្រាប់អ្នកជាប់ពន្ធតូច" ជូនតំណាងសហគ្រាសជាអ្នកជាប់ពន្ធតូច ក្រោមអធិបតីភាព លោកស្រី **ផល សុរី** ប្រធានសាខាពន្ធដារខេត្តកែប។



នាថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅ **សាខាពន្ធដារខណ្ឌមានជ័យ** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "ការបំពេញលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ" ជូនតំណាងសហគ្រាស និងភ្នាក់ងារសេវាកម្មពន្ធដារ ក្រោមអធិបតីភាព លោកស្រី **គាន រ៉ាមី** ប្រធានសាខាពន្ធដារខណ្ឌមានជ័យ។



នាថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅ **សាខាពន្ធដារខេត្តប៉ៃលិន** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "លិខិតជូនដំណឹងស្តីពីការប្រកាសបង់ពន្ធមិនបានត្រឹមត្រូវ បែបបទនិងនីតិវិធីសម្រាប់ការព្យួរ និងការផ្តល់ឡើងវិញនូវសុពលភាពវិញ្ញាបនបត្រអាករលើតម្លៃបន្ថែម" ជូនតំណាងសហគ្រាសជាអ្នកជាប់ពន្ធមធ្យម ក្រោមអធិបតីភាព លោកស្រី **ស៊ូ សុខធី** ប្រធានសាខាពន្ធដារខេត្តប៉ៃលិន។



នាថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៥ នៅ **សាខាពន្ធដារ ខេត្តប៉ៃលិន** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ និងពន្ធលើចំណេញមូលធន" ជូនមន្ត្រីពាក់ព័ន្ធនៃរដ្ឋបាលក្រុងប៉ៃលិន និងអ្នកជាប់ពន្ធ ក្រោមអធិបតីភាព លោកស្រី **ស៊ូ សុខធី** ប្រធានសាខាពន្ធដារខេត្តប៉ៃលិន។



នាថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៥ នៅ **សាខាពន្ធដារខណ្ឌចំការមន** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ និងកម្មវិធីរដ្ឋបាលអេឡិចត្រូនិកពន្ធដារ (GDT e-Administration)" ជូនតំណាងសហគ្រាសជាអ្នកជាប់ពន្ធមធ្យម ក្រោមអធិបតីភាព លោក **ម៉េង ឆុង** ប្រធានសាខាពន្ធដារខណ្ឌចំការមន។



នាថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៥ នៅ **សាខាពន្ធដារខេត្តតាកែវ** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "បញ្ជីគណនេយ្យសាមញ្ញ និងកម្មវិធីប្រកាសពន្ធអាជីវកម្មសម្រាប់អ្នកជាប់ពន្ធតូច (GDT Tax Prefiling App) លើមុខងារៈ ប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ" ជូនតំណាងសហគ្រាសជាអ្នកជាប់ពន្ធតូច ក្រោមអធិបតីភាព លោក **ខិន គឹមស្រេង** ប្រធានសាខាពន្ធដារខេត្តតាកែវ។



នាថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៥ នៅ **សាខាពន្ធដារខណ្ឌមានជ័យ** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "ការបំពេញលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (ToI e-Filing) ការបំពេញលិខិតប្រកាសពន្ធ ប្រចាំខែនិងប្រចាំឆ្នាំ លើមុខងារៈ ការលើកទឹកចិត្តផ្នែកពន្ធដារសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ" ជូនតំណាងសហគ្រាស និងភ្នាក់ងារសេវាកម្មពន្ធដារ ក្រោមអធិបតីភាព លោកស្រី **គាន រ៉ាមី** ប្រធានសាខាពន្ធដារខណ្ឌមានជ័យ ។



នាថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៥ នៅ **សាខាពន្ធដារខេត្តស្វាយរៀង** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (ToI e-Filing)" ជូនតំណាងសហគ្រាសជាអ្នកជាប់ពន្ធមធ្យម ក្រោមអធិបតីភាព លោក **ឥន្ទ ទឹម** ប្រធានសាខាពន្ធដារខេត្តស្វាយរៀង។




នាថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៥ នៅ **សាខាពន្ធដារខេត្តព្រៃវែង** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "សិទ្ធិនិងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ ពន្ធលើប្រាក់បៀវត្ស និងកម្មវិធីវិក្កយបត្រនាំសំណាង (GDT Lucky Draw)" ជូនលោកគ្រូ អ្នកគ្រូ និងនិស្សិតសាកលវិទ្យាល័យជាស៊ីមកំចាយមារ ក្រោមអធិបតីភាព លោក **ហ៊ូ ហោមរិទ្ធ** ប្រធានសាខាពន្ធដារខេត្តព្រៃវែង។



# បញ្ជរទទួលសេវាកម្មពន្ធដារ (Taxpayer Service Counter)

គិតចាប់ពីថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៥ មក អគ្គនាយកដ្ឋានពន្ធដារ បានបើកបញ្ជរផ្តល់សេវាពន្ធដារជូនអ្នកជាប់ពន្ធ នៅជាន់ទី២នៃអគារអគ្គនាយកដ្ឋានពន្ធដារថ្មី (GDT Tower) ដែលមានអាសយដ្ឋាននៅ អគារលេខ ៣៣៣ វិថីពន្ធដារ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ សម្រាប់សាធារណជននិងអ្នកជាប់ពន្ធដែលមានបំណងមកដាក់លិខិតរដ្ឋបាលនិងឯកសារនានាមករដ្ឋបាលសារពើពន្ធ។ បន្ថែមលើសនេះ បញ្ជរផ្តល់សេវាពន្ធដារមានមន្ត្រីប្រចាំការទទួលស្វាគមន៍សាធារណជននិងអ្នកជាប់ពន្ធមកសាកសួរព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងពន្ធដារ ជាអាទិ៍មាន ព័ត៌មានទូទៅ ព័ត៌មានអំពីបំណុលពន្ធ លិខិតប្រកាសពន្ធប្រចាំខែ និងប្រចាំឆ្នាំ ទាក់ទងនឹងការចុះបញ្ជីនិងការធ្វើបច្ចុប្បន្នភាពព័ត៌មាន ពន្ធលើចលនទ្រព្យ និងអចលនទ្រព្យ និងពន្ធលើផ្ទាំងផ្សព្វផ្សាយជាដើម។ បន្ថែមលើនេះ នៅជាន់ទី៣នៃអគារអគ្គនាយកដ្ឋានពន្ធដារថ្មី (GDT Tower) មានបន្ទប់ប្រជុំគ្រប់ប្រភេទជាច្រើនទាំងខ្នាតតូចនិងខ្នាតធំ ដែលមានបរិក្ខារសំបូរបែប ថ្មី ទំនើប និងមានផាសុកភាពខ្ពស់សម្រាប់ផ្តល់សេវាជូនអ្នកជាប់ពន្ធតាមតម្រូវការ ពិសេសការជួបពិគ្រោះយោបល់ផ្ទាល់ជាមួយមន្ត្រីពន្ធដារ។















ក្រៅពីដម្រើសមកទទួលបទពិសោធផ្ទាល់នៅអគារអគ្គនាយកដ្ឋានពន្ធដារថ្មី (GDT Tower) សាធារណជននិងអ្នកជាប់ពន្ធ ក៏អាចប្រើប្រាស់កម្មវិធីរដ្ឋបាលអេឡិចត្រូនិកពន្ធដារ (GDT e-Administration) ក្នុងការដាក់លិខិតរដ្ឋបាលនិងឯកសារនានាមករដ្ឋបាលសារពើពន្ធ ប្រកបដោយភាពងាយស្រួល ឆាប់រហ័ស ចំណេញពេលវេលា និងមានប្រសិទ្ធភាពខ្ពស់លើការរក្សាទុក ព្រមទាំងអាចតាមដានដំណើរការរាល់ឯកសារដែលបានបញ្ជូនមករដ្ឋបាលសារពើពន្ធបានទៀតផង៕



# អគ្គនាយកដ្ឋានពន្ធដារ

# សូមស្វាគមន៍

សូមទូរស័ព្ទទៅកាន់ **១២៧៧** រួចចុច **លេខតំណភ្ជាប់របស់អង្គភាព**

(ដោយមិនចាំបាច់ជ្រើសរើសភាសា)

ដើម្បីទាក់ទងទៅកាន់នាយកដ្ឋាន ឬសាខាពន្ធដារខេត្ត-ខណ្ឌ

**(ដោយឥតគិតថ្លៃ)**



អគារលេខ ៣៣៣ វិថីពន្ធដារ ភូមិដើមគរ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ
សារអេឡិចត្រូនិក: gdt@tax.gov.kh លេខទូរស័ព្ទ: (855) 23 266 668

## អាសយដ្ឋាននាយកដ្ឋាន សាលាជាតិពន្ធដារ ទីចាត់ការពន្ធដាររាជធានីភ្នំពេញ និងសាខាពន្ធដារខេត្ត-ខណ្ឌ

## នាយកដ្ឋានថ្នាក់កណ្ដាល អង្គភាពសវនកម្មពន្ធដារពិសេស សាលាជាតិពន្ធដារ និងទីចាត់ការពន្ធដាររាជធានីភ្នំពេញ

### នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ

អគារលេខ ៣៣៣ វិថីពន្ធដារ ភូមិដើមគរ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ១០៩៩
សារអេឡិចត្រូនិក: admin.info@tax.gov.kh

### នាយកដ្ឋានហិរញ្ញវត្ថុ និងបុគ្គលិក

អគារលេខ ៣៣៣ វិថីពន្ធដារ ភូមិដើមគរ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ១៨០០
សារអេឡិចត្រូនិក: dfp@tax.gov.kh

### នាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ

អគារលេខ ៣៣៣ វិថីពន្ធដារ ភូមិដើមគរ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ២១០០
សារអេឡិចត្រូនិក: dlpic@tax.gov.kh

### នាយកដ្ឋានពន្ធចលនទ្រព្យ និងអចលនទ្រព្យ

អគារលេខ ៣៣៣ វិថីពន្ធដារ ភូមិដើមគរ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ២៧០១
សារអេឡិចត្រូនិក: dpt@tax.gov.kh

### នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន

អគារលេខ ៣៣៣ វិថីពន្ធដារ ភូមិដើមគរ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៨០១៤
សារអេឡិចត្រូនិក: dit@tax.gov.kh

### នាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ

អគារលេខ ៣៣៣ វិថីពន្ធដារ ភូមិដើមគរ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៣២០១
សារអេឡិចត្រូនិក: dtci@tax.gov.kh

### នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ

អគារលេខ ៣៣៣ វិថីពន្ធដារ ភូមិដើមគរ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៣៦០១
សារអេឡិចត្រូនិក: dlt@tax.gov.kh

### នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម

អគារលេខ ៣៣៣ វិថីពន្ធដារ ភូមិដើមគរ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៤៩០០
សារអេឡិចត្រូនិក: dsmt@tax.gov.kh

### នាយកដ្ឋានសវនកម្មសហគ្រាស

អគារលេខ ៣៣៣ វិថីពន្ធដារ ភូមិដើមគរ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៥៦០០
សារអេឡិចត្រូនិក: dea@tax.gov.kh

### អង្គភាពសវនកម្មពន្ធដារពិសេស

អគារលេខ ៣៣៣ វិថីពន្ធដារ ភូមិដើមគរ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៦០០១
សារអេឡិចត្រូនិក: USTA@tax.gov.kh

### សាលាជាតិពន្ធដារ

អគារលេខ៤១-៤៣ ផ្លូវ១១២ សង្កាត់ផ្សារដេប៉ូ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ (ខាងកើតអគ្គនាយកដ្ឋានពន្ធដារ)
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៦៤០១
សារអេឡិចត្រូនិក: nts@tax.gov.kh

### ទីចាត់ការពន្ធដាររាជធានីភ្នំពេញ

អគារកែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៦៨០១
សារអេឡិចត្រូនិក: ppmd@tax.gov.kh

## សាខាពន្ធដារខណ្ឌ

### សាខាពន្ធដារ ខណ្ឌឫស្សីកែវ

អគារ១០២ ផ្លូវជាតិលេខ៥ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩០០៧
សារអេឡិចត្រូនិក: russeykeo@tax.gov.kh

### សាខាពន្ធដារ ខណ្ឌដូនពេញ

ផ្ទះលេខ១៦៦ ផ្លូវលេខ១៣០ សង្កាត់ផ្សារកណ្ដាលទី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩០៣២
សារអេឡិចត្រូនិក: daunpenh@tax.gov.kh

### សាខាពន្ធដារ ខណ្ឌ៧មករា

ដីឡូលេខ០៥ ផ្លូវលេខ១៥០ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩០៥៧
សារអេឡិចត្រូនិក: 7makara@tax.gov.kh

### សាខាពន្ធដារ ខណ្ឌមានជ័យ

អគារលេខ៣៤C ផ្លូវ៣៦១ កែងផ្លូវ៦៤២ សង្កាត់ច្បារអំពៅ១ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩០៨៣
សារអេឡិចត្រូនិក: meanchey@tax.gov.kh

### សាខាពន្ធដារ ខណ្ឌចំការមន

អគារលេខ២៨ ផ្លូវលេខ៤៨៨ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩១០៩
សារអេឡិចត្រូនិក: chamkarmorn@tax.gov.kh

### សាខាពន្ធដារ ខណ្ឌទួលគោក

ផ្ទះលេខ២៤ ផ្លូវ២៨៧ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩១៣៥
សារអេឡិចត្រូនិក: tuolkork@tax.gov.kh

### សាខាពន្ធដារ ខណ្ឌដង្កោ

ផ្លូវ២១៧ ភូមិល្វេស សង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩១៦១
សារអេឡិចត្រូនិក: dangkor@tax.gov.kh

### សាខាពន្ធដារ ខណ្ឌសែនសុខ

អគារលេខ៩ ផ្លូវលេខ១០១៩(ហាណូយ) សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩១៨៨
សារអេឡិចត្រូនិក: sensok@tax.gov.kh

### សាខាពន្ធដារ ខណ្ឌពោធិ៍សែនជ័យ

ផ្ទះលេខ២៣៤B ផ្លូវលេខ ២០០៧ សង្កាត់កាកាប១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩២១៣
សារអេឡិចត្រូនិក: porsenchey@tax.gov.kh

## សាខាពន្ធដារខេត្ត

### សាខាពន្ធដារ ខេត្តបន្ទាយមានជ័យ

ភូមិក្បាលស្ពាន សង្កាត់ព្រះពន្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ(ខាងត្បូងស្ពានសៃសិនចំងាយ ៣០០ម៉ែត្រ តាមបណ្តោយផ្លូវជាតិលេខ៥ ឆ្ពោះទៅកាន់ស្រុកមង្គលបូរី)
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៧០៨
សារអេឡិចត្រូនិក: banteaymeanchey@tax.gov.kh

### សាខាពន្ធដារ ខេត្តបាត់ដំបង

ផ្ទះលេខ២ ផ្លូវជាតិលេខ៥ សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩២៩២
សារអេឡិចត្រូនិក: battambang@tax.gov.kh

### សាខាពន្ធដារ ខេត្តកំពង់ចាម

ផ្ទះលេខ៥ ភូមិទី១៥ ផ្លូវខេមរភូមិន្ទ សង្កាត់កំពង់ចាម ក្រុងកំពង់ចាម ខេត្តកំពង់ចាម
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩២៦៥
សារអេឡិចត្រូនិក: kampongcham@tax.gov.kh

### សាខាពន្ធដារ ខេត្តកំពង់ឆ្នាំង

ភូមិឃ្លាំងប្រាក់ សង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៤៧៣
សារអេឡិចត្រូនិក: kampongchhnang@tax.gov.kh

### សាខាពន្ធដារ ខេត្តកំពង់ធំ

ភូមិបល្ល័ង្កលិច សង្កាត់ដំរីជាន់ខ្លា ក្រុងស្ទឹងសែន ខេត្តកំពង់ធំ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៣៦៩
សារអេឡិចត្រូនិក: kampongthom@tax.gov.kh

### សាខាពន្ធដារ ខេត្តកំពង់ស្ពឺ

ផ្លូវជាតិលេខ៤ ភូមិត្រពាំងលើក សង្កាត់រកាធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៤៩៩
សារអេឡិចត្រូនិក: kampongspeu@tax.gov.kh

### សាខាពន្ធដារ ខេត្តកំពត

ផ្លូវលេខ៧២៩ ភូមិ១ឧសភា សង្កាត់កំពង់កណ្តាល ក្រុងកំពត ខេត្តកំពត
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៥២៦
សារអេឡិចត្រូនិក: kampot@tax.gov.kh

### សាខាពន្ធដារ ខេត្តកណ្តាល

អគារលេខ២៦ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩២៣៩
សារអេឡិចត្រូនិក: kandal@tax.gov.kh

### សាខាពន្ធដារ ខេត្តកោះកុង

អគារកែងផ្លូវលេខ៩០០ និងផ្លូវលេខ៩៩៥ ភូមិ២ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៥៧៧
សារអេឡិចត្រូនិក: kohkong@tax.gov.kh

### សាខាពន្ធដារ ខេត្តក្រចេះ

ភូមិក្រចេះ សង្កាត់ក្រចេះ ក្រុងក្រចេះ ខេត្តក្រចេះ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៦៣០
សារអេឡិចត្រូនិក: kratie@tax.gov.kh

### សាខាពន្ធដារ ខេត្តមណ្ឌលគិរី

ផ្លូវលេខ ៣៧៦៣ ភូមិកណ្តាល សង្កាត់ស្ពានមានជ័យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៦៨១
សារអេឡិចត្រូនិក: mondulkiri@tax.gov.kh

### សាខាពន្ធដារ ខេត្តព្រៃវែង

អាគារកែងផ្លូវលេខ៥ និងផ្លូវលេខ៣ ភូមិ២ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៣១៨
សារអេឡិចត្រូនិក: preyveng@tax.gov.kh

### សាខាពន្ធដារ ខេត្តព្រះវិហារ

ភូមិអណ្តូងពោធិ៍ សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៦០៤
សារអេឡិចត្រូនិក: preahvihear@tax.gov.kh

### សាខាពន្ធដារ ខេត្តពោធិ៍សាត់

ផ្លូវជាតិលេខ៥ ភូមិមាន់ចៃ សង្កាត់ព្រៃញី ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៤៤៧
សារអេឡិចត្រូនិក: pursat@tax.gov.kh

### សាខាពន្ធដារ ខេត្តរតនគិរី

ផ្លូវលេខ ២០ ភូមិថ្មដា សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៦៥៥
សារអេឡិចត្រូនិក: ratanakiri@tax.gov.kh

### សាខាពន្ធដារ ខេត្តសៀមរាប

ផ្លូវជាតិលេខ 6 ភូមិសាលាកន្សែង សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៣៤៣
សារអេឡិចត្រូនិក: siamreap@tax.gov.kh

### សាខាពន្ធដារ ខេត្តព្រះសីហនុ

វិថី ២៨មិថុនា ភូមិ០១ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៥៥២
សារអេឡិចត្រូនិក: preahsihanouk@tax.gov.kh

### សាខាពន្ធដារ ខេត្តស្ទឹងត្រែង

ផ្លូវភូមិស្ពានថ្ម សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៧៣៣
សារអេឡិចត្រូនិក: stoengtreng@tax.gov.kh

### សាខាពន្ធដារ ខេត្តស្វាយរៀង

ផ្លូវលេខ៣១៤ ភូមិពោធិ៍តាហោ សង្កាត់ពោធិ៍តាហោ ក្រុងស្វាយរៀង ខេត្តស្វាយរៀង
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៤២១
សារអេឡិចត្រូនិក: svayrieng@tax.gov.kh

### សាខាពន្ធដារ ខេត្តតាកែវ

ភូមិ១ សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៣៩៦
សារអេឡិចត្រូនិក: takeo@tax.gov.kh

### សាខាពន្ធដារ ខេត្តឧត្តរមានជ័យ

អគារខាងលិចសាលាខេត្ត ទល់មុខវិមានឯករាជ្យ ភូមិបុរីរដ្ឋបាល សង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៨១១
សារអេឡិចត្រូនិក: odormeanchey@tax.gov.kh

### សាខាពន្ធដារ ខេត្តកែប

ផ្លូវលេខ២៣៥០ ភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៧៥៩
សារអេឡិចត្រូនិក: kep@tax.gov.kh

### សាខាពន្ធដារ ខេត្តប៉ៃលិន

ភូមិប៉ាហ៊ីត្បូង សង្កាត់ប៉ៃលិន ក្រុងប៉ៃលិន ខេត្តប៉ៃលិន
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៧៨៥
សារអេឡិចត្រូនិក: pailin@tax.gov.kh

### សាខាពន្ធដារ ខេត្តត្បូងឃ្មុំ

ភូមិនិគមលើ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ (ជាប់ខាងត្បូងសាលាឧទ្ធរណ៍ខេត្តត្បូងឃ្មុំ)
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៨៣៧
សារអេឡិចត្រូនិក: tboungkhmum@tax.gov.kh

# កម្មវិធីទូរស័ព្ទដៃពេញនិយមទាំង ១០ របស់អគ្គនាយកដ្ឋានពន្ធដារ

## កម្មវិធីទូរស័ព្ទដៃអ្នកជាប់ពន្ធ (GDT Taxpayer App)

សម្រាប់បង់ពន្ធលើអចលនទ្រព្យ ពន្ធលើមធ្យោបាយដឹកជញ្ជូន និងពន្ធលើផ្ទាំងផ្សព្វផ្សាយ

App Store | Google Play

សូមស្កេន ដើម្បីទាញយកកម្មវិធី

## កម្មវិធីប្រកាសពន្ធសម្រាប់អ្នកជាប់ពន្ធតូច (GDT Tax Prefiling App)

សម្រាប់ប្រកាសពន្ធប្រចាំខែ និងប្រចាំឆ្នាំ របស់សហគ្រាសដែលជាអ្នកជាប់ពន្ធតូច

App Store | Google Play

សូមស្កេន ដើម្បីទាញយកកម្មវិធី

## កម្មវិធីត្រួតពិនិត្យ និងតាមដានឯកសារ (GDT Check & Track App)

សម្រាប់តាមដានឯកសារដែលបានដាក់ស្នើមករដ្ឋបាលសារពើពន្ធ ពិនិត្យភាពត្រឹមត្រូវនៃឯកសារ ដែលមាន QR Code ចេញដោយអគ្គនាយកដ្ឋានពន្ធដារ

App Store | Google Play

សូមស្កេន ដើម្បីទាញយកកម្មវិធី

## កម្មវិធីគណនាពន្ធលើប្រាក់បៀវត្ស (GDT Salary Tax Calculation App)

សម្រាប់គណនាពន្ធលើប្រាក់បៀវត្សប្រចាំខែដែលត្រូវបង់

App Store | Google Play

សូមស្កេន ដើម្បីទាញយកកម្មវិធី

## កម្មវិធីគណនាពន្ធលើមធ្យោបាយដឹកជញ្ជូន (GDT Means of Transportation Tax Calculation App)

សម្រាប់គណនាប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូន ដែលត្រូវបង់ប្រាក់ពន្ធប្រចាំឆ្នាំ

App Store | Google Play

សូមស្កេន ដើម្បីទាញយកកម្មវិធី

## ព័ត៌មានពន្ធដារ (GDT News App)

សម្រាប់ទទួលបានព័ត៌មាន វគ្គបណ្តុះបណ្តាល សិក្ខាសាលា ច្បាប់និងលិខិតបទដ្ឋានគតិយុត្ត វីដេអូផ្សេងៗទៀតស្តីពីពន្ធដារ...

App Store | Google Play

សូមស្កេន ដើម្បីទាញយកកម្មវិធី

## កម្មវិធីជជែកផ្ទាល់ជាមួយពន្ធដារ (GDT Live Chat App)

សម្រាប់សាកសួរព័ត៌មានផ្សេងៗស្តីពីពន្ធដារ ( ផ្នែកពន្ធទូទៅ និង e-Tax Service )

App Store | Google Play

សូមស្កេន ដើម្បីទាញយកកម្មវិធី

## ប្រតិទិនពន្ធដារ (GDT Calendar App)

អាចពិនិត្យកាលបរិច្ឆេទដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធប្រចាំខែ និងឆ្នាំ

App Store | Google Play

សូមស្កេន ដើម្បីទាញយកកម្មវិធី

## កម្មវិធីសទ្ទានុក្រមពន្ធដារ (Tax Glossary App)

សម្រាប់ស្វែងរកពាក្យគន្លឹះផ្សេងៗស្តីពីពន្ធដារ

App Store | Google Play

សូមស្កេន ដើម្បីទាញយកកម្មវិធី

## កម្មវិធីវិក្កយបត្រនាំសំណាង (GDT Lucky Draw App)

សម្រាប់បញ្ចូលវិក្កយបត្រ ដើម្បីចូលរួមផ្សងសំណាងឈ្នះរង្វាន់ជាច្រើនពីអគ្គនាយកដ្ឋានពន្ធដារ

App Store | Google Play

សូមស្កេន ដើម្បីទាញយកកម្មវិធី

## មជ្ឈមណ្ឌលពិគ្រោះយោបល់តាមទូរស័ព្ទរបស់អគ្គនាយកដ្ឋានពន្ធដារ ( ១២៧៧ )
## មានចម្ងល់ពីពន្ធដារ មិនដឹងសួរនៅទីណាមែនទេ ?




## ឬលោកអ្នកអាច Chat សួរសំណួរពីពន្ធដារតាម
## កម្មវិធី GDT Live Chat ដោយគ្រាន់តែស្កេន QR Code ខាងក្រោម



# ការបង់ពន្ធលើអចលនទ្រព្យកាន់តែងាយស្រួលតាមរយៈមុខងារថ្មី Quick Payment ក្នុងកម្មវិធីទូរស័ព្ទដៃអ្នកជាប់ពន្ធ ( GDT Taxpayer App )



**ជំហានទី១** ត្រូវជ្រើសរើសជម្រើសណាមួយក៏បានក្នុងចំណោមជម្រើសទាំង ៤ រួមមាន ៖

- ស្កេនបារកូដសម្គាល់អចលនទ្រព្យលើសេចក្តីជូនដំណឹងបង់ប្រាក់ពន្ធលើអចលនទ្រព្យ ឬ
- ស្កេនបារកូដលើកាតសម្គាល់ការបង់ពន្ធលើអចលនទ្រព្យ ឬ
- បញ្ចូលលេខអត្តសញ្ញាណសម្គាល់អចលនទ្រព្យ (PIN) ឬ
- បញ្ចូលលេខបង្កាន់ដៃបង់ប្រាក់ពន្ធឆ្នាំចាស់






## ជំហានទី២

ជ្រើសរើសធនាគារពាណិជ្ជដៃគូរបស់អគ្គនាយកដ្ឋានពន្ធដារណាមួយក៏បានដើម្បីបង់ប្រាក់ពន្ធជាការស្រេច។




GDT Taxpayer App

សូមស្កេន ដើម្បីទាញយកកម្មវិធី

Download on the App Store
GET IT ON Google Play

សូមស្កេនដើម្បីទស្សនាវីដេអូណែនាំកម្មវិធីទូរស័ព្ទដៃសម្រាប់អ្នកជាប់ពន្ធ GDT Taxpayer App

# កម្មវិធីរដ្ឋបាលអេឡិចត្រូនិកពន្ធដារ ( GDT e-Administration)

**ដាក់លិខិតរដ្ឋបាលនិងឯកសារនានាមករដ្ឋបាលសារពើពន្ធបានពីគ្រប់ទីកន្លែង ដោយគ្រាន់តែប្រើប្រាស់កម្មវិធីរដ្ឋបាលអេឡិចត្រូនិកពន្ធដារ ( GDT e-Administration ) តាមជំហានងាយៗដូចខាងក្រោម៖**

**ជំហានទី ១**

ចូលទៅកាន់គេហទំព័រផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ **https://www.tax.gov.kh** ជ្រើសរើសសេវាកម្មអេឡិចត្រូនិកពន្ធដារ និងទាញយក (**Download**) កម្មវិធីរដ្ឋបាលអេឡិចត្រូនិកពន្ធដារ (**GDT e-Administration**) រួចដំឡើង (**Setup**) កម្មវិធីនេះនៅលើកុំព្យូទ័រជាការស្រេច។

**ជំហានទី ២**

ប្រើប្រាស់គណនីដែលមានស្រាប់ដូចធ្លាប់ចូលប្រើប្រាស់ប្រព័ន្ធ កម្មវិធីផ្សេងៗរបស់អគ្គនាយកដ្ឋានពន្ធដារ ក្នុងករណីមិនទាន់មានគណនី សូមចុះឈ្មោះប្រើប្រាស់ដោយចុច "**បង្កើតគណនីថ្មី**"។

**ជំហានទី ៣**

ជ្រើសរើសប្រភេទអ្នកប្រើប្រាស់ជា អ្នកជាប់ពន្ធ ឬភ្នាក់ងារសេវាកម្មពន្ធដារ ឬអ្នកតំណាងសហគ្រាស រួចបញ្ចូលព័ត៌មាន និងឯកសារដែលកម្មវិធីតម្រូវ។

**ជំហានទី ៤**

ចុចម៉ឺនុយ "**បង្កើតលិខិតរដ្ឋបាលថ្មី**" បន្ទាប់មកបញ្ចូលព័ត៌មានអ្នកស្នើសុំ កម្មវត្ថុនៃលិខិត និងខ្លឹមសារសង្ខេប រួចជ្រើសរើសអង្គភាពដែលត្រូវទទួលលិខិត។

**ជំហានទី ៥**

ភ្ជាប់លិខិតរដ្ឋបាលនិងឯកសារយោងផ្សេងៗ (**Attachment**) ជាទម្រង់ **PDF** បន្ទាប់មកពិនិត្យផ្ទៀងផ្ទាត់ព័ត៌មានដែលបានបញ្ចូលព្រមទាំងឯកសារភ្ជាប់ឡើងវិញ រួចចុចបញ្ជូនជាការស្រេច។

**សូមស្កេន QR Codes ដើម្បីទស្សនាវីដេអូណែនាំ**



បុគ្គលទូទៅ | ភ្នាក់ងារសេវាកម្មពន្ធដារ | អ្នកតំណាងសហគ្រាស




**កម្មវិធី រដ្ឋបាលអេឡិចត្រូនិកពន្ធដារ (GDT e-Administration)**

# ប្រភពព័ត៌មានអំពីពន្ធដារ




## គេហទំព័រហ្វេសប៊ុកផ្លូវការរបស់ អគ្គនាយកដ្ឋានពន្ធដារ

សូមស្កេនដើម្បីចូលទៅកាន់គេហទំព័រហ្វេសប៊ុកផ្លូវការ




## ឆានែលតេឡេក្រាម ព័ត៌មានពន្ធដារកម្ពុជា

សូមស្កេនដើម្បីចូលទៅកាន់ឆានែលតេឡេក្រាម




## លោកអ្នកអាចធ្វើការពិគ្រោះយោបល់ផ្ទាល់ តាមរយៈកម្មវិធីជជែកផ្ទាល់ជាមួយពន្ធដារ (GDT Live Chat)

Download on the App Store

GET IT ON Google Play

សូមស្កេនដើម្បីទាញយកកម្មវិធី GDT LIVE CHAT

# កម្មវិធីឆែតបត់ពន្ធដារ ( បូណ៍មី - BEAURAMEI)

## កម្មវិធីឆែតបត់ពន្ធដារ “បូណ៍មី” របស់អគ្គនាយកដ្ឋានពន្ធដារ

( GDT Chatbot – Called “BEAURAMEI” ) គឺជាកម្មវិធីបច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត ( Artificial Intelligent – AI ) ដែលត្រូវបានអភិវឌ្ឍ និងធ្វើរចនាបទឡើងដោយអ្នកអភិវឌ្ឍកម្មវិធីបច្ចេកវិទ្យាព័ត៌មាននៃអគ្គនាយកដ្ឋានពន្ធដារ សម្រាប់បំពេញមុខងារស្រដៀងគ្នាទៅនឹងទម្រង់សារឆ្លើយឆ្លងជាអក្សរ ( Text Messages ) រវាងមនុស្សនឹងមនុស្ស។តាមរយៈការសន្ទនាឆ្លើយឆ្លងជាមួយអ្នកប្រើប្រាស់ក្នុងទម្រង់អក្សរ ( TextMessages ) “បូណ៍មីឬBEAURAMEI” មានសមត្ថភាពផ្តល់ឯកសារពាក់ព័ន្ធ និងផ្តល់ព័ត៌មានដោយផ្អែកលើច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារព្រមទាំងផ្តល់ជាជម្រើសសំណួរពាក់ព័ន្ធបន្ថែមសម្រាប់អ្នកប្រើប្រាស់សន្ទនាបន្តដើម្បីទទួលបានព័ត៌មានកាន់តែលម្អិត និងចំគោលដៅស្របតាមតម្រូវការ៕



សូមស្កេន QR កូដដើម្បីចូលទៅកាន់កម្មវិធីឆែតបត់ពន្ធដារ “បូណ៍មី” នៅក្នុង Telegram

សូមស្កេន QR កូដដើម្បីចូលទៅកាន់របៀបប្រើប្រាស់កម្មវិធីឆែតបត់ពន្ធដារ “បូណ៍មី” នៅក្នុង Youtube

# កម្មវិធី GDT Lucky Draw Bot របស់អគ្គនាយកដ្ឋានពន្ធដារ

## GDT Lucky Draw Bot របស់អគ្គនាយកដ្ឋានពន្ធដារ

កាន់តែលឿន និងងាយស្រួលជាងមុន






សូមស្កេន QR កូដដើម្បីចូលទៅកាន់កម្មវិធី GDT Lucky Draw Bot នៅក្នុង Telegram

សូមស្កេន QR កូដដើម្បីចូលទៅកាន់របៀបប្រើប្រាស់កម្មវិធី GDT Lucky Draw Bot នៅក្នុង Youtube

# ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានពន្ធដារកម្ពុជា ( GDT Home Tax)

ពហុមុខងារឌីជីថលរួម (**Unify Digital Platform**) ដែលផ្តល់នូវសេវាកម្មគាំទ្រ ប្រៀបបានទៅនឹងច្រកចេញ-ចូលតែមួយទម្រង់ឌីជីថលដែលមានមុខងារ ដូចជា៖ មុខងារគាំទ្រផ្នែកសុវត្ថិភាព, មុខងារសារជូនដំណឹង, មុខងារ **QR Code** ឆ្លាតវៃ, មុខងារទំនាក់ទំនងផ្ទាល់

**Login** តែម្តង ដើម្បីចូលប្រើប្រាស់ប្រព័ន្ធរបស់អពដ, ចំណេញពេលវេលា

កាន់តែងាយស្រួលប្រើប្រាស់ កាន់តែសាមញ្ញរហ័ស ប្រកបដោយទំនុកចិត្ត និងប្រសិទ្ធភាព

**ការកំណត់សិទ្ធិ** (**RAM-Relationship Authorization Management**)
- អនុញ្ញាតឱ្យម្ចាស់សហគ្រាស អាចកំណត់សិទ្ធិ ឱ្យទៅអ្នកតំណាង ឬភ្នាក់ងារសេវាកម្មពន្ធដារណាមួយ ឱ្យធ្វើប្រតិបត្តិការទៅតាមសិទ្ធិដែលបានកំណត់
- ជាមុខងារដែលមានដំបូងគេបំផុតនៅកម្ពុជា

អ្នកប្រើប្រាស់អាចទទួលបានព័ត៌មានថ្មីៗទាក់ទងនឹងពន្ធដារ និងចំណេះដឹងអំពីពន្ធដារ (**e-Learning**)






www.tax.gov.kh/km/tax-bulletin

សូមស្កេន QR Code
ដើម្បីទទួលបានព្រឹត្តិបត្រពន្ធដារ
តាមរយៈទូរស័ព្ទដៃ




www.tax.gov.kh/km/tax-news-letter

សូមស្កេន QR Code
ដើម្បីទទួលបាន
ព្រឹត្តិបត្រព័ត៌មានប្រចាំសប្តាហ៍
តាមរយៈទូរស័ព្ទដៃ

**ព្រឹត្តិបត្រពន្ធដារ** ជាមធ្យោបាយដ៏សំខាន់ក្នុងការផ្សព្វផ្សាយព័ត៌មានថ្មីៗ សំខាន់ៗ និងជាផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារទៅកាន់សាធារណជន អ្នកជាប់ពន្ធ និងភាគីពាក់ព័ន្ធ។ បណ្តុំព័ត៌មានដែលបានចងក្រងក្នុងព្រឹត្តិបត្រពន្ធដារ គឺជាសម្រង់ព្រឹត្តិការណ៍-គោលនយោបាយសារពើពន្ធរបស់រាជរដ្ឋាភិបាល ក៏ដូចជាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សកម្មភាពគួរឱ្យកត់សម្គាល់នានារបស់ថ្នាក់ដឹកនាំអគ្គនាយកដ្ឋានពន្ធដារ លទ្ធផលការងារដែលសម្រេចបានរបស់អគ្គនាយកដ្ឋានពន្ធដារព្រមទាំងបានចងក្រងនូវលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារដែលបានដាក់ឱ្យអនុវត្ត។

ការចែករំលែកព័ត៌មានជាទៀងទាត់តាមរយៈព្រឹត្តិបត្រពន្ធដារ បានឆ្លុះបញ្ចាំងពីតម្លាភាព និងគណនេយ្យភាពចំពោះការអនុវត្តតួនាទី និងភារកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ ថែមទាំងជួយកសាងទំនាក់ទំនងល្អជាមួយសាធារណជន អ្នកជាប់ពន្ធ និងភាគីពាក់ព័ន្ធ ដោយផ្តល់ឱ្យអ្នកអាននូវការយល់ដឹងកាន់តែស៊ីជម្រៅអំពីសកម្មភាពការងារ និងគោល-នយោបាយពាក់ព័ន្ធនឹងពន្ធដារ។  បន្ថែមពីនេះ ព្រឹត្តិបត្រពន្ធដារមានលក្ខណសម្បត្តិជាកំណត់ត្រាវឌ្ឍនភាពការងារ ព្រឹត្តិការណ៍សំខាន់ៗ និងជាប្រភពព័ត៌មានដែលមានសារៈប្រយោជន៍សម្រាប់ពេលអនាគត ទាំងសម្រាប់រដ្ឋបាលសារពើពន្ធ ក៏ដូចជាសាធារណជន អ្នកជាប់ពន្ធ និងភាគីពាក់ព័ន្ធ។

ជារួម ព្រឹត្តិបត្រពន្ធដារ ដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្សព្វផ្សាយព័ត៌មាន បង្កើនតម្លាភាព និងគណនេយ្យភាពនៃការអនុវត្តតួនាទី និងភារកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ និងបានគាំទ្រដល់មុខងារទំនាក់ទំនងជាមួយសាធារណជន អ្នកជាប់ពន្ធ និងភាគីពាក់ព័ន្ធកាន់តែប្រសើរឡើង។




សម្រាប់ព័ត៌មានបន្ថែមលោកអ្នកអាចទំនាក់ទំនងតាមរយៈ

Website Facebook Instagram Youtube Telegram

អគារលេខ៖ ៣៣៣ វិថីពន្ធដារ ភូមិដើមគរ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

មជ្ឈមណ្ឌលពិគ្រោះយោបល់ / **Call Center** ៖ ១២៧៧ (ដោយឥតគិតថ្លៃ) | គេហទំព័រ ៖ www.tax.gov.kh | សារអេឡិចត្រូនិក ៖ gdt@tax.gov.kh